ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- ការបញ្ចប់អំពើប្រល័យពូជសាសន៍ខ្មែរក្រហម
- ជម្លោះកោះរវាងកម្ពុជាប្រជាធិបតេយ្យ និង ប្រទេសវៀតណាម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ១៨៣ ខែមីនា ឆ្នាំ២០១៥

ស្វែងរកការពិត

លេខ១៨៣ ខែមីនា ឆ្នាំ២០១៥

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា

◆ ការបញ្ចប់អំពើប្រល័យពូជសាសន៍ខ្មែរក្រហម ....................................១

**ផ្នែកឯកសារ**

◆ ចម្លើយសារភាព ណែន ទុយ ហៅ ភី ..........................................៤

◆ យុវនារីថន ធ្វើពលិកម្មគ្រប់បែបយ៉ាងដោយ ....................................៩

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ជម្លោះកោះរវាងកម្ពុជាប្រជាធិបតេយ្យ និង..................................១៧

◆ មិនដឹងរឿងអាក្រក់របស់ខ្មែរក្រហម.............................................២២

◆ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដើម្បី.........................................២៤

◆ ចាប់ពីរបបខ្មែរក្រហមដល់ខប្បត្តិហេតុ ហាំបាលី .............................២៦

**ផ្នែកច្បាប់**

◆ តើអ្វីជា "ភាពវិសាមញ្ញ" ចំពោះពាក្យយុត្តិធម៌...............................៤៣

**វេទិកាពិភាក្សាសាធារណៈ**

◆ ដំណើរវិជ្ជមានឆ្ពោះទៅរកការកាត់ទោសជនសង្ស័យ ..........................៤៩

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ មានទោសព្រោះអ្វី? ..................................................................៥០

◆ ដំណើរភៀសខ្លួនឆ្លងដែនពីរបប .....................................................៥៥





ប្រជាជនភូមិកំពង់ឈើទាល ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ចូលរួមវេទិកាពិភាក្សាសាធារណៈ រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈមជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

***ស្នេរលេខនេះ*** ៖ *អេង កុកថាយ, ម៉ែន ពិចិត្រ, ស៊ាង ចិន្តា, ដេវីដ សេហូហ៊្វើ, លឹម ជ័យទត្ត, ជូ សូភា, ជា សីហា* ***អ្នកនិពន្ធនិងស្រាវជ្រាវ*** ៖ *ទាវ សារៈមុនិន្ទ និង ឌី សុជាតា* ***អ្នកបកប្រែ*** ៖ *សាយ សូលីដា, សុភ័ក្ត្រ ភាណា* ***និពន្ធនាយកទូទៅ*** ៖ *ឆាំង យុ* ***ជំនួយការនិពន្ធនាយក*** ៖ *សោម ប៊ុនថន* ***ក្រាហ្វិកកុំព្យូទ័រ*** ៖ *សោម ប៊ុនថន* ***គ្រប់គ្រងការចែកផ្សាយ*** ៖ *ឆេង វើង និង សន ល័ក្ខ* Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ការបញ្ចប់របបប្រល័យពូជសាសន៍ខ្មែរក្រហម : សកម្មភាពយោធាវៀតណាម នៅខែធ្នូ ឆ្នាំ១៩៧៨ និង ខែមករា ឆ្នាំ១៩៧៩

របបប្រល័យពូជសាសន៍នៅកម្ពុជាបានកើតមានឡើងចន្លោះ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និង ថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ ។ នៅចន្លោះអំឡុងពេលនេះ មានមនុស្សចំនួន១.៧ ទៅ ២លាននាក់ បានស្លាប់ដោយសារការអត់ឃ្លាន ពលកម្មដោយបង្ខំ ជំងឺ និងការសម្លាប់ផ្តាច់ពូជ ។ ពេលខ្មែរក្រហមចូលមកគ្រប់គ្រងទីក្រុងភ្នំពេញ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភ្លាមៗនោះ ខ្មែរក្រហមបានជម្លៀសប្រជាជនខ្មែរចេញពីទីក្រុងភ្នំពេញ និងទីក្រុងផ្សេងៗ នៅទូទាំងប្រទេសកម្ពុជាឲ្យទៅធ្វើការនៅតាមទីជនបទ ។ ប្រជាជនកម្ពុជាត្រូវបានបែងចែកទៅជាក្រុមតូចៗ ក្រុមស្ត្រី បុរស យុវជន និងក្មេងៗ ។ ចំណែកអាពាហ៍ពិពាហ៍វិញត្រូវបានខ្មែរក្រហមជាអ្នករៀបចំឲ្យ ។ មិនតែប៉ុណ្ណោះ រូបិយប័ណ្ណ និងភាពទាន់សម័យត្រូវបានលុបបំបាត់ចោលទាំងអស់ ។ រីឯអ្នកមានចំណេះដឹងខ្ពស់ និងអតីតអ្នកគាំទ្ររបបមុនៗ ក៏ត្រូវបានខ្មែរក្រហមសម្លាប់ដែរ ។

កម្ពុជា និងវៀតណាមគឺជាបងប្អូនកុម្មុយនីស្តដែលមានគោលដៅតែមួយ គឺប្រែក្លាយប្រទេសរបស់ខ្លួនទៅជាប្រទេសកុម្មុយនីស្តដែលមានសេចក្តីសុខក្សេមក្សាន្ត ក៏ប៉ុន្តែអ្នកទាំងពីរក៏មានទស្សនៈខុសគ្នាយ៉ាងខ្លាំងដែរថា តើនរណាគួរដឹកនាំរបបកុម្មុយនីស្តនៅតំបន់ឥណ្ឌូចិន ។ ប៉ុល ពត ជឿជាក់ថាប្រទេសកម្ពុជាគួរតែធ្វើជាអ្នកដឹកនាំ ។ ចំណែកប្រទេសចិន និងសហភាពសូវៀតវិញបានប្រយុទ្ធប្រឆាំងគ្នាដណ្តើមការដឹកនាំកុម្មុយនីស្តនិយមនៅលើពិភពលោក ហើយប្រទេសកម្ពុជាបានសម្របខ្លួនជាមួយនឹងប្រទេសចិន រីឯវៀតណាមវិញ គឺនៅខាងសហភាពសូវៀត ។ ការប្រយុទ្ធគ្នានៅតាមព្រំដែនរវាងប្រទេសវៀតណាម និងកម្ពុជាបានផ្ទុះឡើងក្នុងឆ្នាំ១៩៧៦ ហើយបានបន្តដោយឥតឈប់ឈរ រហូតដល់ឆ្នាំ១៩៧៨ ។

នៅចុងខែធ្នូ ឆ្នាំ១៩៧៨ វៀតណាមបានចាប់ផ្តើមធ្វើការលុកលុយមួយដែលមានលក្ខណៈទ្រង់ទ្រាយធំទៅលើរបបកម្ពុជាប្រជាធិបតេយ្យ ។ ការលុកលុយនេះបានដឹកនាំដោយក្រុមអ្នកចម្បាំងកម្ពុជាដែលបានបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានៅគ្រានោះ ។ នៅក្នុងរយៈពេលពីរសប្តាហ៍ប៉ុណ្ណោះវៀតណាមអាចបណ្តេញយោធាខ្មែរក្រហមគ្រប់ច្រកល្ហកទាំងអស់ឲ្យចេញពីព្រំដែនកម្ពុជា-ថៃ ដោយសារតែមានការវាយលុកយ៉ាងឆាប់រហ័ស ខណៈយោធាខ្មែរក្រហមក៏ចាកចេញយ៉ាងឆាប់រហ័សដែរនោះ ទើបបានបន្សល់ទុកនូវភ័ស្តុតាងជាច្រើននៃរបបប្រល័យពូជសាសន៍ និងការសម្លាប់រង្គាលដែលរួមបញ្ចូលទាំងចំនួនឯកសារជាច្រើននៅឯគុកទួលស្លែង ។ បន្ទាប់ពីនោះវៀតណាមបានបង្កើតនិងបានបន្តគាំទ្ររដ្ឋាភិបាលកម្ពុជាថ្មីដែលត្រូវបានហៅថា របបសាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីប្រយុទ្ធប្រឆាំងនឹងរបបខ្មែរក្រហមរហូតដល់ឆ្នាំ១៩៨៩ ទើបវៀតណាមដកកងទ័ពចេញពីប្រទេសកម្ពុជា ។

នៅអំឡុងពេលនោះ ខ្មែរក្រហមត្រូវបានបន្តទទួលស្គាល់ដោយអង្គការសហប្រជាជាតិថា ជារដ្ឋាភិបាលកម្ពុជាដោយស្របច្បាប់ដែលតំណាងឲ្យប្រជាជនកម្ពុជាទាំងមូល ដែលអ្នកទាំងអស់នេះសុទ្ធជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ខ្មែរក្រហម ។

នៅពេលដែលសង្គ្រាមត្រជាក់បានបញ្ចប់សហគមន៍អន្តរជាតិបានចាប់ផ្តើមបង្កើតអាជ្ញាធរបណ្តោះអាសន្នមួយក្នុងគោលបំណងដើម្បីរៀបចំការបោះឆ្នោតតាមបែបលទ្ធិប្រជាធិបតេយ្យជាលើកដំបូងនៅកម្ពុជា ក្នុងឆ្នាំ១៩៩៣ ។

នៅក្នុងឆ្នាំ១៩៩៥ កម្ពុជា និង អង្គការសហប្រជាជាតិបានចាប់ផ្តើមពិភាក្សាគ្នាស្តីអំពីរបៀបនានាដែលសាលាក្តីមួយអាចត្រូវបានគេបង្កើតឡើងដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ នៅក្នុងឆ្នាំ២០០៦ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើង ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានរួមចំណែកជាអ្នក

ឯបត្តម្ភឯកសារផ្សេងៗទៅឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីជួយសម្រួលដល់ការចាប់ផ្តើមប្រតិបត្តិការឲ្យមានភាពឆាប់រហ័ស ។

មជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវបានបង្កើតឡើងក្នុងឆ្នាំ ១៩៩៧ ក្នុងបំណងប្រមូលឯកសារនានាដែលពាក់ព័ន្ធទៅនឹងរបបខ្មែរក្រហម ដោយធ្វើការសម្ភាសជាមួយជនដៃដល់ និងជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាសជាមួយមនុស្សរាប់ពាន់នាក់ អស់រយៈពេល១៩ឆ្នាំមកហើយ ។ អ្វីដែលយើងបានរៀនពីជនរងគ្រោះ និងអ្នករស់រានមានជីវិតនោះគឺ ថាអ្នកទាំងនោះចង់ឲ្យវៀតណាមរំដោះខ្លួនចេញពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម ម្យ៉ាងវិញទៀតជនរងគ្រោះចង់ឲ្យមានគេម្នាក់គ្រាប់បែកនៅកន្លែងគុករបស់ខ្មែរក្រហម និងលេណដ្ឋានពលកម្មដើម្បីឲ្យពួកគាត់រួចខ្លួន ។ ជនរងគ្រោះទាំងនោះមានការដឹងគុណយ៉ាងខ្លាំងដែលកងទ័ពវៀតណាមបានមករំដោះខ្លួនចេញពីការសម្លាប់របស់ខ្មែរក្រហម ដែលរួមបញ្ចូលទាំងញាតិសន្តាន និងមនុស្សជាទីស្រលាញ់របស់ខ្លួនទៀតផង ។

អស់រយៈពេលជាច្រើនឆ្នាំកន្លងមក ក្មេងៗជំនាន់ក្រោយចាប់ផ្តើមចោទសួរសំណួរធំៗ ចំនួនពីរសំណួរគឺ ៖ តើមូលហេតុអ្វីបានជាគ្មាននរណាម្នាក់មកបញ្ឈប់ខ្មែរក្រហមចេញពីការប្រព្រឹត្តអំពើឃោរឃៅយង់ឃ្នងបែបនេះចំពោះប្រជាជនខ្លួនឯង? តើមូលហេតុអ្វីបានជាអង្គការសហប្រជាជាតិទទួលស្គាល់ខ្មែរក្រហមជាអ្នកតំណាង ប្រទេសកម្ពុជាពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ ទៅវិញ និងបានដាក់ទណ្ឌកម្មទៅលើប្រទេសកម្ពុជាទៀត? ខ្ញុំគិតថា គ្មានអ្នកណាម្នាក់អាចឆ្លើយសំណួរនេះបានទេ ។

ខ្ញុំគិតថា វាគឺជាការត្រឹមត្រូវដែលវៀតណាមបានលុកលុយប្រទេសកម្ពុជាហើយបានបណ្តេញខ្មែរក្រហមចេញ ពីព្រោះនៅពេលនោះ មនុស្សជិតពីរលាននាក់បានបាត់បង់ជីវិត និងមនុស្សចន្លោះពី១.៣០០-១.៥០០ បានស្លាប់ជារៀងរាល់ថ្ងៃដោយសារជំងឺ ការសម្លាប់ ពលកម្មដោយបង្ខំ និងការអត់ឃ្លាន ។ ជាការពិតណាស់ក្នុងឆ្នាំ១៩៧៨ មានការកាប់សម្លាប់មនុស្សលើសពីឆ្នាំ១៩៧៥ ទៅ ១៩៧៧ ទៅទៀត ។ ខ្ញុំយល់ឃើញថាករណីនេះ វៀតណាមបានអនុវត្តនូវ “ការទទួលខុសត្រូវដើម្បីការពារ” យ៉ាងជោគជ័យ ដើម្បីសង្គ្រោះប្រជាជនកម្ពុជាចេញពីការសម្លាប់ និងទារុណកម្មបន្ថែមទៀត ។ វាគឺជាករណីចាំបាច់ដែលរដ្ឋមួយត្រូវធ្វើឲ្យបានល្អ ដើម្បីបញ្ឈប់របបប្រល័យពូជសាសន៍ ទោះបីជាវាបានរំលោភច្បាប់អន្តរជាតិ និងគំរាមកំហែងដល់ប្រព័ន្ធរដ្ឋក៏ដោយ ។ ប៉ុន្តែវាមានប្រសិទ្ធភាព ហើយទទួលបាននូវការគាំទ្រយ៉ាងទូលំទូលាយពីជនរងគ្រោះដែលចង់រួចផុតពីរបបប្រល័យពូជសាសន៍ និងគ្មាននរណាម្នាក់អាចធ្វើការសម្រេចចិត្តសម្រាប់



កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាជួយសង្គ្រោះកុមារដែលជាប់ឃុំឃាំងជាមួយឪពុក ត្រូវឆ្មាំគុកខ្មែរក្រហមសម្លាប់មុនពេលរបបរបស់ខ្លួនដួលរលំ ឆ្នាំ១៩៧៩ ។ កុមារឈរាប់ពី

គាត់ក្នុងករណីនេះឡើយ ។ វាជាឆន្ទៈរបស់ជនរងគ្រោះ ដែលចង់ឲ្យគេរំដោះរួចសិន រួចបានគិតអំពីបូរណភាព និងអធិបតេយ្យភាពរដ្ឋកម្ពុជាពេលក្រោយ ។ ជាការពិត សព្វថ្ងៃនេះប្រទេសកម្ពុជា ជារដ្ឋអធិបតេយ្យមួយដូចរដ្ឋដទៃទៀតដែរនៅលើសកលលោកនេះ ។ ចំណុចដែលគួរអោយចាប់អារម្មណ៍មួយទៀត ដែលខ្ញុំចង់ធ្វើការកត់សម្គាល់នោះគឺថា ស្ទើរតែគ្រប់អំពើប្រល័យពូជសាសន៍ទាំងអស់ តែងតែប្រព្រឹត្តដោយរដ្ឋខ្លួនឯងផ្ទាល់ ដោយរដ្ឋាភិបាល និងអាជ្ញាធរដែនដី ។ នៅពេលដែលច្បាប់ **R2P** "ការទទួលខុសត្រូវដើម្បីការពារ" ដាក់ទំនួលខុសត្រូវឲ្យការពារជនរងគ្រោះទៅលើរដ្ឋមួយ ខ្ញុំមិនគិតថា វាជារឿងត្រឹមត្រូវទេ ។ រដ្ឋមួយមិនអាចការពារប្រជាជនខ្លួនបានទេ ពីព្រោះអំពើប្រល័យពូជសាសន៍ ជាជំងឺសកលមួយដែលកើតឡើងដោយសារតែប្រព័ន្ធរដ្ឋ ។ សម្រាប់បញ្ហានេះ ខ្ញុំមិនមានដំណោះស្រាយអ្វីមួយទេ ក៏ប៉ុន្តែវាជាចំណុចមួយដែលត្រូវពិចារណា ដើម្បីបង្កើតយន្តការមួយដើម្បីការពារ បញ្ឈប់ និង ដាក់ទណ្ឌកម្មទៅលើអំពើប្រល័យពូជសាសន៍ ។ ចំណុចចុងក្រោយដែលខ្ញុំចង់លើកឡើងនោះគឺថា ការសម្រេចមួយចេញពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ដើម្បីទប់ស្កាត់នូវអំពើប្រល័យពូជសាសន៍ ឬ បញ្ឈប់វា គឺមានការយឺតយ៉ាវ និងមិនបានបង្កើតនូវការឆ្លើយតបដ៏សមស្របប្រឆាំងទៅនឹងអំពើប្រល័យពូជសាសន៍ទេ ។



ម្តាយ ក្នុងមន្ទីរសន្តិសុខស-២១ ឬ (គុកទួលស្លែង) ។ ឪពុកម្តាយរបស់ក្មេងៗទាំងនេះ
ប្តាំ នង ចាន់ផល និង នង ចាន់នី មានម្តាយឈ្មោះ មុំ យ៉ូវ ។

ប្រជាជនបានបន្តស្លាប់រាប់ពាន់នាក់ នៅពេលដែលក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិពិភាក្សាគ្នាថា តើអំពើប្រល័យពូជសាសន៍កំពុងកើតមាន ឬក៏អត់ ហើយរដ្ឋជាសមាជិកក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិចរចាគ្នាទៅលើផលប្រយោជន៍ផ្សេងៗរបស់ខ្លួន ។ ចំពោះករណីប្រទេសកម្ពុជាវិញនោះ ចំនួនប្រជាជនបានបាត់បង់ជីវិត១.៤០០នាក់ជារៀងរាល់ថ្ងៃ មុនពេលដែលវៀតណាមចូលមកដល់ ។ អង្គការសហប្រជាជាតិបានទទួលស្គាល់ខ្មែរក្រហមជារដ្ឋាភិបាលប្រទេសកម្ពុជាស្របច្បាប់ និងគាំទ្រនូវកិច្ចខិតខំប្រឹងប្រែងការធ្វើសង្គ្រាមរបស់ខ្មែរក្រហមពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ គឺខុសក្រមសីលធម៌ ។

ខ្ញុំបានជួបភ្ញៀវទេសចរណ៍ក្មេងៗជាច្រើន ទាំងជនបរទេស និងជនជាតិកម្ពុជាជារៀងរាល់សប្តាហ៍ នៅឯសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ដែលបានបង្ហាញនូវភាពភ្ញាក់ផ្អើលយ៉ាងខ្លាំង ដែលអង្គការសហប្រជាជាតិបន្តទទួលស្គាល់ខ្មែរក្រហម បន្ទាប់ពីបានឃើញការធ្វើទារុណកម្ម និងឧក្រិដ្ឋកម្មផ្សេងៗ ចំពោះបុរស ស្ត្រី និង ក្មេងៗ នៅឯគុកទួលស្លែង ។ នេះជាបញ្ហាយ៉ាងច្បាស់មួយដែលការអនុវត្តរបស់ **R2P** ជាចាំបាច់ត្រូវតែបញ្ចៀសជាពិសេសការបង្កើតសន្តិភាពក្រោយអំពើប្រល័យពូជសាសន៍ ។

**អេង កុកថាយ**

# ចម្លើយសារភាពរបស់ ណែន ទុយ ហៅ ភី លេខាវរសេនាតូច៥១៣ ភូមិភាគពាយ័ព្យ

ណែន ទុយ ហៅ ភី កើតនៅភូមិខ្ញុំជ្រៃ ឃុំរហាត់ទឹក ស្រុកមង្គលបូរី ខេត្តបាត់ដំបង (បច្ចុប្បន្ន ខេត្តបន្ទាយមានជ័យ) ។ ទុយ ត្រូវបានអង្គការចាប់ខ្លួននៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៧ និងបានបង្ខំឲ្យសរសេរចម្លើយសារភាពដែលមានកម្រាស់២៥ទំព័រ ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី២០ ខែសីហា ឆ្នាំ១៩៧៧ ។ នៅក្នុងចម្លើយសារភាព ទុយ បានឆ្លើយដាក់មនុស្សចំនួន៧៧នាក់ ។

ខាងក្រោមនេះ គឺជាសង្ខេបចម្លើយសារភាពរបស់ ទុយ ដែលរៀបរាប់ពីសកម្មភាពរបស់ខ្លួនចាប់តាំងពីឆ្នាំ១៩៦៨ រហូតដល់ថ្ងៃអង្គការចាប់ខ្លួន ។

នៅអាយុ១២ឆ្នាំ ទុយ បានចូលរៀននៅសាលាក្នុងភូមិបានរយៈពេល៣ឆ្នាំ ។ នៅឆ្នាំ១៩៦២ ទុយ និងម្តាយបានផ្លាស់ទៅរស់នៅជាមួយបងស្រីឈ្មោះ ឡាន នៅភូមិឈើទាល ឃុំវត្តតាមិម ស្រុកសង្កែ តំបន់១ ភូមិភាគពាយ័ព្យ ។ បន្ទាប់ពីរស់នៅជាមួយបងស្រីបានរយៈពេល៥ឆ្នាំ នៅឆ្នាំ១៩៦៧ ទុយ បានទៅស៊ីឈ្នួលបូមទឹកដាក់ចម្ការឲ្យចៅកែ យុន នៅភូមិកង្កួត ឃុំកន្ទឺ ស្រុកបាណន់ តំបន់១ ភូមិភាគពាយ័ព្យ ។

នៅឆ្នាំ១៩៦៨ ទុយ ត្រូវបានប្រធានភូមិឈ្មោះ តិប និងជំទប់ទី១ឈ្មោះ ប៉ុច នៅភូមិកង្កួត ជ្រើសរើសឲ្យចូលបម្រើជាកង



ជនរងគ្រោះនៅមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែង

ជីវពល ដើម្បីការពារកុំឲ្យខ្មែរក្រហមចូលមកទាក់ទងយកស្បៀងពីក្នុងភូមិ ។ រយៈ៧ថ្ងៃក្រោយមក ទុយ និងឈ្មោះ សាញ់ ក៏បានត្រឡប់ទៅធ្វើការនៅចម្ការក្រូចរបស់ថៅ កែ យុន វិញ ។ បន្ទាប់ពីត្រឡប់ទៅនៅចម្ការក្រូចបានមួយរយៈ ទុយ និង សាញ់ ត្រូវបានជំទប់ទី១ ឈ្មោះ ប៉ុច និង សែប សុខ ដែលជាយោធាសាលាស្រុកបាណន់ ណែនាំឲ្យចូលធ្វើការជាគិញយកការណ៍ពីខ្មែរក្រហម ។ ទុយ និង សាញ់ តម្រូវឲ្យទាក់ទងជាមួយខ្សែគិញពីរនាក់គឺឈ្មោះ ម៉ៅ និងថៅកែក្រូចឈ្មោះ យុន ផ្ទាល់ដើម្បីតាមដានរកខ្សែបណ្តាញខ្មែរក្រហមដែលមានមូលដ្ឋាននៅក្នុងព្រៃ និងពង្រីកខ្សែគិញបន្ថែមទៀត ។

រហូតដល់ចុងឆ្នាំ១៩៦៨ ទុយ និង សាញ់ កសាងបានខ្សែគិញថ្មីចំនួន៤នាក់ផ្សេងទៀត រួមមាន ឌុង, ហុក, កំប៉ោង និង សុខ ។ អ្នកទាំងបួនគឺជាអតីតកសិករនៅភូមិកង្កួត ឃុំកន្ទឺ ស្រុកបាណន់ តំបន់១ ។ បន្ទាប់មក ទុយ បាន ស៊ើបដឹងអំពីខ្សែបណ្តាញរបស់ខ្មែរក្រហមនៅក្នុងភូមិឈ្មោះ ធុច និងបានរាយការណ៍ទៅថ្នាក់លើ ។ បីថ្ងៃក្រោយ ធុច ត្រូវបាន ប៉ុច ចាប់យកទៅបាត់ ។



នៅដើមឆ្នាំ១៩៦៩ ចៅហ្វាយស្រុកបាណន់ ឈ្មោះ ស៊ី សៀងហ៊ីវ បានហៅ ទុយ, ប៉ុច, ម៉ៅ, យុន, សាញ់, សែប សុខ មកប្រជុំ និងបានអប់រំអ្នកទាំងអស់នោះឲ្យខិតខំបន្តស៊ើបរកបណ្តាញរបស់ខ្មែរក្រហមដែលជាជនក្បត់ជាតិ និងគ្មានសាសនា ។ ចៅហ្វាយស្រុក ស៊ី សៀងហ៊ីវ ក៏បានណែនាំ ទុយ ឲ្យស្គាល់សមាជិកខ្សែគិញចំនួនបួននាក់ទៀត រួមមាន គន, ខូយ, យ៉ាត, ដេន ។ ទុយ បានផ្អាកពីការងាររបស់ខ្លួន នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ជាថ្ងៃរដ្ឋប្រហារទម្លាក់សម្តេច សីហនុ ។

នៅខែមេសា ឆ្នាំ១៩៧០ ទុយ បានចូលបម្រើបដិវត្តន៍ខ្មែរក្រហមតាមរយៈ ឡឹក សឿន ហៅ ទាត់ ។ លុះដល់ខែតុលា ឆ្នាំ១៩៧០ ទុយ ត្រូវបាន ធន ចាត់តាំងឲ្យធ្វើជាអនុក្រុមកងទ័ព តំបន់១ ភូមិភាគពាយ័ព្យ ។ បន្ទាប់ពីធ្វើការជាមួយ ធន បានមួយខែ ធន បានអប់រំ ទុយ ឲ្យចូលជាសមាជិក សេ.អ៊ី.អា ដោយពន្យល់ថារបបកុម្មុយនីស្តមិនមានសាសនា មិនស្គាល់បុណ្យបាប និងមិនមានយសស័ក្តិទេ ។ បើ ទុយ ចង់រស់នៅក្នុងសង្គមណាដែលសម្បូរសប្បាយ និងមានការប្រណិប័តន៍ខាងសាសនា លុះត្រាតែ ទុយ ចូលជាមួយ សេ.អ៊ី.អា ។ នៅខែវិច្ឆិកា ឆ្នាំ១៩៧០ ធន បានខ្ទេសនាម ទុយ ឲ្យចូលជាសមាជិក សេ.អ៊ី.អា ដែលមាន ហឹង្ស ជាអ្នកទទួលស្គាល់ ។ បន្ទាប់ពីទទួលជាសមាជិក សេ.អ៊ី.អា ទុយ ត្រូវបានណែនាំឲ្យស្គាល់ឈ្មោះ ខៀន និង ណៃ ព្រមទាំងត្រូវបានចាត់តាំងឲ្យកសាងកម្លាំងថ្មីបន្ថែម និងបង្កសកម្មភាព រារាំងកុំឲ្យកម្លាំងបដិវត្តន៍អាចយកជ័យជម្នះបាន ។

នៅដើមឆ្នាំ១៩៧១ ទុយ បានបំផុសបំផុលកងទ័ពខ្មែរក្រហមដែលនៅខ្សែត្រៀមឲ្យរត់ចោលជួរ ដោយបាននិយាយថា កងទ័ពរបស់រដ្ឋាភិបាលមានចំនួនច្រើនវាយសំដៅមកពីបន្ទាយត្រែង និងបន្ទាយគាស់ក្រឡ ។ នៅពេលដែលកងទ័ពខ្សែត្រៀមរត់ចោលជួរ កងទ័ពរដ្ឋាភិបាលបានចូលដល់ភូមិបឹងស្រង៉ែ និងកេណ្ឌបានប្រជាជនចំនួន៥០គ្រួសារ ។ នៅពាក់កណ្តាលឆ្នាំ១៩៧១ ទុយ កសាងបានសមាជិកថ្មីចំនួនពីររូប រួមមាន ភេទ អ្នកបើកបរប្រចាំតំបន់៣ (ភូមិភាគពាយ័ព្យ) , ស៊ីអ៊ីវ កម្មករ (រោងចក្រស្ករសនៅភូមិកំពង់គល់) ។ មកដល់ចុងឆ្នាំ១៩៧១ អង្គការបដិវត្តន៍បានដកកងទ័ពចំនួន៣០នាក់

ពីគ្រប់តំបន់ ដើម្បីរៀបចំកងទ័ពថ្មីនៅតំបន់៥ (ភាគខាងជើងខេត្តបាត់ដំបង) ធ្វើឲ្យ ទុយ ដាច់ការទាក់ទងជាមួយ ណៃ, ខឿន, ភេទ និង ស៊ីអ៊ីវ ។ លុះដល់ឆ្នាំ១៩៧២ ទើប ទុយ បានជួបជាមួយ ធន និងត្រូវបានចាត់តាំងឲ្យធ្វើជាប្រធានក្រុមនៃកងអនុសេនាធំរបស់តំបន់ ហើយ ធន ព្រមទាំងបានណែនាំ ទុយ ឲ្យស្គាល់ ថង ឃឹន អនុរបស់ ធន និង ព្រាំ មកពីវៀតណាម និងជាប្រធានបច្ចេកទេសជួសជុលគ្រឿងម៉ាស៊ីនប្រចាំតំបន់៣ (ភូមិភាគពាយ័ព្យ) ។ ទុយ ត្រូវបានចាត់តាំងឲ្យបំផ្លិចបំផ្លាញឃ្លាំងគ្រាប់ អាវុធ និងស្បៀងរបស់បដិវត្តន៍ ។ នៅពាក់កណ្តាលឆ្នាំ១៩៧២ ទុយ កសាងបានសមាជិកថ្មីចំនួន៣នាក់បន្ថែមរួមមាន ហ៊ឹន (កសិករ) , ឈឿន (ប្រធានកងតូច) , ឈន អនុកងតូចនៃវរសេនាតូច៥១៣ តំបន់៥ (ភូមិភាគពាយ័ព្យ) ។ នៅចុងឆ្នាំ ១៩៧២ ទុយ និង ហ៊ឹន បាននាំគ្នាដុតជង្រុកស្រូវ នៅភូមិស្រែគង អស់ប្រហែល ៤០០ថាំង នៅពេលដែលដាច់ខែ្សត្រៀម ។

នៅដើមឆ្នាំ១៩៧៣ ធន បានណែនាំឲ្យ ទុយ ស្គាល់ខ្សែ សេ.អ៊ី.អា មួយចំនួនផ្សេងទៀត ដូចជា ស្អែម, ឈិន, ឡូយ, យុង, ថង់ឃួន ។ ទុយ និង ហ៊ឹន បានទាក់ទង ថង់ឃួន ឲ្យធ្វើពាណិជ្ជកម្មជាមួយ ស៊ីអឿន ពាក់ស័ក្តិ៥ នៅបន្ទាយជប់ ស្រុកព្រះនេត្រព្រះ តំបន់៥ ភូមិភាគពាយ័ព្យ ។ នៅពេលដែលអង្គការដកកងទ័ពទៅវាយនៅខេត្តសៀមរាប ទុយ, ហ៊ឹន និងថង់ឃួន បានរាយការណ៍ឲ្យ ស៊ីអឿន ចូលមកកេណ្ឌប្រជាជនពីភូមិចំបក់ផ្អែម និងភូមិគោកខ្សាច់បានចំនួន១០០គ្រួសារ ។ ស្របពេលដែលសហរដ្ឋអាមេរិកចាប់ផ្តើមទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជា ទុយ, ហ៊ឹន, ឈន និង ឈឿន បានបំផុសឲ្យកងទ័ពរត់ចោលជួរអស់ចំនួន៦០នាក់ និងកេណ្ឌប្រជាជនចូលតំបន់រដ្ឋាភិបាលគ្រប់គ្រងអស់ចំនួនបីភូមិ ។ រហូតដល់ចុងឆ្នាំ១៩៧៣ ទុយ កសាងកម្លាំងបានចំនួន៦នាក់បន្ថែមទៀត រួមមាន ប៉ិប (ប្រធានកងតូច) , ញ៉ាញ់ (ប្រធានកងតូច) , រ៉ន (ប្រធានកងតូច) , ផុន (ប្រធានកងតូច) , តាំ (ប្រធានកងតូច) , រួមកងវរសេនាតូច៥១៣ (ភូមិភាគពាយ័ព្យ) ។

នៅឆ្នាំ១៩៧៤ ធន បានផ្លាស់ ទុយ ចេញពីកងទ័ពតំបន់ឲ្យធ្វើជាប្រធានអនុសេនាធំ នៅតំបន់ដែលទើបរំដោះបាននៅស្រុកព្រះនេត្រព្រះ ។ ធន បានប្រាប់ ទុយ អំពីស្ថានភាពរបស់កងទ័ពលន់ នល់ ដែលចាញ់កងទ័ពបដិវត្តន៍ស្ទើរគ្រប់ទីកន្លែង និងឲ្យ ទុយ ត្រូវបន្តពង្រឹងកម្លាំង សេ.អ៊ី.អា របស់ខ្លួន និងមិនអនុញ្ញាតឲ្យរាយការណ៍ប្រាប់កម្លាំង សេ.អ៊ី.អាដទៃអំពីស្ថានភាពកងទ័ពលន់ នល់ ទេ ។ នៅស្រុកព្រះនេត្រព្រះ ទុយ បានណែនាំសមាជិកសេ.អ៊ី.អា របស់ខ្លួនឲ្យទប់ទល់បន្តិចបន្តួច ប្រសិនបើកងទ័ព លន់ នល់ វាយចូលមកដើម្បីទុកឱកាសឲ្យកងទ័ព លន់ នល់ យកឈ្នះ ។ ជាលទ្ធផលកងទ័ពខ្មែរក្រហមមិនអាចវាយឈ្នះកងទ័ព លន់ នល់ នៅបន្ទាយថ្មពួក ដោយសារតែមានជំនួយពីកងទ័ពនៅជប់របស់ ស៊ីអឿន បន្ទាប់ពី ទុយ បានប្រាប់អំពីផែនការរបស់ខ្មែរក្រហម ។ មិនតែប៉ុណ្ណោះ កងទ័ព លន់ នល់ រំដោះបានប្រជាជនចំនួន២០០គ្រួសារ និងដណ្តើមបានស្រូវចំនួន១៥ឡាន ។

នៅឆ្នាំ១៩៧៤ ដដែល ទុយ បានកសាងកម្លាំង សេ.អ៊ី.អា ថ្មីចំនួន៥នាក់ រួមមាន សាញ់ ប្រធានអនុសេនាធំ (នៃវរសេនាតូច៥១៣) , ពេក ប្រធានកងតូច (នៃអនុសេនាធំកងកាំភ្លើងធំ) , ចុន ប្រធានកងតូច (នៃវរសេនាតូច៥១៣) , វេត ប្រធានកងតូច (នៃវរសេនាតូច៥១៣ តំបន់៥ ភូមិភាគពាយ័ព្យ) ។

នៅដើមឆ្នាំ១៩៧៥ ធន បានចាត់តាំងទុយ ហោ ភី ជាលេខាវរសេនាតូច, ចយ ជាអនុ និង ទុយ ជាសមាជិកនៃវរសេនាតូច៣១៥ តំបន់៥ ។ នៅខែកុម្ភៈ ឆ្នាំ១៩៧៥ ធន និង ហ៊ីង្ស បានហៅ ទុយ ហោ ភី, ចយ និង ទុយ មកណែនាំប្រាប់អំពីផែនការរបស់ខ្មែរក្រហមដែលនឹងវាយផ្តាច់ទូទាំងប្រទេសនៅខែឧសភា ឆ្នាំ១៩៧៥ បន្ទាប់ពីអ្នកទាំងពីរបានទៅរៀនសូត្រជាមួយអង្គការអស់រយៈពេលកន្លះខែមក ។ ហ៊ីង្ស បានបន្ថែមទៀតថា មធ្យោបាយតែមួយគត់ដែលអាចដណ្តើមជ័យជម្នះពីបដិវត្តន៍ខ្មែរក្រហមបាន គឺមានតែវាយបកបដិវត្តន៍នៅពេលដែលកងទ័ពកំពុងប្របូកប្របល់សប្បាយនឹងជ័យជម្នះ ។ ដូច្នេះការងារសំខាន់នៅចំពោះមុខ គឺកសាងកម្លាំង សេ.អ៊ី.អា បន្ថែមឲ្យបានច្រើន ។ ប៉ុន្តែ ផែនការនោះមិនបានទទួលជោគជ័យទេ ដោយសារតែកងទ័ពខ្មែរក្រហមបានចូលដល់ផ្សារជប់មុន ព្រមទាំងបានចាប់មេទាហាន និងជម្លៀសកូនទាហានចេញទៅអស់ នៅសល់តែអាវុធដែល ទុយ បានដឹកយកទៅទុកសម្រាប់ប្រើប្រាស់នៅថ្ងៃខាងមុខ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៥ អង្គការខ្មែរក្រហមប្រចាំភូមិភាគ បានបញ្ជាឲ្យប្រមូលអាវុធ និងគ្រាប់ពីគ្រប់តំបន់ទាំងអស់

ដោយទុកតែគ្រាប់ចំនួន៧ឡានតែប៉ុណ្ណោះ សម្រាប់ការពារតំបន់ព្រំដែន ។ បន្ទាប់មក ធន បានណែនាំឲ្យ ទុយ ឲ្យទាក់ទងជាមួយ វ៉ាន់ សមាជិកស្រុកសេរីសោភ័ណ, ឆាត អនុលេខាស្រុកថ្មពួក, យុយ សមាជិកស្រុកភ្នំស្រុក ដើម្បីស្រាវជ្រាវរកខ្សែរបស់ ស៊ីអឿន ដែលត្រូវបានខ្មែរក្រហមជម្លៀសចេញបន្ទាប់ពីរំដោះរួច ។ នៅពេលនោះ ទុយ រកឃើញ អេង ទាហានសេរីកាពាក់ស័ក្តិ១, សំអាត គ្រូបង្រៀនស្រុកសេរីសោភ័ណ តំបន់៥ ។ បន្ទាប់មក ទុយ បានចាត់តាំង ស្អែម, អេង និង សំអាត ឲ្យលបបាញ់តាមកន្លែងដែលមានកងទ័ពខ្មែរក្រហមប្រចាំការ ។ ក្រោមការណែនាំរបស់ ទុយ សមាជិកខាងលើបានលបបាញ់កន្លែងដាក់រថក្រោះរបស់កងទ័ពភាគ នៅចម្ការគពីរដង, កន្លែងដាក់កាំភ្លើងបាញ់យន្តហោះនៅស្វាយចេកម្តង និងភ្នំបាក់ម្តង ។ បន្ទាប់មក ហឹង្ស បានផ្លាស់ ទុយ, សាញ់, ព្រមទាំងប្អូនប្រុសរបស់គាត់ (ហឹង្ស) ឈ្មោះ សារី ទៅក្តាប់ផ្នែកសេដ្ឋកិច្ចវិញ ដោយ ហឹង្ស ទទួលដំណឹងថា អង្គការមានគម្រោងចាយក្រដាសប្រាក់ដែលខ្លួនបានបោះពុម្ព ។

នៅខែសីហា ឆ្នាំ១៩៧៥ អង្គការបានហៅ ទុយ ទៅរៀនសូត្រនៅភ្នំពេញចំនួនមួយខែ និងនៅភូមិភាគចំនួនមួយខែ ។ មុនពេលដែល ទុយ ទៅរៀនសូត្រ ទុយ បានចាត់តាំងឲ្យ ស្អែម, សំអាត និង អេង ស្វែងរកកម្លាំងរបស់កងទ័ពសេរីកា ។ អ្នកទាំងបីរកឃើញកងទ័ពសេរីកាចំនួន ២០ នាក់ ប៉ុន្តែសកម្មភាពនោះបានបែកការណ៍ ។ ដូច្នេះ ស្អែម, សំអាត និង អេង ព្រមទាំងកងទ័ពសេរីកាចំនួន១២ នាក់ផ្សេងទៀតក៏បាននាំគ្នារត់ទៅថៃ ។ សមាជិកនៅសេសសល់ចំនួន៨នាក់ត្រូវបានខ្មែរក្រហមបាញ់សម្លាប់ ។

បន្ទាប់ពីទទួលដំណឹងថា អង្គការនឹងមិនចាយក្រដាសប្រាក់នៅចុងឆ្នាំ១៩៧៥ ហឹង្ស បានផ្លាស់ ទុយ ចេញពីសេដ្ឋកិច្ចហិរញ្ញវត្ថុទៅធ្វើជាលេខាវរសេនាតូច៥១៣ ដែលមាន គុណ ជាអនុ និង សារឿន ជាសមាជិក ។ ហឹង្ស បានណែនាំ ទុយ ឲ្យរៀបចំកងទ័ពវរសេនាតូច៥១៣ឡើងវិញ ដោយបញ្ចូលកម្លាំង សេ.អ៊ី.អា ឲ្យក្តាប់កងតូច និងកងអនុសេនាធំ ព្រមទាំងពង្រីកកម្លាំងបន្ថែម ។

នៅដើមឆ្នាំ១៩៧៦ ហឹង្ស បានហៅ ទុយ និង ចយ ប្រធានបច្ចេកទេសជួសជុលគ្រឿងម៉ាស៊ីន (តំបន់៥), ស្រួច ជំនួយការតំបន់៥ និងជាប្រធានផ្នែកកសិកម្ម, ហ៊ិន ជំនួយការតំបន់៥ និងជានារីលើកអាងទឹក, វ៉ាន់ សមាជិកស្រុកសេរីសោភ័ណ, ឆាត អនុលេខាស្រុកថ្មពួក, យុយ សមាជិកស្រុកភ្នំស្រុក មកប្រជុំដើម្បីលើកផែនការវាយបដិវត្តន៍នៅឆ្នាំ១៩៧៦ ។ ដូច្នេះសមាជិក សេ.អ៊ី.អាទាំងអស់ត្រូវខិតខំកសាងសមាជិកបន្ថែម បង្កទំនាស់តាមតំបន់ព្រំដែន និងទាក់ទងរកខ្សែរយៈដែលបានរត់ទៅក្រៅប្រទេស ។ មិនតែប៉ុណ្ណោះ ហឹង្ស បានខទ្មេសនាមសមាជិកប្រជុំឲ្យស្គាល់ ហុង អតីតអ្នកបម្រើសម្តេច សីហនុ និងបច្ចុប្បន្នជាជំនួយការតំបន់និងប្រធានមន្ទីរក្តាប់ខាងសិល្បៈ, លាប់ ប្រធានកសិកម្មតំបន់, គង់ លេខាសង្កាត់ប្រាសាទ ក្តាប់តំបន់, សាវ៉ាត់ ប្រធានពាណិជ្ជកម្មតំបន់៥ ភូមិភាគពាយ័ព្យ ។ បន្ទាប់មក ហឹង្ស បានបញ្ជាឲ្យ ទុយ, ចយ, សុគុណ, ហឹននិងរួមទៅធ្វើការទំនាក់ទំនងនៅឡាក់៤៣ តំបន់ព្រំដែនថៃ ដើម្បីស្វែងរកកងទ័ពសេរីកា ដែលបានរត់ភៀសខ្លួន ។ នៅទីនោះ ទុយ បានជួប ដាំ រួចបាននាំ ទុយ ឲ្យជួបជាមួយ ដុំណាល់ សេរីកាស័ក្តិ៣, អេង ស័ក្តិ១, សំអាត ដែលបានរត់ចេញពីប្រទេសកម្ពុជា កាលពីចុងឆ្នាំ១៩៧៥ ។ កន្លះខែក្រោយ ទុយ បានជួបជាមួយ អេង កងទ័ពរបស់ អ៊ុន តាំ ពាក់ស័ក្តិ១ ដែលបានណែនាំ ទុយ ឲ្យស្គាល់ ដនកងទ័ពរបស់ អ៊ុន តាំ ពាក់ស័ក្តិ១, ឌី គយនៅស្រុកសេរីសោភ័ណមុនរំដោះ ដែលត្រូវជាប្អូនរបស់ ដន ។ ទុយ បានរាយការណ៍ទៅអេង នៅឡាក់៤២ជាប់ព្រំដែនថៃ អំពីសមាជិកចំនួន៤០ នាក់ដែល ដន និង ឌី បានអប់រំដើម្បីរៀបចំកងទ័ពសេរីកា ។

នៅខែមិថុនា ឆ្នាំ១៩៧៦ ទុយ, ហឹន, រួម, សុគុណ និង ចយ បានទៅជួប អេង ស័ក្តិ១, ដុំណាល់ ស័ក្តិ៣, ដាំ នៅឡាក់៤៧ជាប់ព្រំដែនថៃ ដើម្បីពិភាក្សាអំពីកម្លាំងកងទ័ពបដិវត្តន៍នៅតាមព្រំដែន និងតំបន់ខាងក្នុង ព្រមទាំងបានលើកផែនការវាយបក្សនៅចុងឆ្នាំ១៩៧៦ នារដូវប្រមូលផលកាត់ ។ បន្ទាប់ពីប្រជុំ ដុំណាល់ និង អេង បានណែនាំ ទុយ និងសមាជិកដទៃទៀតឲ្យបំផ្ទុះគ្រាប់មីន និងដុតចម្រូងដែលបក្សបានដាំនៅតាមបណ្តោយព្រំដែនដើម្បីងាយស្រួលក្នុងការដឹកនាំកងទ័ពចូលមកវាយបក្ស ។ នៅពេលនោះដែរ ទុយ បានទទួលមនុស្សចំនួន៧០ នាក់ ដែលជាប់និន្នាការនយោបាយ និងជាសាច់ញាតិបងប្អូនរបស់សមាជិក សេ.អ៊ី.អា ។ បន្ទាប់មក ទុយ បានប្រគល់មនុស្សចំនួន ៣០ នាក់ ទៅឲ្យ ហឹង្ស និងបានបញ្ជូនបន្តទៅឲ្យ ង៉ុយ និង ឆាត ។ មនុស្សទាំង៣០ នាក់នោះ គឺជាប្រជាជនដែល

ខ្មែរក្រហមជម្លៀសចេញពីទីក្រុងភ្នំពេញ ភាគច្រើនជាប់និន្នាការដែលខ្មែរក្រហមត្រូវបោសសម្អាត ។ នៅចុងឆ្នាំ១៩៧៦ ទុយ កសាងបានកម្លាំង សេ.អ៊ី.អា ៤នាក់បន្ថែម រួមមាន ខាន់ ប្រធានក្រុមវរសេនាតូច៥១៣, កាន់ ប្រធានក្រុមសេដ្ឋកិច្ច វរសេនាតូច៥១៣, សី ប្រធានក្រុម កងធំទី២ វរសេនាតូច៥១៣, តី ប្រធានក្រុម វរសេនាតូច៥១៣ តំបន់៥ ភូមិភាគពាយ័ព្យ ។ ទុយ បានណែនាំអ្នកទាំងបួនដោយនិយាយថា របបកុម្មុយនីស្តតឹងតែងណាស់ យុវជនយុវនារីស្រឡាញ់គ្នាមិនបានទេ បើអង្គការដឹងនឹងត្រូវយកទៅវាយចោល បើទោះបីជាធ្លាប់បានតស៊ូយូរយ៉ាងណាក៏អង្គការមិនអនុគ្រោះឡើយ មិនតែប៉ុណ្ណោះ ការរស់នៅសព្វថ្ងៃបីដូចជាជាប់គុក ។ ជាសរុបផែនការវាយប្រហារបដិវត្តន៍នៅចុងឆ្នាំ១៩៧៦ មិនទទួលបានជោគជ័យទេដោយសារតែកងទ័ពមកពីខាងក្រៅត្រូវបានកងទ័ពរណសិរ្សថៃរារាំង និងមិនអាចក្តាប់សភាពការណ៍នៅតំបន់ខាងក្នុងបាន ។

នៅខែមករា ឆ្នាំ១៩៧៧ ទុយ, សុគុណ, សារឿន, ហ៊ីង្ស, ដុំណាល់ និង អេង បានប្រជុំគ្នាសាជាថ្មីនៅឡាក់៤៧ ដើម្បីរៀបចំផែនការវាយប្រហារបក្សនៅឆ្នាំ១៩៧៧ ម្តងទៀត ។ ហ៊ីង្ស បានណែនាំ ទុយ ឲ្យបន្តបង្កប់ខ្លួននៅក្នុងជួរបដិវត្តន៍ និងខិតខំពង្រីកកម្លាំងបន្ថែម ដើម្បីកសាងកម្លាំងថ្មីឲ្យក្តាប់តាមសហករណ៍ និងអូសទាញប្រជាជនដែលជម្លៀសមកពីភ្នំពេញឲ្យចូលរួមសកម្មភាពជាមួយផែនការវាយប្រហារបដិវត្តន៍នៅខែកញ្ញា ឆ្នាំ១៩៧៧ ក្រោមការដឹកនាំរបស់ អ៊ិន តាំ ។ មិនតែប៉ុណ្ណោះ ហ៊ីង្ស បានប្រាប់ ទុយ ឲ្យរាយការណ៍អំពីសកម្មភាពរបស់ខ្លួនទៅឲ្យសមាជិក សេ.អ៊ី.អា ដទៃនៅពេលដែល ហ៊ីង្ស មិននៅ រួមមាន សាន្ត សេនាធិការយោធាភូមិភាគពាយ័ព្យ, ស៊ូ គណៈទំនាក់ទំនងព្រំដែនខ្មែរ-ថៃ, ម៉ៃ គណៈទំនាក់ទំនងនៅជាមួយ ស៊ូ, នួវ គណៈកងពល ភូមិភាគពាយ័ព្យ, ឈិន ជាងសំណង់អាងទឹក តំបន់៥ , សុវ៉ាន់ ជាងសំណង់អាងទឹកតំបន់៥ , ភឿន ប្រធានស្ថិតិតំបន់៥ , ឃាម អនុប្រធានពាណិជ្ជកម្ម តំបន់៥ , ឈុយ ប្រធានអនុសេនាធំទី៧ វរសេនាតូច៥១៣, ធន់ នារីជំនួយការពេទ្យតំបន់៥ , ប្រាក់ ប្រធាននារីពាណិជ្ជកម្ម តំបន់៥ ភូមិភាគពាយ័ព្យ ។ បន្ទាប់មក ទុយ , ម៉ៃ និង ស៊ូ បានពង្រឹងបណ្តាញតាមបណ្តោយ ផ្លូវជាតិលេខ៦ ពីសេរីសោភ័ណទៅកាន់ប៉ោយប៉ែត និងទាក់ទងបាន ឈឿន ពាណិជ្ជកម្មដ្ឋ ប្រចាំការនៅអូរជ្រៅ ដើម្បីនាំកងទ័ព អ៊ិន តាំ មកតាមផ្លូវជាតិលេខ៦ វាយបដិវត្តន៍នៅខែកញ្ញា ឆ្នាំ១៩៧៧ ។ ជាងនេះទៅទៀត ទុយ និង គង់ បានបន្តពង្រីកកម្លាំងនៅក្នុងចំណោមយុវកក (យុវជនកុម្មុយនីស្តកម្ពុជា) និងបានដកទ័ពទៅក្តាប់សហករណ៍នៅសង្កាត់ប្រសាទ ជាទីកន្លែងដែលប្រជាជនភាគច្រើនត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញ ។ នៅទីនោះ ទុយ បានខទ្វេសនាម ឈឿន ប្រធានកងតូច វរសេនាតូច៥១៣, ប៉ិប ប្រធានកងតូច វរសេនាតូច៥១៣, ឈន ប្រធានកងតូច វរសេនាតូច៥១៣ តំបន់៥ ភូមិភាគពាយ័ព្យ ទៅឲ្យ ហ៊ីង្ស ។ បន្ទាប់មក ហ៊ីង្ស បានណែនាំ ទុយ ឲ្យជ្រើសរើសសមាជិក សេ.អ៊ី.អា ៣នាក់ផ្សេងទៀត ទៅបំផ្លាញអាងទឹកត្រពាំងថ្ម នៅក្នុងស្រុកភ្នំស្រុក តំបន់៥ ដែលមានប្រវែង ១៥គីឡូម៉ែត្រ ដោយធ្វើការទំនាក់ទំនងជាមួយ ឈិន និង សុវ៉ាន់ ដែលជាជាងសំណង់អាងទឹក ។ មិនតែប៉ុណ្ណោះ ហ៊ីង្ស បានណែនាំ ទុយ ហៅ គី ឲ្យទាក់ទងជាមួយ ទុយ លេខាវរសេនាតូច៤២៥ ប្រចាំព្រំដែនថៃនៅស្រុកថ្មពួក ដើម្បីរៀបចំខ្សែទាក់ទងតាមព្រំដែននៅឡាក់៤២ និងឡាក់៣០ ក្នុងគោលបំណងបើកផ្លូវឲ្យកងទ័ពរបស់ អ៊ិន តាំ ចូលវាយប្រហារតំបន់ខាងក្នុង ។ បន្ទាប់មក ហ៊ីង្ស បានហៅ ទុយ ហៅ គី សុគុណ, សារឿន, និង ទុយ លេខាវរសេនាតូច៤២៥ , ស៊ូ, ម៉ៃ, សាន និង នួវ ជួបនៅភូមិនិមិត្ត ស្រុកអូរជ្រៅ តំបន់៣ ភូមិភាគពាយ័ព្យ ដើម្បីពិភាក្សាអំពីការវិវឌ្ឍនៃផែនការវាយប្រហារបដិវត្តន៍នៅខែកញ្ញា ឆ្នាំ១៩៧៧ ។ ហ៊ីង្ស បានចាត់តាំងឲ្យ ទុយ ហៅ គី ទទួលពីឡាក់៤៧ ទៅ ៤២, ទុយ លេខាវរសេនាតូច៤២៥ ទទួលពីឡាក់ ៣០ ទៅ២៨ ។ ចំណែកឯ ហ៊ីង្ស, សាន្ត និង នួវ ចាំទទួលកងទ័ពចូលតាមផ្លូវជាតិលេខ៦ ។

បន្ទាប់មក ទុយ បានចាប់ផ្តើមសកម្មភាពតាមព្រំដែន ដូចជាដេញគោក្របីចូលទឹកដីថៃ ដែលធ្វើឲ្យថៃយល់ច្រឡំថាខ្មែរចូលមកឈ្លានពាន និងបានយកកាំភ្លើងមកដេញបាញ់ ។ ក្រោយមក ហ៊ីង្ស បានចាត់តាំង ទុយ និងសាញ់ ឲ្យដឹកអាវុធពីឃ្លាំងដែលបានលាក់ទុកជាង១០០០ដើម ទៅដាក់នៅកន្លែងរបស់គាត់ និងបានកោះហៅកម្លាំងដែលកសាងបានមកជួប ដោយយកលេសថា មកចូលរួមសន្និបាតតំបន់ ។ នៅពេលដែល ទុយ កំពុងដឹកអាវុធ នៅខែឧសភា ឆ្នាំ១៩៧៧ ក៏ត្រូវអង្គការឃាត់ខ្លួនតែម្តង ។ **ម៉ែន ពិចិត្រ**

# យុវនារីថន ធ្វើពលិកម្មគ្រប់បែបយ៉ាងដោយឥតលក្ខខណ្ឌ ដើម្បីបដិវត្តន៍ និងប្រជាជន

កាលពីដើមខែមីនា ឆ្នាំ១៩៧៦នេះ អង្គការប្រគល់ភារៈឲ្យខ្ញុំដឹកជញ្ជូនអំបិល និងក្រណាត់ យកទៅចែកជូនប្រជាជនសហករណ៍ក្នុងខេត្តកំពង់ស្ពឺ ។

ខេត្តកំពង់ស្ពឺ ជាខេត្តមួយដែលល្បីល្បាញខាងក្រខ្សត់តាំងពីដើមរៀងមក ។ ដីក្នុងខេត្តកំពង់ស្ពឺ ជាទូទៅជាដីសោះកក្រោះគ្មានដីជាតិទេ ហើយភាគច្រើនជាដីខ្សាច់ក្រហម ។ ជារៀងរាល់ឆ្នាំ នៅក្នុងខេត្តកំពង់ស្ពឺ មិនសូវមានភ្លៀងធ្លាក់គ្រប់គ្រាន់ ដូចខេត្តដទៃៗទៀតទេ ។ រីឯប្រភពទឹក ជាទន្លេ ស្ទឹង បឹងបួរ អូរជ្រលង ក៏មិនសូវសម្បូរដែរ ។ ផលស្រូវជារៀងរាល់ឆ្នាំនៅក្នុងខេត្តកំពង់ស្ពឺ បានតិចតួចស្តួចស្តើងណាស់ គឺដីក្នុងមួយហិកតា បានផលមិនដល់មួយតោនផង ។ នៅរដូវប្រាំង ទឹករីងហួតហែងអស់ ។ ដីឡើងស្ងួតបែកក្រហែងនៅគ្រប់ទិសទី ។ មនុស្សសត្វផងនានា ពិបាកនឹងរកទឹកប្រើប្រាស់ណាស់ កុំថាឡើយដល់ទៅមានទឹកងូត ។ ដូច្នេះជីវភាពប្រជាជនក្នុងខេត្តកំពង់ស្ពឺ មានការលំបាកក្រខ្សត់អត់ឃ្លាន ខ្វះមុខខ្វះក្រោយជាប្រចាំ ។ នេះជាប្រវត្តិចាស់របស់តំបន់កំពង់ស្ពឺដែលឈឺចាប់ខ្លោចផ្សាធ្វើឲ្យប្រជាកសិករយើង ត្រូវរត់ចោលស្រុកចោលស្រែ ចោលភូមិកររបស់ខ្លួនជារៀងរាល់ឆ្នាំ ដើម្បីស្វែងរកទីកន្លែងរស់នៅថ្មី ដែលអាចបង្កបង្កើនផលរកស៊ីចិញ្ចឹមជីវិតបានធូរគ្រាន់បើជាងនេះ ។

ពេលដែលខ្ញុំបើកឡានទៅដល់តំបន់កំពង់ស្ពឺភ្លាម ទិដ្ឋភាពថ្មីៗប្លែកៗជាច្រើន បានទាញអារម្មណ៍ខ្ញុំ ធ្វើឲ្យខ្ញុំរំភើបរីករាយផង ហើយមានការគោរពកោតសរសើរដល់ស្មារតីប្រយុទ្ធយ៉ាងមានៈព្យាយាមស៊ិតស៊ាញរបស់បងប្អូនកសិករសហករណ៍យើងក្នុងខេត្ត



កសិករនៅសហករណ៍ ស្រុកកោះធំ ប្រមូលផលពោត

កំពង់ស្ពឺ ក្រោមការដឹកនាំដ៏ត្រឹមត្រូវ និងឈ្លាសវៃនៃបក្សកុម្មុយនីស្តកម្ពុជាដ៏រុងរឿងផង ។ នៅតាមគ្រប់ភូមិសហករណ៍យើងឃើញមានដំណាំដាំដុះផ្សេងៗដូចជា ចេក ដូង ដំឡូង អំពៅ និងបន្លែបង្ការជាច្រើនមុខទៀត ខំប្រយុទ្ធនឹងធម្មជាតិដ៏កំណាចដុះលូតលាស់បម្រើសេចក្តីត្រូវការរបស់ប្រជាជនសហករណ៍យើង ។ ក្រៅពីនេះ នៅតាមចំការនានា យើងឃើញមាន មន ត្រុំ កប្បាស ខំប្រណាំងប្រជែងគ្នា ដុះលូតលាស់ខៀវស្រងាត់ដែរ ។ ពិតមែនតែទិដ្ឋភាពទាំងនេះ មិនសូវត្រគុំត្រកាល ដូចទិដ្ឋភាពនៅតាមដួរមាត់ទន្លេទេ តែវាក៏ជាទិដ្ឋភាពថ្មីសន្ធាងស្រស់បំព្រង និងត្រកាលប្លែកនៃតំបន់កំពង់ស្ពឺ ដែលពីដើមធ្លាប់តែក្រៀមក្រោះ ស្ងួតបែកក្រហែងនោះដែរ ។ នៅតាមទីវាលដ៏ធំល្វឹងល្វើយ យើងឃើញប្រជាកសិករយើងទាំងស្រី ទាំងប្រុស ទាំងចាស់ ទាំងក្មេង ច្រើនមីរដេរដាស គ្រប់ទីកន្លែងកំពុងវាយសម្រុកប្រយុទ្ធលើកប្រព័ន្ធភ្លឺថ្មី និងជីកប្រឡាយថ្មី ដើម្បីម្ចាស់ការលើបញ្ហាទឹក ឲ្យបានជាអតិបរមាសម្រាប់វាយសម្រុកបង្កបង្កើនផល នៅរដូវវស្សាខាងមុខនេះ សម្រេចទិសដៅបីតោនមួយហិកតា ដូចជាតំបន់នានាដែរ ។ បងប្អូនកសិករសហករណ៍យើងនៅខេត្តកំពង់ស្ពឺ ប្តេជ្ញាកសាង និងកែប្រែជនបទកំពង់ស្ពឺដ៏ក្រៀមក្រោះ ស្ងួតបែកក្រហែងនេះ ឲ្យទៅជាជនបទថ្មី ដែលប្រកបដោយភ្លឺ និងប្រឡាយខ្វាត់ខ្វែង មានទឹកដក់ និងហូរខួបប្រាំង ខួបវស្សា ព្រមទាំងមានដំណាំដាំដុះខៀវស្រស់បំព្រងខួបប្រាំងខួបវស្សានៅគ្រប់ច្រកល្ហកទាំងអស់ ។

ក្រោយពេលដែលប្រគល់សម្ភារទាំងអស់ជូនអង្គការប្រចាំខេត្តកំពង់ស្ពឺហើយ ខ្ញុំត្រូវនៅរង់ចាំកន្លះថ្ងៃទៀត ដើម្បីធ្វើដំណើរវិលត្រឡប់មកកាន់ក្រុងភ្នំពេញវិញ ។ ឆ្លៀតពេលទំនេរមួយរសៀលនេះ យើងខ្ញុំក៏បាននាំគ្នាទៅការដ្ឋានជិតៗនោះ ចូលរួមលើកភ្លឺ និងជីកប្រឡាយថ្មីជាមួយបងប្អូនកសិករសហករណ៍យើង ។ ដោយនៅរដូវនេះ ធាតុអាកាសក្តៅខ្លាំង បងប្អូនសហករណ៍យើងនាំគ្នាសម្រេចអនុវត្តម៉ោងពេលធ្វើការនៅលើការដ្ឋាន ចាប់ពីម៉ោង៣រសៀល ទៅទល់នឹងម៉ោង៦ល្ងាច ។ គ្រាន់តែម៉ោងជិតបី បងប្អូនកសិករសហករណ៍យើងនៅគ្រប់ការដ្ឋានទាំងអស់ នាំគ្នាលីចប វែកបង្គី ចុះស្រ មូលមីរ ឆ្ពោះតម្រង់ទៅកាន់មុខសញ្ញារៀងៗខ្លួន ។ យើងខ្ញុំក៏ប្រញាប់ប្រញាល់ ស្រូតរូតទៅឲ្យដល់ការដ្ឋានទាន់បងប្អូនដែរ ។ ពេលយើងខ្ញុំដើរទៅជិតដល់ការដ្ឋានប្រជាជនសហករណ៍យើងភាគច្រើនមិនទាន់មកដល់ការដ្ឋាននៅឡើយទេ តែយើងខ្ញុំឃើញមនុស្សប្រមាណ៤-១០-២០នាក់កំពុងសកម្មមមាញឹកទាញខ្សែតម្រង់បោះបង្គោលដៅមុខសញ្ញានីមួយៗ ឲ្យបានច្បាស់លាស់ ។ ក្នុងចំណោមនោះ យើងខ្ញុំឃើញមិត្តនារីម្នាក់រាងតូចស្តើងសម្បុរខ្មៅ ដូចជាបងប្អូននារីកសិករយើងទូទៅដែរ កំពុងសកម្មមមាញឹក ញាប់ទាំងដៃ ញាប់ទាំងជើង ញាប់ទាំងមាត់ រួមការងាររវាស់វែងតម្រង់ខ្សែ និងបោះបង្គោលជាសញ្ញាដៅទិសដែលភ្លឺ និងប្រឡាយថ្មីត្រូវលូតតទៅមុខទៀត ។ ពេលខ្ញុំក្រឡេកឃើញដំណើរនិងកាយវិការរបស់មិត្តនារីនេះ អារម្មណ៍ខ្ញុំហាក់ដូចជានឹកឃើញរឿងអ្វីមួយពីអតីតកាល ដែលខ្លួនខ្ញុំខំរកនឹកពុំឃើញដែរ ។ ពេលនោះប្រជាជនស្រី-ប្រុស ចាស់ ក្មេង ជជែកគ្នាសើចលេងក្អាកក្អាយខៀវខ្វារ បណ្តើរគ្នាជាក្រុមៗមកដល់ការដ្ឋាននេះដែរ ។ យើងខ្ញុំដោយគ្មានគិតគូរពីរឿងរ៉ាវ ឬព្រឹត្តិការណ៍អ្វីទាំងអស់ក៏បានចុះប្រឡូកជួយកាប់ដីបងប្អូនយើងយ៉ាងពេញទំហឹងភ្លាមដែរ ។ មិត្តនារី និងយុវនារី ដែលជាអ្នកកើប និងជញ្ជូនអាចម៍ដីយកទៅចាក់លើកភ្លឺថ្មីធ្វើការសកម្មប្រយុទ្ធក្នុងបរិយាកាសសប្បាយរីករាយ និងប្រឡងប្រណាំងគ្នាយ៉ាងផុសផុលក្លៀវក្លា ។ យើងមើលទៅភ្លឺឃើញហាក់ដូចជាឆ្ងាយដែរ តែមិត្តនារីរែកជញ្ជូនដីដើរទៅមក ដូចជាឆាប់រហ័សពេក លឿនពេក ធ្វើឲ្យពួកយើងខ្ញុំប្រឹងកាប់ដីឡើងញើសហូរសស្រាក់ ស្រោចស្រពជោគជាំខោអាវអស់ហើយ ក៏នៅតែសឹងមិនទាន់ទៀត ។ ខ្ញុំនឹកគិតក្នុងចិត្តថា បងប្អូននារីយើងឥឡូវពូកែធ្វើការមិនចាញ់បុរសឡើយ ។ ហើយចំពោះខ្លួនខ្ញុំដែលរវល់តែកាច់ចង្កូតឡាន និងលើកដាក់ លីសែង ធូនៗម្តងៗ ពុំសូវបានហ៊ឹកហ៊ឺនក្នុងការងារពលកម្មធ្ងន់ជាប់យ៉ាងនេះ ប្រាកដជាពុំអាចប្រឡងប្រណាំងជាមួយបងប្អូននារីយើងបានឡើយ ។ ខ្ញុំនឹកដល់ត្រឹមនេះហាក់ ដូចជាអៀនខ្លួន ហើយប្តេជ្ញាខំកាប់ដីឲ្យបានលឿនបំផុត ដើម្បីឲ្យទាន់មិត្តនារីដែលរែកជញ្ជូន ។

ខ្ញុំកំពុងតែប្រឹងកាប់អស់ពីសរសៃសរសូងក្នុងខ្លួន ។ ញើសហូរសស្រាក់ជោគខោអាវ ហើយហូរស្រក់តក់ៗ តាមចុងច្រមុះ និងចង្កា តែក្នុងចិត្តខ្ញុំរំភើបរីករាយក្រៃលែង ភ្លេចនឹកគិតអស់ដល់ការនឿយហត់ ព្រោះអារម្មណ៍ខ្ញុំវាដក់ទៅក្នុងការប្រឡងប្រណាំងធ្វើ

ការងារពលកម្ម លើកប្រព័ន្ធភ្លឺថ្មី ជីកប្រឡាយថ្មីនេះ ជាមួយបងប្អូនកសិករយើង ។ ស្រាប់តែមានមិត្តនារីម្នាក់ ទម្លាក់អម្រែកពីស្មានៅក្បែរខ្លួនខ្ញុំ ហុចដៃមកចាប់ដៃខ្ញុំដោយបន្ទីវាចាយ៉ាងរំភើបរីករាយឥតឧបមាថា៖ «យី! មិត្តជិនទេ តើ! មិត្តសុខសប្បាយជាទេ? មិត្តនៅធ្វើការឯណាសព្វថ្ងៃ? ហើយមិត្តអញ្ជើញមកដល់កំពង់ស្ពឺនេះពីកាលណា?»

ពាក្យសម្តីទាំងនេះ ធ្វើឲ្យខ្ញុំស្រឡាំងកាំង បញ្ឈរដងចបឈប់កាប់ដី ហើយងាកមករកម្ចាស់សំឡេងនេះភ្លាមដោយក្តីងឿងឆ្ងល់ ។ មិត្តនារីចាប់លោក់ដៃខ្ញុំយ៉ាងណែន ហើយសើចញញឹមស្រស់ស្រាយមកកាន់ខ្ញុំ ។ ពេលនោះទើបខ្ញុំស្គាល់ថាជាមិត្តនារីថន ។ មិត្តនារីថន និងខ្ញុំបែកគ្នារហូតតាំងពីកណ្តាលឆ្នាំ១៩៧១មកម្ល៉េះ ហើយពុំដែលបានទទួលដំណឹងអំពីគ្នាម្តងណាឡើយ ។ ទើបតែថ្ងៃនេះ យើងបានមកជួបមុខគ្នាដោយចៃដន្យ ។ យើងខ្ញុំសប្បាយរីករាយឥតឧបមា ហើយរំជួលចិត្តក្រៃលែង ។ ហាក់បីដូចជាបងប្អូនបង្កើតចេញពីផ្ទៃម្តាយតែមួយ ហើយព្រាត់ប្រាសគ្នាយូរហើយ ទើបតែបានជួបមុខគ្នាជាថ្មីឡើងវិញ ។ ខ្ញុំសង្កេតឃើញមិត្តនារី ថន មានការប្រែប្រួលច្រើន ។ ម្យ៉ាងខាងរូបរាងកាយមិត្តខ្មៅហើយមាំជាងមុនឆ្ងាយ ។ ខាងអត្តចរិត អាកប្បកិរិយា និងគោលជំហរ មិត្តនឹងន ចាស់ទុំ តែចេះរាក់ទាក់ ស្រស់ស្រាយ រាបសារ ទន់ភ្លន់ជាមួយប្រជាជន-មហាជនស្មើទូទៅទាំងអស់ ។ ក្នុងការងារ មិត្តសកម្មប្រយុទ្ធ ឈ្លាសវៃ ប៉ិនប្រសប់ ហើយម៉ឺងម៉ាត់ ហ្មត់ចត់បំផុត ។ ខ្ញុំនឹកកោតសរសើរ និងគោរពមិត្តនៅក្នុងចិត្ត ហើយប្តេជ្ញារៀនសូត្រអំពីមិត្តជានិច្ច ។ យើងខ្ញុំសាកសួរសុខទុក្ខគ្នា សាកសួរអំពីបទពិសោធការងារបដិវត្តន៍ និងរៀនសូត្រពីគ្នាទៅវិញទៅមក យ៉ាងរាក់ទាក់ស្រស់ស្រាយ ។ ពេលនោះ ខ្ញុំនឹកឃើញរឿងដើមទាំងអស់មកវិញ៖

«យុវនារីថន ជាកូនកសិករកណ្តាលថ្នាក់ក្រោម នៅស្រុកមុខកំពូល ខេត្តកណ្តាល ។ ពេលរៀនចប់នៅសាលាបឋមសិក្សាឪពុកមាមិត្តដែលធ្វើគ្រូបង្រៀននៅក្រុងភ្នំពេញ បានយកមិត្តមករៀនសូត្រ បន្តវិជ្ជានៅសាលាមធ្យមសិក្សាក្រុងភ្នំពេញទៀត ។ ពេលមកនៅរៀនក្រុងភ្នំពេញ មិត្តថន មានការប្រាស្រ័យទាក់ទងជាមួយយុវជន-យុវនារីចម្រើនជាច្រើន ហើយតាមរយៈមិត្តភក្តិទាំងនេះ មិត្តក៏មានការយល់ដឹងអំពីបដិវត្តន៍ជាបន្តបន្ទាប់ ។ ឆ្នាំ១៩៧១ ចក្រពត្តិអាមេរិកបានបញ្ជាឲ្យពួកអាក្សត់ លន់ នល់ ធ្វើរដ្ឋប្រហាររំលំឯករាជ្យ សន្តិភាព អព្យាក្រឹត នៃប្រទេសកម្ពុជា ប៉ុនប៉ងយកប្រទេសកម្ពុជា ធ្វើជាអាណានិគមបែបថ្មីរបស់វា និងធ្វើជាមូលដ្ឋានយោធាសម្រាប់ឈ្លានពានអាស៊ីអាគ្នេយ៍ ។ ពេលនោះ



ទំនប់ទឹកដែលសង់ឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នៅស្រុកទូកមាស ខេត្តកំពត សម្រាប់ស្រោចស្រពស្រូវរដូវប្រាំង

បក្សកុម្មុយនីស្តកម្ពុជាដ៏រុងរឿង និងត្រឹមត្រូវ ក៏បានបំផុសប្រជាជន យុវជន-យុវនារីកម្ពុជា នៅទូទាំងប្រទេស ទាំងនៅជនបទ ទាំងនៅទីក្រុងក្រោកឡើងធ្វើការតស៊ូវាយប្រហារពួកអាក្សត់ប្រឆាំងជំទាស់ពួកអាក្សត់ធ្វើរដ្ឋប្រហារ តាមគ្រប់រូបភាពជាសង្គ្រាម ប្រជាជនផងជាបាតុកម្មមីទិញផង និងជាកុប្បកម្មវាយកម្ទេចរដ្ឋអំណាចក្បត់របស់ខ្មាំងដណ្តើមរដ្ឋអំណាចពីដៃខ្មាំងផង ។ ពេលនោះយុវនារី ថន ដោយបានអង្គការបក្សសម្ងាត់នៅក្នុងក្រុងភ្នំពេញ ជួយអប់រំបំពាក់បំប៉ន ទាំងខាងនយោបាយសតិអារម្មណ៍ និងចាត់តាំងបដិវត្តន៍ជាបន្តបន្ទាប់ជាប់ជានិច្ច ក៏មានការភ្ញាក់រឭកបដិវត្តន៍កាន់តែខ្ពស់ឡើងមានកំហឹងជាតិ និងកំហឹងវណ្ណៈពុះកញ្ជ្រោលឡើងជាលំដាប់ ។ មិត្តបានប្តេជ្ញាបូជាកម្លាំងកាយចិត្ត បូជាយុវវ័យ និងបូជាអាយុជីវិតរបស់មិត្តជូនបក្ស ដើម្បីបុព្វហេតុបដិវត្តន៍ ប្រជាជន និងបុព្វហេតុរំដោះវណ្ណៈក្រីក្រ ។ មិត្តបានចូលរួមប្រឡូកយ៉ាងសកម្មក្នុងគ្រប់ចលនាតស៊ូសម្ងាត់-ចំហ ប្រឆាំងចក្រពត្តិអាមេរិក និងពួកអាក្សត់ជាតិ លន់ នល់ សិរិមតៈ សឺង ង៉ុកថាញ់ នៅកណ្តាលទីក្រុងភ្នំពេញតែម្តង ។ ក្រោយពេលរដ្ឋប្រហារបានបន្តិច បក្សបានស្នើឲ្យមិត្តលះបង់ការសិក្សា ហើយរៀបចំគ្រួសារជាមួយមិត្តយើងម្នាក់ឈ្មោះ ញ៉ែម ហើយឲ្យវិលត្រឡប់ទៅប្រកបរបររកស៊ីធ្វើស្រែចម្ការ នៅឯស្រុកកំណើតរបស់មិត្តវិញ ដើម្បីរៀបចំដំណាក់នីសារផ្តល់ព័ត៌មានខ្មាំងទៅតំបន់រំដោះ និងផ្សារភ្ជាប់ការទាក់ទងពីតំបន់រំដោះមកអង្គការបក្សក្នុងក្រុងវិញ ។ បក្សត្រូវការមិត្តជាចាំបាច់ដើម្បីសម្រេចភារកិច្ចនេះដោយជោគជ័យ ព្រោះមិត្តជាអ្នកស្រុកមុខកំពូលនេះស្រាប់ ដូច្នេះខ្មាំងមិនចាប់អារម្មណ៍ទេ ។ មិត្ត ថន ទទួលគោរពតាមការស្នើរបស់បក្ស និងការណែនាំសព្វបែបយ៉ាងរបស់បក្ស ដោយជ្រះថ្លាបំផុត គ្មានស្ទាក់ស្ទាញ គ្មានទោមនស្ស ឬស្តាយស្រណោះ អាឡោះអាល័យការសិក្សារបស់ខ្លួនឡើយ ។

មួយខែក្រោយមក មិត្ត ថន គឺបានរៀបចំគ្រួសារជាមួយមិត្ត ញ៉ែម ហើយវិលត្រឡប់ទៅប្រកបរបររកស៊ីធ្វើស្រែចម្ការជាមួយឪពុកម្តាយមិត្តនៅឯមុខកំពូលវិញ ។ មិត្ត ថន និងមិត្ត ញ៉ែម ពីរនាក់ប្តីប្រពន្ធ ម្យ៉ាងខិតខំបំពេញភារកិច្ចបដិវត្តន៍ដែលបក្សប្រគល់ឲ្យ ឲ្យបានសម្រេចជោគជ័យជានិច្ចមិនថាយប់ឬថ្ងៃឡើយ ។ ហើយម្យ៉ាងទៀត ក៏ខិតខំធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិតជាអ្នកក្រខ្សត់ និងដើម្បីបិទបាំងសកម្មភាពបដិវត្តន៍របស់មិត្តផង ។ នៅដើមឆ្នាំ ១៩៧១ មិត្តមានកូនប្រុសមួយដែលជាទីស្រឡាញ់គាប់ចិត្ត និងជាទ្រព្យសម្បត្តិយ៉ាងស្តុកស្តម្ភបំផុតនៃគ្រួសារបដិវត្តន៍ថ្មីនេះ ។ ទោះបីជាជាប់រវល់នឹងកូនតូចយ៉ាងនេះហើយក្តី ជាប់រវល់នឹងការងារស្រែចម្ការផងក្តី ក៏មិត្ត ថន និងមិត្ត ញ៉ែម មិនដែលផ្អាកឬពន្យារភារកិច្ចបដិវត្តន៍ម្តងណាឡើយ ។ មិត្តតែងវាយសម្រុកសម្រេចភារកិច្ចតូច-ធំ ជិត-ឆ្ងាយជូនបក្សបានជោគជ័យជានិច្ច ។

ខ្មាំងកាន់តែសាហាវឃោរឃៅហ្វាស៊ីស កាន់តែបង្កើនសកម្មភាពបង្ក្រាបរាគត្បាតប្រជាជនស្លូតត្រង់ នៅក្នុងស្រុកមុខកំពូលក៏ដូចជានៅក្នុងតំបន់ពួកវាកាន់កាប់ទាំងអស់ដែរ ។ នៅក្រោមរបបយោធានិយមហ្វាស៊ីសក្បត់ជាតិ និងក្រោមការជិះជាន់ឆក់ប្លន់ ទាំងយប់ទាំងថ្ងៃ ទាំងស្របច្បាប់ ទាំងមិនស្របច្បាប់ អំពីសំណាក់ពួកអាទាហានស៊ីឈ្នួលក្បត់ជាតិ ជីវភាពប្រជាជន ពិសេសប្រជាជនក្រីក្រកាន់តែធ្លាប់ដុនដាបឡើងៗជារៀងរាល់ថ្ងៃ ។ ឪពុកម្តាយមិត្តថន ដោយជីវភាពក្រក្សត់អត់ឃ្លាន ហើយធ្វើការធ្ងន់ធ្ងរ ហត់នឿយហួសប្រមាណ ក៏ធ្លាក់ខ្លួនទៅជាឈឺគ្រាំគ្រាក្អួតឈាមរហូតដល់ទទួលអនិច្ចកម្មជាបន្តបន្ទាប់ អស់ទាំងពីរនាក់ទៅ ។ ដូច្នេះក្នុងខ្ទមដ៏កំសត់នេះ មិត្តថនរស់នៅតែជាមួយគ្រួសារ និងកូនប្រុសតូចមួយនេះតែប៉ុណ្ណោះ ។

កាលពីពាក់កណ្តាលឆ្នាំ១៩៧១ មានកើតរឿងមួយក្នុងឃុំបាក់ខែង ស្រុកមុខកំពូល ខេត្តកណ្តាល ។ មានយប់មួយនោះ ខ្ញុំមានភារៈនាំឯកសារពីតំបន់ខ្មាំងទៅតំបន់រំដោះ ។ ដោយសភាពការណ៍នៅខាងមុខយើងមិនសូវល្អ ដោយសារមានទាហានខ្មាំងមួយកងកំពុងធ្វើការរាគត្បាតឆែកឆេររុករើសម៉ើមនៅទីនោះ ខ្ញុំក៏សម្រេចចិត្តយកឯកសារទៅផ្ញើទុកនៅផ្ទះមិត្ត ថន ក្នុងភូមិនេះមួយរយៈសិន ។

ប៉ុន្តែ វិលងបីថ្ងៃក្រោយមក បងញ៉ែម ដែលជាគ្រួសាររបស់មិត្ត ថន មានទំនាស់ជាមួយពួកអាទាហានខ្មាំងមួយក្រុម ដែលស្ទាក់ចាប់យុវនារីម្នាក់ ដែលជាកូនចៅប្រជាជនយើងនៅក្នុងភូមិនេះ ។ ពេលនោះគាត់បានចលនាប្រជាជនយើងដេញកាប់ពួកវា ។ ទំនាស់នេះកើតឡើងនៅពេលថ្ងៃត្រង់ ។

លុះព្រលប់ឡើង ស្រាប់តែមានឡានដឹកទាហានខ្មាំងមួយគ្រឿងមកឈប់មុខផ្ទះមិត្ត ថន ។ ពួកវាចុះពីលើឡានព្រូសៗសំដៅចូលទៅក្នុងផ្ទះនោះ ។ អាមេគេបញ្ជាឲ្យកូនទាហានវាព័ទ្ធផ្ទះ និងចូល

ឆែកឆេរ ។ ឃើញសភាព ដូច្នេះ បងញ៉ែម ក៏ចេញមកឈរពាំង មាត់ទ្វារផ្ទះ មិនឲ្យវាចូលទៅក្នុងផ្ទះបាន ។ ពួកវាបានស្រែកឲ្យគាត់ ជៀសចេញ តែគាត់មិនព្រមចេញ ។ គាត់តឹងសរសៃកជាមួយពួក វា ទាររកច្បាប់ដែលពួកវាចូលរកឆែកឆេរផ្ទះគាត់ទាំងយប់យ៉ាង ដូច្នេះ ។ ដោយវាឃើញគាត់ពុំព្រមចេញពីមាត់ទ្វារ ពួកវាក៏លើក កាំភ្លើងភ្ជង់បំពង់ក និងដើមទ្រូងគាត់ តែគាត់នៅតែឈរនឹងថ្កល់ធ្វើ ទឹកមុខមាំសម្លក់សម្លឹងទៅពួកវាវិញយ៉ាងអង់អាច ធ្វើឲ្យពួកវាញ័រ ដៃទៅជាខ្លាចគាត់វិញ ។ ឃើញដូច្នេះ អាមេវាស្ទុះហេមកចាប់សក់ ក្បាលគាត់កន្ត្រាក់ទាញគាត់ឲ្យចេញពីផ្លូវវា ។ តែត្រូវគាត់ដាល់ត្រូវ ចំកណ្តាលដើមទ្រូង ហើយគាត់រហ័សដៃកញ្ឆក់បានកាំភ្លើងខ្លីពី ចង្កេះវា ធ្វើឲ្យអានោះដួលផ្ងារក្រោយ និងធ្វើឲ្យគ្នាវាដកឃ្លាថយពី គាត់ ។ ប៉ុន្តែអានោះក៏រហ័សក្រោកដែរ ។ វាកញ្ឆក់កាំភ្លើងវែងពីគ្នា វាម្នាក់ ហើយតម្រង់មាត់ត្រែទៅរកគាត់ទាំងទឹកមុខក្តៅក្រហាយ ហើយស្រែកបញ្ជាទៅគ្នាវាថា៖ «ព័ទ្ធចាប់វាទាំងរស់ឲ្យបាន! យក វាទៅសួរចម្លើយព្រោះអានេះជាខ្មែរក្រហម១០០ភាគរយ» ។

តែពួកអាកូនទាហានសម្តែងអាការៈបែបចង់រាថយ ។ ប៉ុន្តែ ដោយកាំភ្លើងខ្លីដែលបងញ៉ែមកាន់បាញ់វាទៅគ្មានគ្រាប់សោះ ពួកវាក៏ស្ទុះស្រមកចោមរោមចាប់គាត់ភ្លាម ។ ពេលនោះ បងញ៉ែម មានទឹកមុខយ៉ាងមាំក្រហមសព្វសាច់ ក្រវាត់កាំភ្លើងខ្លីរបស់វាចោល ហើយវាយតដៃនឹងពួកវាការពារខ្លួនយ៉ាងអង់អាច ។ គាត់នៅតែ ឈរក្រាញនៅមួយកន្លែង ចំមាត់ទ្វារចូលវាយតនឹងពួកវា ធ្វើមិនឲ្យ ពួកវាចូលក្នុងផ្ទះបានឡើយ ។ កម្លាំងខ្លាំងរាប់សិបក្បាលហ៊ុមព័ទ្ធចាប់ គាត់ដូចស្រមោចរោមស្កុរ កម្លាំងរបស់មិត្តកាន់តែទ្រោបថយចុះៗ នាំឲ្យពួកវាប្រញាប់គ្នាចាប់គាត់បាន ហើយចងស្លាបសេកគាត់ ក្រោយពីការប្រយុទ្ធយ៉ាងតឹងតែង ស្លាប់រស់អស់រយៈពេលជាង កន្លះម៉ោងក្រោយមក ។ ឯពួកវាវិញក៏ត្រូវបង ញ៉ែម វាយដួល សន្លប់នៅនឹងកន្លែង គ្រេចដៃជើង ពកមុខមាត់មួយចំនួនធំ ។ ពួកវា អូសគាត់ចេញពីមាត់ទ្វារ ហើយវារត់ស្រចូលទៅក្នុងផ្ទះភ្លាម ។ ពួក វានាំគ្នារុករើក្រោមគ្រែ ក្នុងហឹបគៀនជញ្ជាំង ក្នុងអង្រឹងពេញតែ ផ្ទះ ។ មានអាខ្លះក៏បានចូលទៅក្នុងផ្ទះបាយ ។ នៅផ្ទះបាយនេះមិត្តថន កំពុងអង្គុយដាំទឹកជាមួយកូនប្រុសតូចរបស់មិត្ត ដែលទើបអាយុ ប្រាំ-ប្រាំមួយខែប៉ុណ្ណោះ ។ មិត្តហៀបនឹងក្រោកទៅហើយ តែអា ម្នាក់វាមកឈរពាំងមុខមិត្តដោយសួរថា «ធ្វើអីហ្នឹង បានជាផុំឈ្ងៀម ដូចដុតក្រដាស?» គាត់ក៏ឆ្លើយទៅវាវិញភ្លាមថា «ខ្ញុំដាំទឹក!» ។



កសិករនៅតាមសហករណ៍ ភ្ជួរស្រែ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

អានោះក៏យកចុងកាំភ្លើងវាគាស់ផ្ទាំងដាំទឹកចេញពីចង្ក្រាន ហើយកាយធ្យូងក្នុងចង្ក្រាននោះ ដើម្បីរកមើលកម្ទេចឯកសារដែលមិនទាន់ឆេះអស់ ។ តែវាគ្មានឃើញអ្វីសោះ វាក្ដៅក្រហាយណាស់ ។ វាសម្លឹងមុខគាត់រួចវានិយាយថា "រៀបខ្លួនទៅនៅក្នុងគុក វិញស្រួលជាង!" ។ មិត្តសួរវាវិញថា "ខ្ញុំមានរឿងអី បានជាចង់ចាប់ខ្ញុំទៅវិញ." ។ វាក៏គំរាមចាប់ដៃគាត់កន្ត្រាក់អូសទៅតាមវា ។ ដោយគាត់មានសុខភាពពុំសូវល្អផង គាត់ក៏ពុំអាចរើបម្រះគេចពីកណ្ដាប់ដៃវាបានឡើយ ។ គាត់ក៏ត្រូវវាអូសនាំយកទៅតាមវាទៅ ។

ឃើញបងញ៉ែមត្រូវវាចងស្លាបសេក មិត្ត ថន ខ្លោចចិត្តអាណិតគ្រួសារខ្លាំងណាស់ ។ ខ្មាំងវាអូសបង ញ៉ែម សំដៅទៅឡានវាដោយវាភ្ជង់កាំភ្លើងគាត់ជាប់ពីក្រោយ ។ ឯមិត្ត ថន ពរកូនប្រុសជាទីស្រឡាញ់របស់គាត់ដើរតាមក្រោយជាមួយពួកវាមួយចំនួនដែលអាខ្លះដើរបាំងពាចផង អាខ្លះត្រូវគ្នាវា សែងផង ។

ពួកវាក៏បាននាំមិត្តយើងទាំងពីរ និងក្មួយតូចឲ្យឡើងឡានជាមួយវា ។ ឡានបើកចេញពីទីនោះ ទៅដោយទុកចោលផ្ទះខ្ទមកំសត់នៅជ្រងោ។ ដែលអីវ៉ាន់ក្នុងផ្ទះនេះ នៅអារាក់អារាយ ភ្លើងចង្ក្រាននៅមិនទាន់រលត់ បបរនៅពេញឆ្នាំងមិនទាន់ហូប ទ្វារផ្ទះចំហធ្លុង ។

## ដាច់ខាតលះបង់អ្វីៗទាំងអស់ដើម្បីបដិវត្តន៍

ខ្មាំងវាបាននាំមិត្ត ថន ជាមួយបង ញ៉ែម និងកូនប្រុសគាត់ទៅឃុំឃាំងនៅទីសេនាធិការរបស់ពួកវាឯជ្រោយចង្វារ ។ ពេលទៅដល់ខ្មាំងវានាំបង ញ៉ែម ទាំងដៃជាប់ចំណងបញ្ចូលបន្ទប់សួរចម្លើយភ្លាម ។ ខ្មាំងបានឈ្លេចយកការណ៍ពីគាត់នូវឈ្មោះ និងទីកន្លែងរបស់មិត្តយើងដែលបានមកទាក់ទងធ្វើការងារជាមួយគាត់ ។ តែគាត់ឥតនិយាយរកវាឡើយ ។ ពួកវាយកគាត់ទៅចងដៃ ចងជើងចងខ្លួនភ្ជាប់នឹងកៅអី រួចវាបញ្ច្រកទឹកត្រីគាត់ទាល់តែគាត់សន្លប់លែងដឹងខ្លួន ។ រួចវាបញ្ជាគ្នាវាឲ្យដើរជាន់ពីលើខ្លួនប្រាណគាត់ ។ វាធ្វើទារុណកម្មលើរូបគាត់បណ្ដើរ ឈ្លេចសួរចម្លើយគាត់បណ្ដើរ ។ វាធ្វើដូច្នេះ ច្រំដែលៗអស់រយៈពេលបីយប់បីថ្ងៃ ។ ប៉ុន្តែវាគ្មានបានទទួលចម្លើយអ្វីបន្តិចពីគាត់ឡើយ ។ ដោយអស់សង្ឃឹមនឹងយកការណ៍ពីគាត់បានតទៅទៀត អាខ្មាំងក៏យកគាត់បញ្ចូលទៅក្នុងទ្រុងមួយ ហើយគ្រាំចោលនៅមាត់ទន្លេសាប ។ ទឹកលិចពាក់កណ្ដាលខ្លួនធ្វើឲ្យគាត់រងាររណ្ដំថ្គាម តែឆន្ទៈប្ដូរផ្ដាច់របស់បង ញ៉ែម នៅតែរឹងប៉ឹងជានិច្ច ទោះបីគាត់ត្រូវពលីជីវិតនៅពេលខាងមុខនេះក៏ដោយ ។ គាត់រីករាយណាស់ ព្រោះគាត់មិនបានធ្វើឲ្យខូចកម្លាំងបដិវត្តន៍ ព្រោះគាត់ការពារការសម្ងាត់របស់បដិវត្តន៍បានសមនឹងសេចក្ដីទុកចិត្តដ៏ធំធេងរបស់បក្សមកលើរូបគាត់ ។ ក្នុងរយៈពេលតែបីយប់បីថ្ងៃប៉ុណ្ណោះ មិត្ត ថន មើលមុខបង ញ៉ែម លែងស្គាល់ ព្រោះរាងកាយនិងមុខមាត់របស់បង ញ៉ែម ពេលនេះ ប្រែប្លែកទៅជាហើមលិបដាំខ្មៅរលសព្វសាច់ទាំងអស់ ។ ប៉ុន្តែបងញ៉ែម នៅតែខំញញឹមពព្រាយជានិច្ច ពេលខ្មាំងបណ្ដើរគាត់កាត់មុខមិត្ត ថន ដើម្បីលើកទឹកចិត្តគ្រួសាររបស់គាត់កុំឲ្យតក់ស្លុត ឬព្រួយបារម្ភអ្វីចំពោះរូបគាត់ ។

បន្ទាប់ពីយកការណ៍ពីបង ញ៉ែម មិនបាន វាក៏ហៅមិត្ត ថន និងកូនតូចទៅសួរចម្លើយទៀត ។ វាបាននាំ មិត្តថន ទៅជួបអាស័ក្តិពីរជានាយការិយាល័យទីពីររបស់វា ។ អានោះឃើញមិត្ត ថន ពរកូនចូលមក វាក៏ញញឹមដាក់គាត់ដោយនិយាយថា "យី! មិត្ត ថន ទេតើ! ខ្ញុំស្មានតែជនណា! បែកគ្នាតែពីរឆ្នាំប៉ុណ្ណោះមានកូនមួយស្រេច!" ។ មិត្តថនមិននិយាយអ្វីឡើយ គាត់ខំសម្លឹងមុខវាដោយគិតក្នុងចិត្តថា តើអានេះជាអ្នកណាអីចេះ? តែគាត់គិតមិនឃើញទាល់តែសោះ ។

បន្តិចក្រោយមក ស្រាប់តែមិត្ត ថន ឮវានិយាយទៀតថា "សាច់ឈាមប៉ុណ្ណឹងដែរ និងមិនគួរយកប្ដីយៀកកុងសោះ! មើលមិត្ត! តើអាចប្រាប់ខ្ញុំបានទេ ពីការទាក់ទងរវាងអាញ៉ែម និងពួកយៀកកុង?" ។

មិត្ត ថន ឆ្លើយទៅវាវិញដោយកំបុតថា "ខ្ញុំមិនដឹងទេ" ។ អាស័ក្តិពីរនោះក៏សួរបន្តទៅទៀតថា "មិត្តឯងលាក់នឹងយើង ។ ចុះមិត្តឯងដឹងថា វាធ្វើសកម្មភាពបម្រើយៀកកុងទេ?" ។

មិត្ត ថន ក៏នៅតែឆ្លើយនឹងវាថា មិនដឹងទៀត ។ វាសួរទៀតថា "ចុះពេលក្រសួងយើងទៅដល់ តើមិត្តឯងកំពុងដុតអីនៅក្នុងចង្ក្រាន?" គាត់ក៏ឆ្លើយទៅវាវិញភ្លាមថា "ខ្ញុំដុតភ្លើងដាំទឹក ពួកអស់លោកមិនឃើញទេឬ?" ។

អានោះវាលែងនិយាយអីតទៅទៀត ទឹកមុខវាផ្លាស់ប្ដូរមួយរំពេច ប្រែក្លាយទៅជាសាហាវឃោរឃៅភ្លាមដែរ ។

សូមបញ្ជាក់ថា នៅពេលដែលពួកវាឡើងទៅប្រុងឆែកផ្ទះរបស់មិត្ត ថន នោះ បងញ៉ែម បានឲ្យមិត្ត ថន យកឯកសារដែលខ្ញុំ

បានផ្ញើទុកទៅដុតកម្ទេចចោល ។ ចំណែកបង ញ៉ែម គាត់នៅឈរបាំងផ្លូវពួកវា ដើម្បីឲ្យមិត្ត ថន មានឱកាសកម្ទេចឯកសារនោះចោល ព្រោះជាឯកសារសម្ងាត់របស់អង្គការដែលទាក់ទងមូលដ្ឋានរំដោះ និងទីក្រុង ។ ឯកសារនេះក៏បានក្លាយទៅជាផេះអស់ ដោយគ្មានសល់អ្វីជាទីសម្គាល់ឡើយ មុនពេលដែលពួកវាចូលទៅដល់ក្នុងផ្ទះបាយបន្តិច ។ ហេតុនេះក្នុងការចូលឆែកឆេរផ្ទះមិត្ត ថន ខ្មាំងវាគ្មានចាប់បានភ័ស្តុតាងអីបន្តិចសម្រាប់យកជាការបានឡើយ ។ ខ្មាំងវាក្តៅក្រហាយណាស់ ព្រោះកម្ទេចកម្លាំងស្នូលនៃបដិវត្តន៍យើងមិនបានយកការណ៍ពីផែនការយើងក៏មិនបានទៀត ។ ទោះបីវាខំសម្លុត ធ្វើទារុណកម្មលើរូបរាងកាយបង ញ៉ែម យ៉ាងឃោរឃៅព្រៃផ្សៃយ៉ាងណាក៏ដោយ ក៏វាមិនអាចសម្រេចគោលបំណងខ្ញុំក្រិដ្ឋប្រឆាំងបដិវត្តន៍បានឡើយ ។ វាយកការណ៍ពីបង ញ៉ែម មិនបានវាក៏បន្តដើរខបាយកលឈ្លបយកការណ៍ពីមិត្ត ថន ទៀត ។ តែមិត្ត ថន មិនព្រមឆ្លើយឲ្យការណ៍ទៅពួកវាដាច់ខាត ។ គាត់បានបំពាក់ជាប់នូវគោលជំហររក្សាការសម្ងាត់របស់បដិវត្តន៍រឹងប៉ឹង គឺមិនដឹង មិនឮ មិនឃើញ មិនស្គាល់ ។

ដោយឃើញអាកប្បកិរិយារឹងត្អឹងរបស់មិត្ត ថន យ៉ាងនេះ ទើបមានអាម្នាក់ទៀតមាឌមាំ ស្លៀកពាក់ធម្មតា ស្ទុះពីក្រៅដើរចូលមក ។ រួចវាយកដៃវាចាប់កន្ត្រាក់កូនពីដៃគាត់ ហើយវាបោះទារកនោះ ឡើងទៅលើចុះឡើងៗ ដូចជាបោះបាល់លេងដូច្នោះដែរ ។ អាស័ក្តិពីរវាបន្តសួរគាត់ដោយសម្តីគំរាមថា "ប្រាប់អញមក! តើអាណាខ្លះដែលមកទាក់ទងជាមួយអា ញ៉ែម ដើម្បីឲ្យវាមកបំបះបំបោរប្រជាជនឲ្យប្រឆាំងនឹងកងទ័ពជាតិ? វាឈ្មោះអី? សព្វថ្ងៃវានៅកន្លែងណាខ្លះ? ឆ្លើយមក! បើនាងឯងស្រឡាញ់ជីវិតកូន ។ បើមិនឆ្លើយទេ អញនឹងប្របាច់កកូននាងឯងឲ្យស្លាប់ឥឡូវហ្នឹង" ។ មិត្ត ថន នៅស្ងៀម ភ្នែកខំសម្លឹងមើលកូនប្រុសជាទីស្រឡាញ់ស្មើជីវិតដែលកំពុងត្រូវបានពួកវា បោះឡើងលើចុះឡើងៗដូចបាល់ ។ បន្ទាប់មក វាយកដៃដ៏រឹងមាំរបស់វាទៅប្របាច់កទារកនោះ យោលយោគខ្លួនដូចប៉ោលនាឡិកា ។ មិត្តឮសំឡេងកូនស្រែកយំយ៉ាងខ្លោចផ្សាបំផុត លាយឡំនឹងសម្តីគំរាមកំហែងឈ្លបសួរចម្លើយរបស់អាស័ក្តិពីរប្រតិកិរិយា ។ វាសួរមិត្តរកមុខមិត្តយើងឈ្មោះអី? ធ្វើការអី? រស់នៅកន្លែងណា? បើមិនឆ្លើយទេ វាសម្លាប់កូនគាត់ឥឡូវ! ។ ជាក់ស្តែង មិត្ត ថន ស្គាល់មិត្តយើងមួយចំនួនដែរ ព្រមទាំងស្គាល់កន្លែងធ្វើការចំហរបស់មិត្តយើងទាំងនោះទៀត ។ គឺមិត្ត ថន ដឹងទាំងអស់ គាត់អាចឆ្លើយរាយការណ៍ប្រាប់បានចង្អុលមុខមិត្តយើងប្រាប់វាបាន ដើម្បីឲ្យកូនប្រុសជាទីស្រឡាញ់របស់គាត់អាចរស់រានមានជីវិតនៅជិតគាត់តទៅទៀត ។ ប៉ុន្តែមិត្ត ថន នៅតែមិនព្រមនិយាយអ្វីរកពួកវាឡើយ ។ គាត់ខំសម្លឹងទៅកូនរបស់គាត់ ដោយមនោសញ្ចេតនាខ្លោចចិត្ត អាណិតស្រឡាញ់យ៉ាងខ្លាំង មិត្តចង់ស្ទុះទៅប្រតាយប្រតប់ជាមួយខ្មាំងដណ្តើមកូនជាទីបណ្តូលចិត្ត មកបីបម ឱបក្រសោប ថ្នាក់ថ្នមក្នុងដៃមិត្តវិញ ។ តែមិត្តត្រូវពួកអាក្បត់ឃោរឃៅ ចាប់មិត្តចងភ្ជាប់នឹងកៅអី ។ ដូច្នេះមិត្តនៅសល់តែមាត់ និងពាក្យសម្តីដើម្បីជេរប្រទេចផ្តាសា បកអាក្រាតអំពើខ្ញុំក្រិដ្ឋហ្វាស៊ីសរបស់ពួកវាយ៉ាងអស់កំហឹងចិត្ត ។ កណ្តាប់ដៃដ៏កំណាចឃោរឃៅមហាហ្វាស៊ីស បានរឹតករបស់ក្មួយតូចយើងដែលគ្មានទោសពៃរ៍អ្វីសោះ កាន់តែតឹងឡើងៗរហូតភ្នែកក្មួយតូចនេះទៅជាសស្លែត មុខឡើងស្វាំង យំលែងចេញ ។ មិត្ត ថន បានឃើញទិដ្ឋភាពខ្លោចផ្សាចំពោះមុខដូច្នេះ មិត្តកាន់តែឈឺចាប់ កាន់តែចងអាឃាតក្តៅក្រហាយនឹងពួកខ្មាំងកាន់តែខ្លាំង ។ មិត្តក៏ស្រែកជេរពួកវាថា "អញគ្មានដឹងទេ! ពួកអាឯងសុទ្ធតែជាពួកក្បត់ជាតិ លក់ប្រទេស មហាព្រៃផ្សៃ មហាហ្វាស៊ីស ។ ពួកអាឯងសម្លាប់ប្រជាជនឥតរើសមុខទេ! សូម្បីតែកូនង៉ាក្នុងអង្រឹង ក៏ពួកអាឯងមិនញញើតដៃនឹងសម្លាប់ដែរ ។ នៅថ្ងៃមុខពួកអាឯងរាល់គ្នា គង់តែស្លាប់ដោយស្នាដៃរបស់ប្រជាជនកម្ពុជាទារបំណុលឈាមពួកអាឯងមិនខានឡើយ" ។ ពេលនោះស្រាប់តែស្បែកជើងបាតដែករបស់ពួកវាធាក់ចំកណ្តាលខ្នងមិត្ត ថនដូចរលកបោកប្រាំង ។ មិត្តក៏ដួលទៅមុខបោកខ្លួននឹងឥដ្ឋបែកអំពិលអំពែក សន្លប់លែងដឹងខ្លួនអស់រយៈពេលយ៉ាងយូរ ។

ពេលដែលមិត្តដឹងខ្លួនឡើងវិញ ស្រាប់តែឃើញសាកសពកូនប្រុសតូចរបស់មិត្តនៅដេកបិទភ្នែកទាំងពីរក្បែរខ្លួនមិត្ត ។ មិត្តខ្លោចចិត្តអាណិតកូនប្រុសតូចនេះណាស់ ។ មិត្តលើកសពកូនឡើងមកឱបផ្ទាប់នឹងដើមទ្រូង ដោយអារម្មណ៍ប្តេជ្ញាចំពោះកូនថា "កូននៅតូចណាស់! កូនត្រូវស្លាប់ដោយដៃខ្ញុំក្រិដ្ឋរបស់ពួកអាក្បត់ជាតិ ដោយគ្មានទោសពៃរ៍អ្វីឡើយ ។ តែសេចក្តីស្លាប់របស់កូន មានន័យជ្រាលជ្រៅណាស់ គឺស្លាប់ដើម្បីការពារការសម្ងាត់របស់បដិវត្តន៍

និងការពារកម្លាំងបដិវត្តន៍ ។ មិនអីទេ! ម៉ែ ពុក អ៊ុំៗ ពូៗ មីងៗរបស់កូនដែលនៅរស់ខាងក្រោយ ប្ដេជ្ញាសងឈាមជូនកូន និងប្រជាជនយើង ដែលត្រូវខ្មាំងជិះជាន់សង្កត់សង្កិនឲ្យបានដាច់ខាត» ។

នៅក្នុងបន្ទប់នេះ មិត្តគ្មានឃើញពួកវាណាម្នាក់សោះ ។ ប៉ុន្តែមិត្តស្ដាប់ឮសំឡេងវិទ្យុរបស់ពួកវា ដែលឆ្លើយឆ្លងគ្នានៅខាងក្រៅ ឮសូរល្មើយៗ ។ មិត្តខំផ្ទៀងត្រចៀកស្ដាប់វានិយាយដោយប្រុងប្រយ័ត្ន ។ ពួកវានៅទីនេះទទួលបញ្ជាពីអាសេនាធិការធំ ឲ្យបញ្ជូនបង ញ៉ែម ទៅគុលាការសឹកក្សត់ ហើយឲ្យដោះលែងខ្លួនមិត្តដើម្បីបន្តតាមដានរាវរកខ្សែយើងទៅទៀត ។ ក្នុងឧបាយកលនេះគឺវាយកមិត្ត ថន ធ្វើជាធ្នាក់ដើម្បីប្រមូលចាប់មិត្តយើងទាំងអស់ដែលនឹងមកទាក់ទងមិត្តថន ។

មួយម៉ោងក្រោយមក វាក៏មកដោះលែងមិត្ត ថន ឲ្យត្រឡប់ទៅផ្ទះវិញ ។ មិត្តពរសាកសពកូនចេញពីទីឃុំឃាំងទៅកាន់ខ្ទមកំសត់របស់មិត្តវិញ ទាំងឈឺចាប់ខ្លោចផ្សាក្តុកក្តួលក្នុងចិត្តក្រៃលែង ។ ពួកវាដោះលែងមិត្តមែន តែវាក៏លួចតាមដានមិត្តជាប់ដែរ ។ មិត្តត្រឡប់មករស់នៅក្នុងផ្ទះនេះវិញ ដោយគ្មានបានទាក់ទងជាមួយអ្នកណាម្នាក់ឡើយ ព្រោះខ្មាំងវាតាមឃ្លាំមើលជាប់រហូត ។ ហេតុនេះមិត្តត្រូវរស់នៅតែឯកឯងក្នុងផ្ទះ ដោយពុំបានចេញដើរទៅណាមកណាហូបតែអង្ករដែលសល់បាតបៅ៉តកាលមុនពេលខ្មាំងចាប់ប៉ុណ្ណោះ ។

### ជីវិតថ្មីក្នុងតំបន់រំដោះ

មានមួយថ្ងៃនៅពេលថ្ងៃត្រង់ ខ្ញុំបានទៅដល់ផ្ទះ មិត្តថន ។ ពេលទៅដល់ ខ្ញុំដើរកាត់មុខផ្ទះគាត់មួយត្រួស ដើម្បីពិនិត្យសភាពការណ៍ជុំវិញនោះ ។ ខ្ញុំក៏បានលួចមើលទៅក្នុងផ្ទះនេះបន្តិចដែរ ។ ខ្ញុំគ្មានឃើញមនុស្សដើរកាត់ ឬឈរនៅកន្លែងណាមួយឡើយ ។ ខ្ញុំក៏បានដើរចូលទៅក្នុងផ្ទះនេះភ្លាម ។

មុននេះខ្ញុំឃើញមិត្ត ថន សម្រាន្តយ៉ាងស្ងៀមស្ងាត់ ។ ពេលខ្ញុំឡើងទៅដល់លើផ្ទះ មិត្ត ថន ភ្ញាក់ព្រើត ហើយក្រោកមកទទួលខ្ញុំ ។ មិត្តនិយាយទាំងអួលដើមកមករកខ្ញុំថា «ប៉ុណ្ណេះ ខ្ញុំនឹងរួចពីទុក្ខភ័យគ្រប់បែបយ៉ាងហើយ ដោយសារមានអង្គការជួយយកចិត្តទុកដាក់រំដោះ និងការពារខ្ញុំ ។ កាលពីម្សិលមិញ និងម្សិលម្ងៃ ខ្ញុំក៏បានឃើញមិត្តយើងដើរកាត់ដែរ ប៉ុន្តែដោយមកពីមានគ្នាវាលបចាំឃ្លាំមើលនៅទីនេះ បានជាមិត្តទាំងនោះមិនទាន់ហ៊ានមកជួបខ្ញុំ» ។

ខ្ញុំពុំបាននិយាយអ្វីតបទៅគាត់វិញឡើយ ដោយរវល់ជាប់ងាកមើលក្រោយញឹកញាប់ ដើម្បីពិនិត្យសភាពការណ៍នៅខាងក្រៅផ្ទះ ។ ខ្ញុំឃើញមនុស្សចម្លែកម្នាក់ វាឈប់កង់ចំមុខផ្ទះ ភ្នែកវាសម្លឹងមកមើលយើងមួយសន្ទុះ រួចទើបវាជិះកង់ចេញទៅបាត់ ។ ខ្ញុំឆ្លៀតពេលនេះក៏ស្នើទៅមិត្ត ថន ឲ្យរៀបចំខ្លួនចេញពីផ្ទះគាត់ជាប្រញាប់ដែរ ទៅតាមការណែនាំរបស់អង្គការ ។ ក្រោយពីបានប្រាប់គាត់ពីកន្លែងណាត់ជួបគ្នារួច ខ្ញុំក៏ប្រញាប់ចេញទៅមុនគាត់ភ្លាមដែរ ។

ខ្ញុំចាំគាត់មួយសន្ទុះ ទើបឃើញគាត់ទៅដល់កន្លែងណាត់ ។ មកដល់ពេលព្រលប់ងងឹតមើលគ្នាមិនយល់ ទើបមានមិត្តម្នាក់មកនាំមិត្ត ថន ចេញតទៅទៀត ។ ក្រោយពេលគាត់ចេញផុតទៅបានបន្តិច ស្រាប់តែឮសូរឡានដឹកទាហានខ្មាំង បើកមកឈប់មុខផ្ទះដែលខ្ញុំស្នាក់នៅ ។ ខ្ញុំក៏រំសៀកខ្លួនចុះតាមសសរផ្ទះបាយ គេចតាមផ្លូវក្រោយផ្ទះបាត់ទៅ ។ ពួកវាចុះពីឡាន បើកប្រតិបត្តិការចូលឆែកឆេរតែសម្បកផ្ទះទទេ ដែលគ្មានមនុស្ស គ្មានសម្ភារ គ្មានអ្វីទាំងអស់ ។

អស់ពេលមួយអាទិត្យក្រោយមក យើងក៏បានទទួលដំណឹងថាមិត្ត ថន បានទៅដល់តំបន់រំដោះ ដោយសុវត្ថិភាពហើយ ។ មិត្តបានស្នើអង្គការចូលធ្វើកងទ័ពនារី ដើម្បីរួមចំណែកជាមួយយុទ្ធជនយុទ្ធនារីនៃកងទ័ពបដិវត្តន៍យើងឯទៀត វាយកម្ទេចខ្មាំងសងឈាមឲ្យគ្រួសារគាត់ កូនគាត់ និងប្រជាជន យើងដែលត្រូវខ្មាំងជិះជាន់សង្កត់សង្កិន ចាប់ចង កាប់សម្លាប់យ៉ាងឃោរឃៅហួសស៊ីសបំផុត ។ មិត្តបានចូលរួមបំពេញភារកិច្ចបដិវត្តន៍នេះ យ៉ាងអង់អាចក្លាហានសកម្មប្រយុទ្ធជាប់ជានិច្ច ។ មិត្តបានប្ដេជ្ញាខទ្ទិសឈាមស្រស់កម្លាំងកាយចិត្ត និងអាយុជីវិតរបស់មិត្ត ជូនបដិវត្តន៍ ជូនប្រជាជន ដោយគ្មានស្ដាយស្រណោះអាឡោះអាល័យអ្វីបន្តិចសោះឡើយ ។ តាំងពីពេលនោះមក យើងបែកគ្នារហូត ពុំដែលមានភារកិច្ចអ្វីទាក់ទងជាមួយគ្នាម្ដងណាឡើយ ហើយក៏ពុំដែលបានទទួលដំណឹងអ្វីអំពីគ្នាដែរ ។ ទើបតែថ្ងៃនេះ យើងបានជួបគ្នាដោយចៃដន្យ នៅលើការដ្ឋានលើកភ្លឺ ជីកប្រឡាយថ្មីនេះតែម្ដង ។ យើងរំភើបរីករាយឥតឧបមាដោយឃើញថា យើងនៅរស់ទាំងអស់គ្នា ។ យើងប្ដេជ្ញាបន្តធ្វើបដិវត្តន៍សង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជា ឲ្យកាន់តែខ្លាំងក្លា កាន់តែជ្រាលជ្រៅថែមទៀត ដើម្បីដណ្ដើមជ័យជម្នះលោតផ្លោះធំៗថ្មីៗទៀតជានិច្ច» ។ **ឆេង ខេង**

# ជម្លោះកោះរវាងកម្ពុជាប្រជាធិបតេយ្យ និងប្រទេសវៀតណាម

## *អតីតកងទ័ពខ្មែរក្រហម និយាយអំពីការកាន់កាប់កោះក្រចកសេះ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ*

*កង សុំ អាយុ៦៥ មានស្រុកកំណើតនៅភូមិស្តុក ឃុំស្តុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។ នៅឆ្នាំ១៩៧១ សុំ បានចូលបដិវត្តន៍ជាមួយកងទ័ពវៀតណាមខាងជើង ក្នុងកងពលទី៩ ព្រោះពេលនោះ វៀតណាមខាងជើងសុំដីខ្មែរ នៅម្តុំវត្តដុង, ជម្រៅ និងកាត់ក្តុក ដើម្បីធ្វើជាមូលដ្ឋានវាយវៀតណាមខាងត្បូង ។ នៅឆ្នាំ១៩៧២ តា១៥ (ឬ តាម៉ុក) បានទាមទារយកកងទ័ពខ្មែរពីវៀតណាមវិញ ។ សុំ មកនៅសេ៨ (ឬ វរសេនាតូចលេខ៨) ជាមួយកងរបស់ តាណាត (រួមមាន ៖ ណាត, ពីន និង តាសូ) ជាអ្នកដឹកនាំ ។ ពេលនោះ សុំ បានចេញពីស្រុកកំណើតរបស់គាត់ មកនៅស្អាងកោះធំវិញ ។ ក្រោយមកកងរបស់ សុំ ក៏ត្រូវបានបញ្ជូលមកនៅក្នុងកងពល១២ ក្រោមការគ្រប់គ្រងរបស់ ណាត និង ពីន ដដែលដែលត្រូវបានរៀបចំឡើងវិញ ។*

*ក្រោយពីជ័យជម្នះ សុំ ស្នាក់នៅភ្នំពេញបានមួយរយៈពេលខ្លីក្នុងខែមេសា ឆ្នាំ១៩៧៥ សុំ និងកងវរសេនាតូចរបស់គាត់*



*កងទ័ពបដិវត្តន៍ខ្មែរក្រហម យាមល្បាតនៅតាមឆ្នេរសមុទ្រ*

ត្រូវបានអគ្គការផ្លាស់មករួមជាមួយកងពល១៦៤ ផ្នែកជើងទឹកនៅកំពង់សោម ដែលមាន មាស មុត ជាលេខាកងពល ។ ខណៈនោះលេខាកងពល ១៦៤ បានបញ្ជាឲ្យវរសេនាតូចរបស់ សុំ ទៅកាន់កាប់កោះក្រចកសេះ (ភាសាបារាំងហៅថា កោះពូលូប៉ង់សង់ ចំណែកភាសាវៀតណាមហៅថា កោះថូជូ) ។ សុំ បានរៀបរាប់ថា វរសេនាតូចរបស់ខ្លួនដែលត្រូវធ្វើដំណើរទៅការពារកោះក្រចកសេះនោះមានចំនួន១៥០នាក់ ។ ឈ្មោះ ស៊ីង, ប៉ក់ និង នេន ជាលេខាអនុលេខា និងសមាជិករបស់វរសេនាតូច (បច្ចុប្បន្នស្លាប់ទាំងបីនាក់) ។ ចំណែក សុំ មានតួនាទីជាមេបញ្ជាការអនុសេនាតូច ។ ពេលទៅដល់លើកោះក្រចកសេះ សុំ បានឃើញប្រជាជនវៀតណាមប្រមាណ ២៥០នាក់ រួមមាន ក្មេង, ចាស់ រស់នៅលើកោះនោះ ។ ប្រជាជនស្ទើតែទាំងអស់លើកោះនោះចេះនិយាយភាសាខ្មែរ និងរាក់ទាក់យ៉ាងខ្លាំងជាមួយយោធាខ្មែរក្រហម ព្រមទាំងបានដាំបាយឲ្យហូបទៀតផង ។ ប៉ុន្តែនៅពេលនោះមេបញ្ជាការកងវរសេនាតូចរបស់ សុំ បាននិយាយវិទ្យុទាក់ទងជាមួយមេបញ្ជាការកងពលនៅកំពង់សោម ដែលបញ្ជាឲ្យជម្លៀសប្រជាជនចេញ ។ កងទ័ពរបស់ខ្មែរក្រហម បានដឹកប្រជាជនវៀតណាមទាំងនោះតាមកាណូត (កម្ទាំង៣៧សេះ) របស់ខ្លួនចំនួន៣គ្រឿង ។ កងទ័ពខ្មែរក្រហម បានប្រាប់ប្រជាជនវៀតណាមទាំងនោះថា នឹងដឹកពួកគាត់យកទៅដាក់នៅកោះត្រល់ ដើម្បីឲ្យត្រឡប់ទៅស្រុកកំណើតរៀងៗខ្លួនវិញ ។ ប៉ុន្តែជាក់ស្តែង សុំ មិនបានដឹងថាកងទ័ពខ្មែរក្រហមដឹកប្រជាជនវៀតណាមយកទៅដាក់នៅកោះត្រល់ពិតប្រាកដឬយ៉ាងណានោះទេ ពីព្រោះគាត់មិនបានចូលរួមដឹកប្រជាជនទាំងនោះ ។ កងទ័ពខ្មែរក្រហមបានទុកបុរសចំណាស់ម្នាក់ឈ្មោះ ង៉ុក ចេះនិយាយភាសាខ្មែរច្បាស់ (ខ្មែរកម្ពុជាក្រោម) និងស្គាល់ទីតាំងភូមិសាស្ត្រឲ្យបន្តនៅលើកោះក្រចកសេះ ។

តាង៉ុក បានជូនយោធាខ្មែរក្រហមដើរមើលកោះ និងប្រាប់ខ្មែរក្រហម ដូចជា កន្លែងឈមនឹងសមុទ្រដាក់ទ័ពមិនបាន គឺដាក់បានតែកាំភ្លើង៣៧មីលីម៉ែត្រ ។ តាង៉ុក បានបន្ថែមថា នៅលើកោះក្រចកសេះនេះមានទីលានឧទ្ធម្ភាគចក្រមួយ ។ បន្ទាប់ពីយោធាខ្មែរក្រហមដឹងភូមិសាស្ត្រលើកោះអស់ហើយ មេបញ្ជាការខ្មែរក្រហមក៏បញ្ជាឲ្យសម្លាប់ តាង៉ុក ចោល ។

សុំ បានបន្តថា នៅក្បែរកោះក្រចកសេះដែលគាត់យាមការពារ មានកូនកោះប៉ប្រះទឹកមួយទៀតដែលស្ថិតនៅជាប់នោះ ។ នៅពេលចង់ហូបពងសត្វរំពេរ កងរបស់គាត់បានជិះទូកទៅបោសសម្អាតខ្សាច់លើកូនកោះនោះ រួចហើយទុកចោលរយៈពេលពីរម៉ោងឲ្យសត្វរំពេចុះមកពង ទើបទៅកើបយកពងនោះមកស្ងោរហូប ។ នៅកោះក្រចកសេះ ក៏មានសត្វត្រកួត និងពង្រួលដែរ ។ ចំណែកដើម ឈើហូបផ្លែ សំបូរទៅដោយ ដូង ស្វាយ និង ខ្នុរ ព្រមទាំងមាន មាន់, ទា និង ជ្រូក ដែលប្រជាជនចិញ្ចឹមមុនពេលយោធាខ្មែរក្រហមទៅដល់ រួមជាមួយគ្នានោះក៏មានត្រីទឹកសាបដែរ ដូចជាត្រីអណ្តែង ជាដើម ។ ចំណែកទឹកសាបសម្រាប់ផឹក និងប្រើប្រាស់ កងរបស់ សុំ បូមពីអណ្តូងនៅលើកោះនោះ ។ ក្រៅពីអាហារដែលរកបាននៅលើកោះក្រចកសេះ កងរបស់ សុំ ទទួលរបបពីកងពលដែលមានមូលដ្ឋាននៅក្រុងកំពង់សោមដឹកយកទៅចែក ។

ក្រោយពេល សុំ នៅយាមការពារកោះក្រចកសេះបានតែប៉ុន្មានថ្ងៃ គាត់ក៏ទទួលដំណឹងថា កងយោធាខ្មែរក្រហមបានស្ទាក់ចាប់កប៉ាល់ ម៉ាយ៉ាហ្គេ របស់អាមេរិក ។ ប៉ុន្តែ អាមេរិកបានទាមទារឲ្យដោះលែង ហើយបានធ្វើការវាយប្រហារ និងទម្លាក់គ្រាប់លើមូលដ្ឋានយោធារបស់ខ្មែរក្រហមនៅកោះតាង កំពង់សោម និងរាម ។ ដូច្នេះហើយ សុំ និងសមាជិកកងរបស់គាត់ក៏ទទួលបញ្ជាឲ្យចល័តមកវាយជាមួយកងទ័ពអាមេរិក នៅកោះតាង និងកោះពូលូវៃ ។ សុំ បន្តថា យោធាខ្មែរក្រហមបានបាញ់ទាហានអាមេរិកាំងស្លាប់ជាច្រើន ដោយសារតែអាមេរិកាំងមានមាឌធំ និងបានបាញ់ទម្លាក់យន្តហោះចម្បាំងរបស់អាមេរិកមួយគ្រឿងនៅកោះពូលូវៃទៀត ។

បន្ទាប់ពីព្រឹត្តិការណ៍ប្រយុទ្ធគ្នាជាមួយកងទ័ពអាមេរិក និងបន្ទាប់ពី សុំ ការពារនៅលើកោះក្រចកសេះបានមួយរយៈ វៀតណាមបានបញ្ជូនកងទ័ពខ្លួនស្ងាត់ៗតាមកប៉ាល់ចូលមកកោះក្រចកសេះ បន្ទាប់មកកងទ័ពវៀតណាមចាប់ផ្តើមវាយចេញពីទីលានចុះឧទ្ធម្ភាគចក្រ កងទ័ពខ្មែរក្រហមទាំងអស់នៅលើកោះមិនបានចាប់អារម្មណ៍ថា កងទ័ពវៀតណាមអាចចូលមកដូច្នេះឡើយ ។

កងទ័ពវៀតណាមបានបាញ់ត្រូវ និងស្លាប់កងទ័ពខ្មែរក្រហមអស់ចំនួន៨នាក់ រួចហើយក៏បានក្តួងចាប់កងទ័ពខ្មែរក្រហមទាំង

អស់ដែលនៅលើកោះ ។ បន្ទាប់មក វៀតណាមបានសួររកមេបញ្ជាការ កងទ័ពខ្មែរក្រហមដែលប្រចាំនៅកោះក្រចកសេះនេះ ប៉ុន្តែដើម្បីលាក់បាំងកងយោធាខ្មែរក្រហមបានលួចយកកាំភ្លើងខ្លីរបស់មេបញ្ជាទៅពាក់ឲ្យសាកសពកងទ័ពខ្មែរក្រហមទាំងនោះ រួចហើយកុហកកងទ័ពវៀតណាមថា មេបញ្ជាការរបស់ខ្លួនបានស្លាប់បាត់ទៅហើយ ។ កងទ័ពវៀតណាម បានចាប់ខ្លួនយោធាខ្មែរក្រហមទាំងអស់ រួចដឹកតាមកាណូតទៅកោះត្រល់ទាំងយប់ ។

សុំ បានទៅដល់កោះត្រល់នៅពេលទៀបភ្លឺ ហើយគាត់ត្រូវបានកងទ័ពវៀតណាមយកទៅដាក់ នៅអតីតបន្ទាយរបស់ កងទ័ពធីវគី (វៀតណាមខាងត្បូង) ដែលមានរបងលួសបន្លាខ្ពស់ៗផុតពីក្បាល ។ នៅទីនោះ អ្នកយាមបានដកហូតយកសម្ភារប្រើប្រាស់ទាំងអស់ពីយោធាខ្មែរក្រហម ដូចជា នាឡិកា និងកន្សែងសូត្រ ។ ប៉ុន្តែមិនបានសួរចម្លើយ និងធ្វើទារុណកម្មលើអ្នកទាំងនោះទេ ។

រាល់ថ្ងៃ ឆ្មាំគុកបានដឹក សុំ និងកងយោធាខ្មែរក្រហមទាំងអស់តាមរថយន្ត យកទៅឲ្យបោចស្មៅនៅក្នុងចម្ការធុរេន នៅលើកោះត្រល់ ដែលមានប្រវែង៣៥គីឡូម៉ែត្រ (តាមរយៈដែនទឹកភូមិសាស្ត្រ) ។ សុំ បាននិយាយថា ប្រជាជននៅលើកោះត្រល់មានចិត្តល្អ និងបានទិញនំឲ្យកងរបស់គាត់ហូបទៀត ។ នៅក្នុងគុក សុំ និងយោធាខ្មែរក្រហមទាំងអស់ទទួលបានរបបអាហារជាធម្មតា ប៉ុន្តែមិនត្រូវបានផ្តល់ ថ្នាំពេទ្យឲ្យទេ ។ ដូច្នេះ យោធាខ្មែរក្រហមដែលត្រូវរបួសដោយសារការប្រយុទ្ធនៅលើកោះក្រចកសេះ ត្រូវយកទឹកអំបិលមកលាងរបួសដោយខ្លួនឯង ។

ឆ្មាំគុកបានបែងចែកយោធាខ្មែរក្រហមទៅជាកងតូចៗ និងបានជ្រើសមេកងម្នាក់ឲ្យគ្រប់គ្រង ។ ចំពោះសមាជិកកងណាដែលធ្វើខុសវិន័យ ដោយទៅបន្ទោរបង់នៅក្រោមបន្ទប់ហើយមិនបានសម្អាត អ្នកយាមនឹងធ្វើទារុណកម្មលើមេកងដោយវាយនឹងដំបង ព្រោះមិនចេះគ្រប់គ្រងសមាជិកក្រុម ។ នៅទីនោះ សុំ និងយោធាខ្មែរក្រហមទាំងអស់ បានរៀបចំគម្រោងវាយអ្នកយាម រួចហែលចេញពីកោះត្រល់ ។

ស្រាប់តែខណៈនោះ សុំ បានស្តាប់តាមវិទ្យុ (ឆ្មាំគុកអនុញ្ញាតឲ្យគាត់ស្តាប់វិទ្យុ) ឮថា សម្តេចព្រះ នរោត្តម សីហនុ ប្រកាសពីចំណងមិត្តភាពពិសេស សាមគ្គីភាពពិសេស រវាងវៀតណាម និងកម្ពុជា ទើបគាត់ផ្អាកផែនការរត់គេចខ្លួន ។ សុំ និងកងយោធាខ្មែរក្រហមទាំងអស់ នៅជាប់ឃុំឃាំងរយៈពេលបីខែ ទើបវៀតណាមដោះលែងឲ្យមកខ្មែរវិញ តាមច្រកហាទៀង ជាប់ស្រុកកំពង់ត្រាច ខេត្តកំពត ។ នៅមុនពេលដោះលែង វៀតណាមបានចែកស្បែកជើង, មួក និងបានកាត់ខោអាវឲ្យ សុំ និង កងយោធាខ្មែរក្រហមម្នាក់មួយកំប្លេរ ។ ពេលនោះ កង ចាប បានឲ្យកងយោធាតំបន់៣៥ ទៅទទួល សុំ និងសមាជិកកងទាំងអស់ពីវៀតណាម រួចហើយដឹកបន្តទៅក្រុងកំពង់សោម ។

នៅពេល សុំ មកដល់ប្រទេសកម្ពុជា ក្នុងអំឡុងខែតុលា និងវិច្ឆិកា ឆ្នាំ១៩៧៥ គាត់ និងសមាជិកកងទាំងអស់ដែលជាប់ឃុំនៅវៀតណាម មិនត្រូវទទួលស្វាគមន៍ពីសំណាក់មេបញ្ជាការកងពល ១៦៤ ទៀតទេ ព្រោះសង្ស័យថា ក្រុមរបស់គាត់ដែលវៀតណាមចាប់យកទៅឃុំជា សេ.អ៊ី.អា និង កា.ហ្សេ.បេ ។ សុំ និងសមាជិកកងទាំងអស់ត្រូវបានហៅមកប្រជុំនៅអូរតែល៧ជាន់ នៅក្នុងក្រុងកំពង់សោម ។

បន្ទាប់ពីប្រជុំចប់ សមាជិកកងទាំងមូលត្រូវបានដក និងបំបែកឲ្យទៅនៅអូរឈើទាល, រោងចក្រប្រេងកាត និងទៅស្ទឹងហាវ ព្រោះអង្គការមិនទុកចិត្ត ។ ចំណែកមេបញ្ជារបស់ សុំ ទាំងអស់ត្រូវបានទម្លាក់តួនាទី ពីប្រធានវរសេនាតូច មកអនុប្រធានវរសេនាតូច ដោយដាក់អ្នកថ្មីមកដឹកនាំជំនួសវិញ ។ ចំណែក សុំ នៅក្នុងកងពល ១៦៤ ដដែល តែត្រូវអង្គការដកកាំភ្លើងមិនឲ្យកាន់ និងបានដកសិទ្ធិជាសម្ព័ន្ធយុវជនបក្សកុម្មុយនីស្តកម្ពុជា រួចបញ្ជូនឲ្យទៅធ្វើស្រែនៅអូរម្លូ មុំព្រលានយន្តហោះកងកេង ។ ទីបញ្ចប់ អង្គការបានផ្លាស់ សុំ មកនៅក្នុងកងពល៧០៣ ដើម្បីវាយជាមួយវៀតណាម នៅតាមបណ្តោយព្រំដែនក្នុងស្រុកចន្ទ្រា, ស្រុកប្រសូត្រ និងស្រុករមាសហែក ក្នុងខេត្តស្វាយរៀង ។ សុំ នៅព្រំដែនបានរយៈពេលបីខែ ក៏រងរបួសត្រង់ភ្លៅ ហើយគាត់ត្រូវបានបញ្ជូនទៅព្យាបាលនៅមន្ទីរពេទ្យ ១៧ មេសា ក្នុងក្រុងភ្នំពេញ ។ រហូតមកដល់ដើមឆ្នាំ១៩៧៩ ពេលកងទ័ពវៀតណាមវាយចូលមកប្រទេសកម្ពុជា សុំ ក៏ជិះរទេះភ្លើងទៅខេត្តពោធិ៍សាត់ រួចបន្តដំណើរដោយថ្មើរជើងទៅស្រុកបវេល ខេត្តបាត់ដំបង ។

**សោម ប៊ុនថន**

# វេទិកាពិភាក្សាសាធារណៈស្តីពី ការអប់រំអំពីប្រល័យ
# ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្ត









# ...ពូជសាសន៍ក្នុងរបបខ្មែរក្រហម នៅភូមិកំពង់ឈើទាល ...កំពង់ធំ ថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥









# មិនដឹងរឿងរ៉ាវអាក្រក់របស់ខ្មែរក្រហម

កែវ រឿន រស់នៅភូមិចម្ការជ្រៃខាងត្បូង ឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។ រឿន មានប្រពន្ធឈ្មោះ អ៊ូច ឡៃ និងមានកូនប្រុសស្រីបីនាក់ ។ សព្វថ្ងៃ រឿន និងគ្រួសារ ប្រកបរបរធ្វើចម្ការ ដាំល្ង និងសណ្ដែក ។ គាត់មានស្រុកកំណើតនៅភូមិតាបេស ឃុំពេជ្រចង្វា ស្រុកបរិបូណ៌ ខេត្តកំពង់ឆ្នាំង ។ រឿន មានឪពុកឈ្មោះ កែវ នឹង និងម្ដាយ វ៉ាន់ ហ៊ុន ។ រឿន មានបងប្អូនចំនួន៨នាក់ (ស្រីម្នាក់) ហើយគាត់ជាកូនទី៥ ក្នុងគ្រួសារ ។

កាលពីតូច រឿន បានរៀនត្រឹមថ្នាក់ទី១០ប៉ុណ្ណោះ នៅសាលាវត្តលោក នៅឃុំពេជ្រចង្វា ។ នៅឆ្នាំ១៩៦៨ ដោយសារតែជីវភាពគ្រួសារយ៉ាប់យ៉ឺន និងរស់នៅតំបន់ដាច់ស្រយាលផងនោះ រឿន បានឈប់រៀនមកជួយធ្វើស្រែចម្ការឪពុកម្ដាយវិញ ។ នៅឆ្នាំ១៩៧២ ក្នុងវ័យប្រមាណ១៩ឆ្នាំ រឿន បានស្ម័គ្រចិត្តចូលធ្វើជាទាហានខ្មែរក្រហម ។ ការចូលរួមជាមួយចលនាខ្មែរក្រហមនេះ គឺ រឿន បានចូលតាមរយៈអ្នកភូមិ ដោយមានការឃោសនាពីសំណាក់ខ្មែរក្រហមអំពីការតស៊ូវណ្ណៈជាដើម ។ ភូមិស្រុកដែល រឿន រស់នៅគឺជាតំបន់ដាច់ស្រយាល ហេតុដូច្នេះនៅអំឡុងឆ្នាំ ១៩៧០ ខ្មែរក្រហមក៏បានចូលមកគ្រប់គ្រងតំបន់នោះ ។

រឿន ចូលធ្វើទាហានដំបូង នៅអង្គភាពស្រុកបរិបូណ៌ ហៅស្រុក១០ ។ នៅអង្គភាពស្រុកបាន២ខែ រឿន ក៏ផ្លាស់មកនៅខាងភូមិភាគបស្ចិម កងពលទី១វិញ ។ រឿន បានមកនៅវរសេនាធំ១៥ ដោយមាននាទីជាយុទ្ធជន ។ នៅអំឡុងពេលនោះ រឿន ត្រូវចាត់ចូលក្នុងកងអន្តរាគមន៍ ហើយចេញវាយគ្រប់ទីកន្លែង ចាប់ពីផ្លូវជាតិលេខ៤ រហូតដល់ព្រំប្រទល់ខេត្តពោធិ៍សាត់ នៅឆ្នាំ១៩៧២ ។ ក្រុមរបស់ រឿន ដើរវាយចល័តវាយ រហូតដល់ឆ្នាំ១៩៧៤ ទើបចាប់ផ្ដើមវាយសម្រុកមកខាងភ្នំពេញ ។ នៅខែមករា ឆ្នាំ ១៩៧៥ កម្លាំងរបស់ រឿន ចាប់វាយពីសមរភូមិខាងត្បូងភ្នំបាសិត ទៅទល់នឹងផ្លូវជាតិលេខ៤ និងពីផ្លូវរទេះភ្លើង ដល់វ៉ាសំរោង ។ ចំពោះអាវុធ រឿន បានបញ្ជាក់ថា មានគ្រប់គ្រាន់ទាំងអស់ ទាំងកាំភ្លើងតូច កាំភ្លើងធំ លើកលែងតែរថក្រោះប៉ុណ្ណោះ ដែលកងរបស់គាត់មិនមាន ។

ក្រោយថ្ងៃជ័យជម្នះ១៧ មេសា កងពលទី១ របស់ រឿន ត្រូវអង្គការបែងចែកជាពីរផ្នែក មួយផ្នែកត្រូវទៅឈរជើងនៅពោធិ៍ចិនតុង និងមួយផ្នែកទៀតទៅនៅការពារនៅខាងសមុទ្រ នៅព្រៃនប់ កោះខ្យង និងកោះសេះ ហើយទ័ពខ្លះទៀតនៅជួយធ្វើការក្នុងការដ្ឋាន លើកទំនប់ នៅម្ដុំព្រៃនប់ និងអូរចំណារ ។ រឿន បានឲ្យដឹងថា មន្ទីរកងពល មានពីរកន្លែង គឺមន្ទីរព្រៃនប់ និងមន្ទីរលង្វែក ដែលធំជាងគេ ។ រឿន បានឈរជើងនៅកោះខ្យង ក្នុងវរសេនាធំក្រោមការគ្រប់គ្រងរបស់ ឯក ផល រហូតដល់បែកឆ្នាំ១៩៧៩ តែម្ដង ។ ក្រោយមក ផល ត្រូវអង្គការចាត់តាំងឲ្យធ្វើជាគណៈតំបន់កោះកុង ។ ចំណែក រឿន ត្រូវអង្គការដំឡើងឋានៈជាបន្តបន្ទាប់ រហូតដល់ឆ្នាំ១៩៧៨ គាត់ទទួលតួនាទីជាប្រធានអនុសេនាតូច នៅខាងកោះខ្យង ដោយមានភារកិច្ចការពារព្រំដែនទឹក ។

រឿន បានបញ្ជាក់ថា ប្រជាជននៅតាមសមុទ្រ គឺមិនមានទេ ព្រោះអង្គការឲ្យមករស់នៅតាមផ្លូវជាតិ នៅម្ដុំព្រៃនប់ និងស្រែចាម ។ នៅកោះខ្យង មានមន្ទីរសន្តិសុខឃោធាមួយ សម្រាប់ដាក់អ្នកទោស ។ មន្ទីរនេះមិនដាក់អ្នកទោសផ្សេងនោះទេ គឺសម្រាប់តែកងទ័ពក្នុងអង្គភាពប៉ុណ្ណោះ ដែលប្រព្រឹត្តខុសនឹងអង្គការវិន័យ ដូចជា ខូចសីលធម៌ ស្រីញី និងលួចឆក់ប្លន់ប្រជាជន ។ រឿន បានឲ្យដឹងថា វិន័យរបស់កងទ័ព គឺតឹងរ៉ឹងជាងវិន័យរបស់ព្រះសង្ឃទៅទៀត ។ មន្ទីរសន្តិសុខកោះខ្យងនេះ មិនធំប៉ុន្មានទេ គឺមានទំហំត្រឹមតែ១០ម៉ែត្រ បួនជ្រុងប៉ុណ្ណោះ ហើយក៏មិនមានអ្នកទោសច្រើនដែរ ។ ចំពោះថា មានការសម្លាប់អ្នកទោស ឬក៏អត់នោះ រឿន មិនបានដឹងនោះទេ ដោយគាត់គ្រាន់តែធ្វើដំណើរឆ្លងកាត់ មិនបានចូលក្នុងមន្ទីរនោះទេ ។

រីឯការហូបចុក មិនមានការខ្វះខាតទេ សម្រាប់ រឿន នៅពេលនោះ តែពិបាកត្រង់ថា អង្គការមិនអនុញ្ញាតឲ្យនរណាម្នាក់មក

លេងផ្ទះឡើយ គឺនៅឈរជើងនៅទីនោះរហូត ។ កងទ័ពគឺ មានការងារគ្រប់គ្នាមិនមានពេលទំនេរទេ អ្នកការពារគឺការពារ អ្នកធ្វើស្រែ លើកទំនប់ ជីកប្រឡាយ មានការងាររៀងខ្លួន ។

នៅឆ្នាំ១៩៧៩ ក្រោយពេលដែលកងទ័ពវៀតណាមវាយទៅដល់ព្រៃនប់ កងពលរបស់ រឿន បានរត់បែកខ្ញែកគ្នាអស់ ។ កម្លាំងរបស់ រឿន វាយជាមួយវៀតណាមបណ្ដើរ ដកថយបណ្ដើរ រហូតដល់កោះកុង ក្លងយៃ ថ្មបាំង ដងទង់ និងមកដល់ព្រំដែនខ្មែរ-ថៃ តែម្ដង ។ នៅអំឡុងឆ្នាំ ១៩៨០ តា ម៉ុក បានដកកម្លាំងរបស់ រឿន មកខាងភ្នំដងរែកជាមួយគាត់វិញ ។ រឿន បានឈរជើងនៅតាមព្រំដែនលាវបណ្ដោយជួរភ្នំដងរែក រហូតដល់ឆ្នាំ១៩៨២ ទើបអង្គការចាត់តាំងឲ្យគាត់ចុះមកចលនាប្រជាជនតាមភូមិក្នុងខេត្តព្រះវិហារ ដែលមាន ស្រុកសង្គមថ្មី និងស្រុកស្វាយលើ ។

មកដល់ឆ្នាំ១៩៨៤ អង្គការបានផ្លាស់ រឿន មកឈរជើងនៅតាមដងទន្លេសាបវិញ ពីដងស៊ឹងសែនមកដល់កំពង់ឆ្នាំង ។ រហូតដល់ឆ្នាំ១៩៨៨ ទើបអង្គការដក រឿន និងកម្លាំងរបស់គាត់មួយចំនួនមកធ្វើការនៅខេត្តកំពង់ឆ្នាំងតែម្ដង ។

រឿន បានរៀបការនៅឆ្នាំ១៩៨១ នៅស្រុកអន្លង់វែង ក្រោយមកអង្គការដកគាត់មកធ្វើកងទ័ព ដោយទុកប្រពន្ធ និងកូនគាត់រស់នៅភូមិអូរសិរិល ស្រុកសំឡូត ។

**ធាវ សារមុនិន្ទ**

# ខ្សែភាពយន្តឯកសាររឿង «ក្បង់ទឹកទន្លេ»

*"ក្បង់ទឹកទន្លេ" គឺជាខ្សែភាពយន្តឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលទទួលបានការគាំទ្រ និងទិដ្ឋាការពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ មកដល់ពេលនេះ ខ្សែភាពយន្ត "ក្បង់ទឹកទន្លេ" ទទួលបានពានរង្វាន់លំដាប់ពិភពលោកចំនួន១៦ហើយ ។ "ក្បង់ទឹកទន្លេ" បង្ហាញនូវដំណើរជីវិតមួយដ៏វិសេសវិសាល និងមិនធ្លាប់មានពីមុនមក ដែលផ្ដើមចេញពីតំបន់ជនបទ ចុងកាត់មាត់ញកព្រៃភ្នំ និងភូមិនេសាទនៅលើផ្ទៃទឹករបស់តួអង្គទាំងបី ។ ខ្សែភាពយន្តនេះបានចាក់បញ្ចាំងនៅសារមន្ទីរសិល្បៈទំនើប សហរដ្ឋអាមេរិក ចាប់ពីថ្ងៃទី១២ ដល់ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ និងប្រទេសអូទ្រីស បែលហ្ស៊ិក អាល្លឺម៉ង់ កូរ៉េខាងត្បូង អ៊ីតាលី អង់គ្លេស និងប្រទេសសិង្ហបុរី ។ ខ្សែភាពយន្តឯកសារនេះ ក៏គ្រោងនឹងដាក់បញ្ចាំងតាមសាកលវិទ្យាល័យ និងភូមិចំនួន៦០ ទូទាំងប្រទេសកម្ពុជា ដើម្បីបើកឲ្យមានការពិភាក្សាស្ដីពីការផ្លាស់ប្ដូរបរិស្ថាន ដើម្បីស្វែងរកដំណោះស្រាយ ។*

*ខ្សែភាពយន្តនេះក៏មានចាក់បញ្ចាំងជូនទស្សនារៀងរាល់ថ្ងៃសុក្រនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។*

*ព័ត៌មានបន្ថែមសូមទាក់ទង កញ្ញា សា ហ្វាទីលី តាមរយៈទូរស័ព្ទលេខ ៖ ០១២ ៥១១ ៩១៤ ។*

*អ៊ីម៉ែល ៖ truthfatily.s@dccam.org គេហទំព័រ ៖ www.ariverchangescourse.com*





# ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យដើម្បីការផ្សះផ្សា

ជាផ្នែកមួយនៃការបន្តចាំ និងយុត្តិធម៌របស់មជ្ឈមណ្ឌលឯកសារកម្ពុជា នៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៥ គម្រោងស្តីពីការអប់រំអំពើប្រល័យពូជសាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានធ្វើវេទិកាសាធារណៈ នៅភូមិកំពង់ឈើទាល ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ដោយមានការចូលរួមពីសិស្សានុសិស្សវិទ្យាល័យកំពង់ឈើទាល និងអ្នកភូមិមួយចំនួន ដើម្បីធ្វើឲ្យប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យកាន់តែទូលំទូលាយ ពីព្រោះប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺជាប្រវត្តិសាស្ត្រមួយដែលប្រជាជនទូទៅបានដឹង ហើយតែងតែលើកមកពិភាក្សា និងចែករំលែកនូវបទពិសោធជាសាធារណៈ ។ បន្ថែមពីលើនេះ គោលបំណងចម្បងនៃវេទិកាសាធារណៈនេះ គឺដើម្បីបន្ថែមនូវការពិតដែលជាប្រវត្តិសាស្ត្រសម្រាប់ជំរុញ និងផ្សព្វផ្សាយឲ្យមានការផ្សះផ្សា ដោយមានការដឹកនាំពិភាក្សាពីអ្នកជំនាញរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ភ្ជាប់នឹងរឿងរ៉ាវរបស់ជនរងគ្រោះដែលបានរួចផុតជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ ។

ការអប់រំអំពើប្រល័យពូជសាសន៍ គឺជាវិធីតែមួយគត់ ដែលជួយបំផុសគំនិតសិស្សានុសិស្ស ឲ្យមានការគិតពិចារណា និងយល់ពីមួយកម្រិតទៅមួយកម្រិត ពីព្រោះអំពើប្រល័យពូជសាសន៍ មិនមែនជារឿងដែលកើតឡើងដោយចៃដន្យនោះទេ ។ ដូច្នេះហើយ ក្មេងៗជំនាន់ក្រោយ ជាពិសេសសិស្សានុសិស្សត្រូវតែយល់ឲ្យបាន



រូបអង្គុយនៅកណ្តាល ឯល ឡាស់ ជតក្នុងវេទិកាសាធារណៈ រៀបចំឡើងដោយគម្រោងអប់រំស្តីពីអំពើប្រល័យពូជសាសន៍ របស់មជ្ឈមណ្ឌលឯកសារ ស្ថិតនៅក្នុងភូមិកំពង់ឈើទាល ឃុំសំបូរ ស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ

ច្បាស់នូវឫសគល់នៃរបបខ្មែរក្រហមថា តើវាកើតឡើងដោយរបៀបណា? មូលហេតុអ្វីខ្លះដែលធ្វើឲ្យវាកើតឡើង ។

ហ៊ុល ដាលីន ជាសិស្សនៃវិទ្យាល័យកំពង់ឈើទាល មានចំណាប់អារម្មណ៍ថា វាពិតជាមានសារសំខាន់ណាស់ដែលសិស្សទាំងអស់ត្រូវតែដឹងពីប្រវត្តិសាស្ត្ររបស់ខ្លួន ជាពិសេសប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដើម្បីធ្វើឲ្យសិស្សកាន់តែយល់ពីប្រវត្តិសាស្ត្រនេះ ។ បន្ថែមពីលើនេះទៀត ដាលីន ក៏បានស្នើសុំឲ្យមានរៀបចំវេទិកាសាធារណៈបែបនេះទៀត ពីព្រោះព័ត៌មានអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅមានកម្រិត ជាពិសេសនៅតាមតំបន់ជនបទដូចជា ភូមិរបស់ខ្លួនជាដើម ។

ឯល ឡាស់ ដែលជាខ្មែរអ៊ីស្លាម មកពីភូមិត្រពាំងឈូក ឃុំបឹង ស្រុកបារាយណ៍ ខេត្តកំពង់ធំ បានឲ្យដឹងថា អ្វីដែលគាត់ត្រូវធ្វើនោះគឺ មកចែករំលែកនូវជីវិតដ៏ជូរចត់របស់ប្រជាជនកម្ពុជានៅក្នុងរបបខ្មែរក្រហម ពីព្រោះគាត់ក៏ជាមនុស្សម្នាក់ដែលធ្លាប់បានរស់នៅឆ្លងកាត់ការលំបាកវេទនា ដូចជា ការបង្អត់អាហារ ការបង្ខំឲ្យធ្វើការងារហួសកម្លាំង និងការកាប់សម្លាប់ដែលខ្មែរក្រហមបាន ប្រព្រឹត្តទៅលើមិនត្រឹមតែប្រជាជនទូទៅប៉ុណ្ណោះទេ ប៉ុន្តែក៏ទៅលើប្រជាជនខ្មែរអ៊ីស្លាមដែរ ។ វេទិកាសាធារណៈនេះ នឹងធ្វើឲ្យសិស្សានុសិស្សទាំងអស់យល់កាន់តែច្បាស់នូវប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងដើម្បីឲ្យដឹងនូវអ្វីដែលជាការពិតប្រវត្តិសាស្ត្រមួយនេះ ។

ប៉ាត់ ដារ៉ាពីពូន ជាមេភូមិកំពង់ឈើទាល បានលើកឡើងថា វេទិកាសាធារណៈស្តីអំពីការអប់រំប្រល័យពូជសាសន៍ កម្ពុជាប្រជាធិបតេយ្យនេះពិតជាមានសារសំខាន់ណាស់ដើម្បីបញ្ជ្រាបចំណេះដឹង និងការយល់ដឹងរបស់សិស្សានុសិស្សអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងដើម្បីឲ្យដឹងពីការប្រព្រឹត្តអំពើឃោរឃៅរបស់ខ្មែរក្រហម ស្របពេលសិស្សមួយចំនួនមិនទាន់ជឿនៅឡើយនូវអ្វីដែលបានកើតឡើងនៅក្នុងរបបនោះ តាមរយៈការនិយាយប្រាប់ពីឪពុកម្តាយ ។

ទោះបីជាយ៉ាងណាក៏ដោយ រឿងដែលគួរឲ្យកត់សម្គាល់នោះ គឺសិស្សានុសិស្សបានសួរសំណួរជាច្រើនទាក់ទងទៅនឹងរបបខ្មែរក្រហមដែលបង្ហាញឲ្យយើងឃើញថា សិស្សានុសិស្សកាន់តែចាប់អារម្មណ៍ទៅលើរបបខ្មែរក្រហមនេះ ។ ដូច្នេះហើយ ដើម្បីធ្វើឲ្យប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យកាន់តែមានភាពច្បាស់លាស់ និងទូលំទូលាយ យើងគួរតែរៀបចំវេទិកាសាធារណៈស្តីអំពីការអប់រំរបបខ្មែរក្រហមបន្ថែមទៀត ។

ការបង្រៀន ការស្តាប់ និងការចែករំលែកប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ គឺជាវិធីដ៏មានប្រសិទ្ធភាពដើម្បីធ្វើឲ្យក្មេងៗជំនាន់ក្រោយ ជាពិសេសសិស្សានុសិស្សបានដឹង និងធ្វើការត្រិះរិះពិចារណាពីកំហុសអតីតកាល ដើម្បីតភ្ជាប់នឹងមេរៀនអនាគត ។ ការធ្វើដូច្នេះគឺដើម្បីធ្វើឲ្យស្លាកស្នាមប្រវត្តិសាស្ត្រមួយនេះ នឹងអាចត្រូវបានព្យាបាលតាមរយៈការផ្សះផ្សា និងការអភ័យទោសចំពោះអ្វីដែលបានកើតឡើង ។ **ស៊ាង ចិន្តា**



រូបអង្គុយខាងមុខ ប៉ាត់ ដារ៉ាពីពូន ថតក្នុងវេទិកាសាធារណៈ

# ចាប់ពីរបបខ្មែរក្រហម ដល់ឧប្បត្តិហេតុ ហាំបាលី : អត្តសញ្ញាណជនជាតិចាម នៅក្នុងយុគសម័យសកលភាវូបនីយកម្ម

***(តពីលេខមុន)***

***ជំពូក៣ៈ ជនជាតិចាមនៅក្នុងទស្សនវិស័យប្រវត្តិសាស្ត្រ***

*នៅក្នុងសៀវភៅ The Ironist's Cage អ្នកនិពន្ធ ម៉ៃឃើល រ៉ស់ Michael Roth បានអះអាងថា “ប្រវត្តិសាស្ត្របានក្លាយជាកន្លែងមួយដែលមនុស្សតែងតែងាកទៅរកដើម្បីនិរន្តភាព ស្ថេរភាព និងលទ្ធភាពដើម្បីធ្វើសកម្មភាពតាមរបៀបមួយដែលមានអត្ថន័យ ពោលគឺមិនមានលក្ខណៈបំពារបំពាន ។ ដោយគ្មានធម្មជាតិ ឬព្រះជាម្ចាស់ដើម្បីណែនាំយើង ទស្សនវិស័យប្រវត្តិសាស្ត្រអាចផ្តល់ភាពស្របច្បាប់ដល់អត្តសញ្ញាណមួយ ក៏ដូចជាកម្មវិធីមួយសម្រាប់ការផ្លាស់ប្តូរ” ។ នៅក្នុងជំពូកនេះ ប្រវត្តិជនជាតិចាមនឹងត្រូវបានលើកយកមកសិក្សា ដើម្បីស្វែងយល់បន្ថែមទៀតនូវការវិវត្តនៃអត្តសញ្ញាណរបស់ជនជាតិចាម ។ ប្រវត្តិសាស្ត្រចម្ប៉ា និងជនជាតិចាម ត្រូវបានធ្វើការសិក្សាយ៉ាងទូលំទូលាយ ជាពិសេសដោយអ្នកសិក្សាស្រាវជ្រាវជនជាតិបារាំង ដែលបានត្រួសត្រាយផ្លូវជាមួយនឹងការសិក្សារបស់ពួកគេអំពីការដួលរលំរបស់ចម្ប៉ានៅក្នុងប្រទេសវៀតណាមភាគកណ្តាល និងខាងត្បូងនៅដើមសតវត្សរ៍ទី២០ ។ ប៉ុន្តែ ចំណេះដឹងនេះមិនមានឥទ្ធិពលមកលើជនជាតិចាមជំនាន់ក្រោយទេ ។ ដូចដែលត្រូវបានស្រាវជ្រាវដោយអ្នកសិក្សា*



*រូបចម្លាក់បង្ហាញពីចម្បាំងរវាងចាម និងខ្មែរ នៅលើជញ្ជាំងប្រាសាទបាយ័ន ក្នុងខេត្តសៀមរាប*

ស្រាវជ្រាវ សូម្បីតែនៅក្នុងចំណោមមនុស្សចាស់ ប្រវត្តិសាស្ត្រចម្ប៉ា មានការយល់ដឹងតិចតួចណាស់ ។ ពួកគេចងចាំរឿងចម្ប៉ាហាក់ដូចជារឿងនិទាន ដែលបានបន្តពីជំនាន់មួយទៅជំនាន់មួយទៀតតាមរយៈការនិទាន ។

ចំណុចសំខាន់នៅក្នុងជំពូកនេះ គឺដើម្បីកំណត់ប្រវត្តិដើមនៃសាសនាអ៊ីស្លាមនៅក្នុងប្រទេសកម្ពុជា ដែលជាអត្តសញ្ញាណសំខាន់បំផុតរបស់ជនជាតិចាម ការចូលមករស់នៅក្នុងប្រទេសរបស់ជនជាតិចាម និងតួនាទីរបស់ពួកគេនៅក្នុងសង្គម និងនយោបាយកម្ពុជា ។ ការនេះនឹងអនុញ្ញាតឲ្យយើងយល់អំពីរបៀបដែលអត្តសញ្ញាណរបស់ជនជាតិចាមបានផ្លាស់ប្តូរកន្លងមក ។ ជំពូកនេះនឹងពិនិត្យមើលអំពីការរីកចម្រើន និងការធ្លាក់ចុះនៃអតីតអាណាចក្រចម្ប៉ារបស់ប្រជាជនចាម ដែលបណ្តាលឲ្យមានការផ្លាស់ប្តូរទីលំនៅមកប្រទេសកម្ពុជា រចនាសម្ព័ន្ធនយោបាយរបស់ចម្ប៉ា និងវីរមេទ័ពជាស្តេចរបស់ជនជាតិចាម ។ បន្ទាប់មក ជំពូកនេះនឹងវិភាគអំពីការប្រកាន់យកសាសនាអ៊ីស្លាមនៅក្នុងចំណោមជនជាតិចាមនៅកម្ពុជា ទំនាក់ទំនងរបស់ពួកគេជាមួយជនជាតិជ្វាដែលបានមកនៅក្នុងប្រទេសកម្ពុជាមុនជនជាតិចាម ការចូលរួមរបស់ពួកគេ នៅក្នុងនយោបាយកម្ពុជា និងឥទ្ធិពលអ៊ីស្លាមមកលើរាជវង្សកម្ពុជាតាមរយៈការពិភាក្សាអំពីព្រះរាជាកម្ពុជាដែលកាន់សាសនាអ៊ីស្លាម ។ ចុងក្រោយ ជំពូកនេះនឹងពិនិត្យមើលអំពីតួនាទីរបស់ជនជាតិចាម នៅក្នុងអំឡុងអាណានិគម ការធ្លាក់ចុះរបស់ពួកគេនៅក្នុងដំណាក់កាលពាក់កណ្តាលដំបូងនៃសតវត្សរ៍ទី២០ និងតួនាទីរបស់ពួកគេនៅក្នុងរបបសាធារណរដ្ឋខ្មែរចន្លោះពីឆ្នាំ១៩៧០ និង១៩៧៥ ។

## ១) រចនាសម្ព័ន្ធនយោបាយប្រទេសចម្ប៉ា

អ្វីដែលចាប់អារម្មណ៍ជាងគេអំពីប្រវត្តិសាស្ត្រចម្ប៉ាសម្រាប់ប្រជាជនកម្ពុជាប្រហែលជាថា វាជាប្រទេសមួយដែលលែងមានអត្ថិភាពទៀតហើយ ប៉ុន្តែ ចម្ប៉ាមានប្រវត្តិជាប់ទាក់ទងយ៉ាងខ្លាំងជាមួយកម្ពុជា និងប្រជាជនកម្ពុជា ដូចដែលមានឆ្លាក់នៅក្នុងចម្លាក់នៃប្រាសាទបាយ័ននៅក្នុងខេត្តសៀមរាប ។ កូនចៅចម្ប៉ាដែលរស់នៅក្នុងប្រទេសកម្ពុជាសព្វថ្ងៃ ជាក្រុមជនជាតិភាគតិចបែបសាសនាមិនធំដុំមួយ ប៉ុន្តែ មានប្រវត្តិយ៉ាងសំខាន់ជាមនុស្សជំនាន់ក្រោយនៃអាណាចក្រដ៏មានឥទ្ធិពលដែលអាចវាយកាន់កាប់ក្រុងអង្គរ ។

នៅក្នុងប្រវត្តិសាស្ត្រ រឿងរបស់ជនជាតិចាមបានប្រែប្រួលពីអ្នកកាន់សាសនាព្រះពុទ្ធ-ហិណ្ឌូ ទៅកាន់សាសនាអ៊ីស្លាមពីម្ចាស់ដីឯករាជ្យទៅជាជនអន្តោប្រវេសន៍ពីក្រុមដែលមានប្រវត្តិសាស្ត្រនិងស្ថាបត្យកម្មសម្បូរបែបទៅជាស្ទើរតែគ្មានឯកសារប្រវត្តិសាស្ត្រនៅសព្វថ្ងៃនេះ និងពីត្រូវសម្លាប់រង្គាល ដោយវៀតណាមទៅជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍របស់ខ្មែរក្រហម ។ សព្វថ្ងៃនេះ ជនជាតិចាមកំពុងតែងើបខ្លួនពីភាពជាជនរងគ្រោះ និងពីក្រុមដែលធំដុំនេះ ព្រមទាំងកំពុងតែកែប្រែអត្តសញ្ញាណខាងក្រៅនេះឲ្យសមស្របតាមលក្ខខណ្ឌក្នុងស្រុក និងសកលលោក ។ ប្រវត្តិសាស្ត្របានប្រាប់នូវរឿងជាច្រើនអំពីអត្តសញ្ញាណរបស់ជនជាតិចាម ។

ចម្ប៉ាជាអាណាចក្រដែនទឹកមួយ លាតសន្ធឹងពីវៀតណាមកណ្តាលទៅដល់ភាគខាងជើងនៃដីសណ្តទន្លេមេគង្គ ។ ដោយសារតំបន់នេះជាតំបន់ភ្នំ ប្រជាជនចាមមិនមែនជាសង្គមកសិកម្មទាំងស្រុងទេ ។ ភាគច្រើនចម្ប៉ាល្បីល្បាញខាងពាណិជ្ជកម្មអន្តរជាតិជាពិសេសជាមួយប្រជុំកោះអាស៊ីអាគ្នេយ៍, ជ្វា, ស៊ូម៉ាត្រា និងបន្តដល់ប្រទេសចិន ឥណ្ឌា និងមជ្ឈិមបូព៌ា ។ គេជឿថា ពីដំបូងប្រជាជនចាម ជាអ្នករុករក និងជាអ្នកនាវាចរសមុទ្រដែលបានរុករកឃើញដីទំនាបមានជីជាតិនៅតាមបណ្តោយឆ្នេរអាណាម និងបានបោះទីតាំងនៅទីនោះជាអចិន្ត្រៃយ៍ ។ ដែនដីនោះបានផ្តល់ឱកាសមានកំណត់សម្រាប់ ការធ្វើកសិកម្ម ប៉ុន្តែ មានទីតាំងនៅក្បែរកំពង់ផែសំខាន់ៗ ដែលបានផ្តល់ភាពងាយស្រួលដល់ជនជាតិចាមទៅសមុទ្រចិនខាងត្បូង និងឆ្ងាយជាងនេះទៀត ។

ដូចប្រទេសផ្សេងទៀតនៅអាស៊ីអាគ្នេយ៍កាលពីជាងពីរពាន់ឆ្នាំមុនដែរ ជនជាតិចាមទទួលឥទ្ធិពលពីវប្បធម៌ឥណ្ឌា ។ នេះគឺមានឆ្លាក់នៅក្នុងចម្លាក់តាមប្រាសាទនៅក្នុងតំបន់ដែលមានសរសេរជាភាសាសំស្ក្រឹត ។ ប៉ុន្តែ សម្រាប់ជនជាតិវៀតណាម វប្បធម៌ចិនមានឥទ្ធិពលជាងគេ ។ នៅឥណ្ឌូចិន (កម្ពុជា ឡាវ វៀតណាម) វៀតណាមជាតំបន់ដែលទទួលឥទ្ធិពលចិន ចំណែកកម្ពុជាជាតំបន់ដែលទទួលឥទ្ធិពលឥណ្ឌា ។ នៅចន្លោះនេះ គឺជាការលាយចម្រុះគ្នានូវវប្បធម៌ដែលមានឥទ្ធិពលទាំងពីរ ។ តាមការពិតទៅវៀតណាមពីដំបូងដែលមានទីតាំងនៅក្បែរតំបន់ទន្លេក្រហម ត្រូវបានកាន់កាប់ដោយប្រទេសចិនអស់រយៈពេលមួយពាន់ឆ្នាំ ចាប់ពីសតវត្សរ៍ទី១ ដល់

សតវត្សរ៍ទី១០ ។

នៅភាគខាងលិចនៃដីសណ្ដទន្លេក្រហម គឺចម្ប៉ាដែលមានវប្បធម៌ដាច់ដោយឡែក ។ ស្ថាបត្យកម្មនៅមីសុន (My Son) និងញ៉ាចាង (Nha Trang) បានបង្ហាញឲ្យឃើញពីការប្រែប្រួលនៃឥទ្ធិពលពីដីសណ្ដទន្លេក្រហមទៅជួរភ្នំអាណាមទៅដែនដីកូសាំងស៊ីន ។ ស្ថាបត្យកម្មវៀតណាមមានលំនាំតាមបែបចិន ចំណែកឯស្ថាបត្យកម្ម ចាមមានលក្ខណៈហិណ្ឌូ ឧទ្ទិសថ្វាយដល់ព្រះសិវៈ និងវិស្ណុ ។

ភាពខុសប្លែកគ្នារវាងវប្បធម៌ទាំងពីរនេះ ត្រូវបានជំរុញដោយស្ថានភាពភូមិសាស្ត្ររបស់តំបន់ ក៏ដូចជាប្រភពដើមនៃជនជាតិទាំងពីរ ។ តំបន់ជួរភ្នំអាណាម ជាទូទៅបង្កើតបានជាតំបន់ជាច្រើនដែលមានទំនាបឆ្នេរមានដីជាតិហើយអាចឲ្យមនុស្សរស់នៅបាន ប៉ុន្តែ ស្ថានភាពភូមិសាស្ត្រនេះ ក៏ធ្វើឲ្យទំនាក់ទំនងរវាងមនុស្សនៅក្នុងតំបន់នីមួយៗមានការលំបាកផងដែរ ។ សណ្ឋានដីក៏បានកំណត់មធ្យោបាយដែលចម្ប៉ារៀបចំរចនាសម្ព័ន្ធនយោបាយ និងរបៀបគ្រប់គ្រងអាណាចក្ររបស់ខ្លួនដែរ ។

ចម្ប៉ាត្រូវបានកត់ត្រាដំបូងនៅក្នុងប្រភពជាភាសាចិនថា លីន អ៊ី (Lin Yi) ។ ប៉ុន្តែ នៅពាក់កណ្ដាលសតវត្សរ៍ទី៨ ជនជាតិចិនបានឈប់រំឭកឈ្មោះ លីន អ៊ី ទៀត ហើយជំនួសដោយហៅតំបន់នោះថា ហ៊ាន់ វ៉ាំង (Huan Hwang) ។ វាជាសហព័ន្ធមួយដែលមានតំបន់បង្រួបបង្រួមមិនសូវត្រូវគ្នាសំខាន់ៗចំនួន៥ ។ ជាច្រើនសតវត្សរ៍កន្លងមក រាជធានីរបស់ចាមបានផ្លាស់ប្ដូរពីភាគខាងជើងទៅខាងត្បូង ។ តំបន់ទាំងនេះមានជម្លោះរវាងគ្នា និងមានភាពខុសប្លែកគ្នាខ្លះៗផ្នែកវប្បធម៌ ទំនៀមទម្លាប់ និងការប្រតិបត្តិសាសនា ។ ប៉ុន្តែ ជម្លោះផ្ទៃក្នុងទាំងនេះ គឺមិនដល់ជម្លោះរវាងចម្ប៉ា និងវៀតណាមទេ ។ កម្លាំងនៃទំនាក់ទំនង និងមជ្ឈការរវាងតំបន់ទាំងនេះអាចជាកត្តារួមចំណែកដល់ការដួលរលំរបស់ចម្ប៉ាទៅក្នុងដៃរបស់វៀតណាម ។ ជម្លោះញឹកញាប់ទាំងនេះរវាងតំបន់ដែលកាត់ផ្ដាច់ពីគ្នាដោយភាពរដិបរដុបនៃដីមាត់សមុទ្រអាណាមជាមួយនឹងភ្នំខ្លះៗដែលលយចូលទៅជួរមាត់សមុទ្រទៀតនោះ ក៏បានចូលរួមចំណែកនៃការដួលរលំនេះដែរ ។

នៅក្នុងសតវត្សរ៍ទី១១ ភាពតានតឹងយ៉ាងធ្ងន់បានកើតឡើងរវាងតំបន់ភាគខាងជើង និងខាងត្បូង ។ ជាក់ស្ដែង នៅក្នុងឆ្នាំ ១០៥០ អ្នកគ្រប់គ្រងវិចាយ៉ា (Vijaya) បានបញ្ជូនកងទ័ពទៅប្រយុទ្ធប្រឆាំងនឹងតំបន់ប៉ាន់ឌូរាំងហ្គា (Panduranga) ។ ស្ដេចបន្តបន្ទាប់របស់ចម្ប៉ាចេញពីវិចាយ៉ាបានបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីបញ្ឈប់ការតស៊ូទាមទារស្វយ័តភាពរបស់តំបន់ប៉ាន់ឌូរាំងហ្គា ។

តំបន់ចាមដែលត្រូវបានគេស្គាល់មុនដំបូងបង្អស់នៅភាគខាងជើងបំផុតមានឈ្មោះថា អិនដ្រាពូរ៉ា (Indrapura) ។ តំបន់នេះមានទីតាំងនៅក្រុងវេសព្វថ្ងៃនេះរបស់វៀតណាម ។ តំបន់ទីពីរមានឈ្មោះថា អាម៉ារ៉ាវ៉ាទី (Amaravati) មានទីតាំងនៅភាគខាងត្បូងនៃអិនដ្រាពូរ៉ា នៅក្នុងខេត្តដាណាំងសព្វថ្ងៃ ។ នៅក្នុងតំបន់នេះ ស្ដេចចាមមួយអង្គ បាដ្រាវរ៉្ម័ន (Bhadravarman) បានសាងសង់ប្រាសាទបែបសាសនាហិណ្ឌូដំបូងបង្អស់ ប្រហែលជានៅក្នុងសតវត្សរ៍ទី៤ ឧទ្ទិសថ្វាយព្រះសិវៈនៅមីសុន ។ មិនយូរប៉ុន្មាន មីសុនបានក្លាយទៅជាទីសក្ការបូជារបស់ជនជាតិចាមកាន់សាសនាហិណ្ឌូដែលក្រោយមកប្រាសាទជាច្រើនទៀតត្រូវបានកសាងឡើង ។ ជាប់នឹងមីសុន គឺជាកំពង់ផែពាណិជ្ជកម្មហ័យអាន (Hoi An) ។ នេះជាមជ្ឈមណ្ឌលពាណិជ្ជកម្មសំខាន់មួយសម្រាប់ជនជាតិចាមដូចសម្រាប់ជនជាតិវៀតណាមសព្វថ្ងៃនេះដែរ ។

ប្រហែលជានៅក្នុងសតវត្សរ៍ទី៧ ប្រាសាទទីមួយឧទ្ទិសថ្វាយព្រះវិស្ណុដែលជាព្រះថែរក្សាលោក និងមេត្តាធម៌របស់សាសនាហិណ្ឌូបានលេចរូបរាងឡើងនៅមីសុន ។ ពុទ្ធសាសនាមហាយានបានចូលទៅចម្ប៉ានៅក្នុងសតវត្សរ៍ទី៩ ។ នៅខាងកើតមីសុន ស្ដេចចាមបានបោះទីតាំងរាជធានីរបស់ពួកគេ ។ រាជធានីនេះត្រូវបានវាតទីដោយវៀតណាមនៅក្នុងអំឡុងទសវត្សរ៍៩៨០ ហើយស្ដេចនៅពេលនេះត្រូវបានគេធ្វើឃាត ។ នេះគឺជាការវាយប្រហារមួយក្នុងចំណោមការវាយប្រហារដំបូងដោយជនជាតិវៀតណាម ដែលមានបំណងធ្វើដំណើរឆ្ពោះទៅទិសខាងត្បូង (ក្រោមយុទ្ធនាការណាំទៀនឆ្ពោះទៅត្បូង) បន្ទាប់ពីបានរំដោះខ្លួនពីការគ្រប់គ្រងដោយចិន ។ នៅក្នុងកិច្ចព្យាយាមឆ្ពោះទៅភាគខាងត្បូងឲ្យកាន់តែឆ្ងាយតាមដែលអាចធ្វើទៅបានដើម្បីឃ្លាតឲ្យឆ្ងាយពីចិន និងដើម្បីកាត់បន្ថយសម្ពាធនៃចំនួនប្រជាជននៅភាគខាងជើងជនជាតិវៀតណាមបានបង្កើតកម្មវិធីណាំទៀន ដែលប៉ុន្មានសតវត្សរ៍ក្រោយមកបានធ្វើឲ្យចម្ប៉ារលាយបាត់ទាំងស្រុង ។ នៅក្នុងឆ្នាំ១៤០២ ស្ដេចចាមបានប្រគល់

អាម៉ារ៉ាវ៉ាទីទៅឲ្យវៀតណាម ។

នៅក្នុងឆ្នាំ១០០០ ជនជាតិចាមបានបង្កើតរាជធានីថ្មីមានឈ្មោះថា វីចាយ៉ា ។ រាជធានីនេះ មានទីតាំងនៅក្រុងឈុយញ៉ុងឈុយ (ណាហៀន) សព្វថ្ងៃនេះ ជាកំពង់ផែមួយសំខាន់ដែរ ។ វីចាយ៉ា បានក្លាយជាមជ្ឈមណ្ឌលវប្បធម៌ និងនយោបាយរបស់ចម្ប៉ា នៅពេលដែលរាជធានីនៅភាគខាងជើង អិនដ្រាពូរ៉ា ត្រូវបោះបង់ចោលដោយសារសម្ពាធពីវៀតណាម ។ ទោះយ៉ាងណាក៏ដោយ រាជធានីថ្មីនេះ ត្រូវឈ្លានពានដោយវៀតណាមក្នុងឆ្នាំ១០៦៩ ដែលក្រោយមកបានដកចេញវិញ បន្ទាប់ពីបញ្ចូលមកក្រោមការកាន់កាប់របស់ខ្លួននូវតំបន់របស់ចម្ប៉ានៅភាគខាងជើងក្រុងវ៉េសព្វថ្ងៃ ។ យូរៗម្តង ជនជាតិចាមលើកទ័ពទៅច្បាំងនឹងវៀតណាម ។ នៅសតវត្សរ៍ទី១៤ មេទ័ពចាមម្នាក់ឈ្មោះ ឆេ បុង ង៉ា បានចូលលួចប្លន់ក្រុងហាណូយប៉ុន្មានដង និងដណ្តើមបានមកវិញនូវតំបន់របស់ចាមដែលត្រូវគេកាន់កាប់ ។ នៅក្នុងដំណាក់កាលខ្ពស់បំផុត វីចាយ៉ា បានគ្រប់គ្រងតំបន់ដែលសព្វថ្ងៃនេះជាខេត្តឈ័ងណាម (Quang Nam) ឈ័ងង៉ៃ (Quang Ngai) បិញឌិញ (Binh Dinh) និងភូយិន (Phu Yen) ។

នៅសតវត្សរ៍ទី១២ ចម្ប៉ាកំពុងមានសង្គ្រាមជាមួយប្រទេសជិតខាងទាំងពីរជាមួយប្រទេសកម្ពុជានៅភាគខាងលិច និងវៀតណាមនៅភាគខាងជើង ។ ក្នុងឆ្នាំ១១៤៥ នៅក្រោមរាជ្យព្រះបាទសូរ្យវរ្ម័នទី២ កងទ័ពខ្មែរបានឈ្លានពាន និងកាន់កាប់ចម្ប៉ាអស់រយៈពេលប៉ុន្មានឆ្នាំ ។ ប៉ុន្តែ មេទ័ពក្រោយៗរបស់ចម្ប៉ាមានភាពវៃឆ្លាតអាចរៀបចំនូវទ័ពទូកយ៉ាងខ្លាំង និងបែរប៉ុន្មានរយម៉ៃយ៍ឡើងទៅដីសណ្តទន្លេមេគង្គ និងកាត់តាមទន្លេសាប ទៅលួចប្លន់ក្រុងអង្គរនៅក្នុងឆ្នាំ១១៧៧ ។ ការបណ្តេញទ័ពទូកចាមធ្វើឡើងដោយព្រះបាទជ័យវរ្ម័នទី៧ ដែលជ័យជម្នះនេះត្រូវបានឆ្លាក់នៅប្រាសាទបាយ័នថាជាភាពជោគជ័យចម្បាំងធំបំផុតមួយរបស់ព្រះអង្គ ។ ក្រោយមកព្រះបាទជ័យវរ្ម័នទី៧ បានហ៊ុំកហ៊ុំន ព្រះអង្គម្ចាស់ចាមមួយអង្គ និងបានអនុញ្ញាតឲ្យព្រះអង្គម្ចាស់អង្គនេះដឹកនាំទ័ពទៅលុកលុយក្រុងវីចាយ៉ា សងសឹកចំពោះការវាយប្រហារក្រុងអង្គរ ។

ខ្មែរបានកាន់កាប់ចម្ប៉ារហូតដល់សតវត្សរ៍ទី១៣ ។ ការកាន់កាប់នេះបាននាំមកនូវសិល្បៈបែបឥណ្ឌា និងស្ថាបត្យកម្មមកចម្ប៉ាកាន់តែច្រើន ។ សង្គ្រាមជាមួយកម្ពុជា បានធ្វើឲ្យចម្ប៉ាចុះខ្សោយ និងងាយរងគ្រោះដោយការវាយប្រហាររបស់វៀតណាម ។ វីចាយ៉ា ត្រូវបានបាត់បង់ទៅវៀតណាមនៅក្នុងឆ្នាំ១៤៧១ ដែលបណ្តាលឲ្យមានការសម្លាប់ជនជាតិចាមរាប់ពាន់នាក់ ។ ប៉ុន្តែការធ្លាក់ចុះនេះមិនមែនជាចុងបញ្ចប់របស់ចម្ប៉ាទេ ។ គ្រួសារញាតិវង្សបាននាំគ្នាភៀសខ្លួនទៅភាគខាងត្បូងទៅកាន់តំបន់ខូសឺរ៉ា (Kauthera) និងប៉ាន់ឌូរ៉ាំងហ្គា (Panduranga) ។

ខូសឺរ៉ា មានទីតាំងនៅក្នុងតំបន់នៃខេត្តញ៉ាចាង និងខាញ់ហ័រ (Khanh Hoa) សព្វថ្ងៃនេះ ។ នៅទីនេះ ជនជាតិចាមបានកសាងប្រាសាទប៉ូណាហ្គា (Po Nagar temple) ឧទ្ទិសថ្វាយទេពធីតា និងអ្នកថែរក្សាដែនដី ។ ប្រាសាទនេះក៏ជានិមិត្តរូបនៃភាពសម្បូរដីជាតិមីសុនដែលសង់ឡើងដើម្បីឧទ្ទិសថ្វាយព្រះសិវៈជានិមិត្តរូបនៃកម្លាំង និងអំណាច ។ ប៉ុន្តែ មីសុនត្រូវបានកាន់កាប់ដោយវៀតណាមអស់រយៈពេលយ៉ាងយូរនៅមុនពេលប៉ូណាហ្គាត្រូវបានសង់ឡើង ។ ដូច្នេះ ប្រាសាទទាំងនេះបានសម្តែងឲ្យឃើញនូវការផ្លាស់ប្តូរនៃជំនឿរបស់ចាមពីការគោរពអាទិទេពបុរស មកជឿលើទេពធីតាវិញ ។ នេះជាសញ្ញាបង្ហាញដែរថា ជនជាតិចាមកំពុងតែស្វែងរកជម្រើសផ្សេងនៅក្នុងផ្នែកជំនឿ ដើម្បីជាដំណោះស្រាយចំពោះការធ្លាក់ចុះនេះ ។ ដូច្នេះព្រឹត្តិការណ៍ប្រវត្តិសាស្ត្រទាំងនេះ បង្កឲ្យមានការផ្លាស់ប្តូរសាសនារបស់ចាម ។

ប៉ាន់ឌូរាំងហ្គា មានទីតាំងនៅក្នុងតំបន់ផាន់រាំង (Phan Rang) ក្នុងខេត្តនិញធ័ន (Ninh Thuan) សព្វថ្ងៃនេះ ។ នេះជាតំបន់ចុងក្រោយដែលត្រូវបានភ្ជាប់ទៅជាទឹកដីរបស់វៀតណាម ។ តំបន់នេះស្ថិតនៅឆ្ងាយបំផុតពីកន្លែងកាន់អំណាចវីចាយ៉ា និងមិនត្រូវបានគ្រប់គ្រងឲ្យបានជិតដល់ពីរាជធានីទេ ។ ប៉ុន្តែ តំបន់នេះជាជម្រកដ៏មានប្រយោជន៍សម្រាប់ទ័ពចាមដែលជាធម្មតាតែងតែភៀសខ្លួនទៅភាគខាងត្បូងបន្ទាប់ពីចាញ់ដៃវៀតណាម ។ នៅពាក់កណ្តាលសតវត្សរ៍ទី១២ នៅពេលដែលកងទ័ពខ្មែរដឹកនាំដោយសូរ្យវរ្ម័នទី២ កាន់កាប់ចម្ប៉ាភាគខាងជើងប៉ាន់ឌូរាំងហ្គាបានផ្តល់ជម្រកដល់ស្តេចចាមដែលភៀសខ្លួនទៅភាគខាងត្បូង ។

**មេទ័ពចាមដ៏អស្ចារ្យ ឆេ បុង ង៉ា**

កម្ពុជាមានមហាក្សត្រ និងមេទ័ពដ៏អស្ចារ្យ គឺព្រះបាទជ័យ

វរ្ម័នទី៧ ដែលកាន់អំណាចពីឆ្នាំ១១៨១ ដល់១២០០ និងបានសងសឹកចំពោះការឈ្លានពានរបស់ចាមមកលើក្រុងអង្គរ នៅក្នុងឆ្នាំ១១៧៧ ។ ប៉ុន្តែ ពីរសតវត្សរ៍ក្រោយមក ចម្ប៉ាមានស្តេចឈ្មោះ ឆេ បុង ង៉ា ដែលកាន់អំណាចពីឆ្នាំ១៣៦០ ដល់១៣៩០ ។ នេះគឺជាស្តេច "អស្ចារ្យ" ចុងក្រោយបង្អស់របស់ចម្ប៉ា ។ ឆេ បុង ង៉ា មិនដែលបង្កការភ័យខ្លាចដល់កម្ពុជាទេ ក្រៅពីការបង្អាក់ពីរបីដងនៅពេលកម្ពុជាថ្វាយសួយសារអាករទៅស្តេចរាជវង្សមិញរបស់ចិន ។ នៅក្នុងឆ្នាំ១៣៨៧ ឆេ បុង ង៉ា បានដកទុកមួយភាគបួននៃដំរីដែលបញ្ជូនពីកម្ពុជា កាត់តាមចម្ប៉ាទៅឲ្យចិន ។

ដោយគុណសម្បត្តិពិសេសក្នុងនាមជាអ្នកចម្បាំង និងលទ្ធភាពក្នុងការប្រើប្រាស់របស់នៅជុំវិញខ្លួនជាប្រយោជន៍ដើម្បីទទួលជ័យជម្នះនៅលើសមរភូមិ ឆេ បុង ង៉ា បានផ្តោតកម្លាំងរបស់ខ្លួនប្រឆាំងនឹងបច្ចាមិត្តនៅភាគខាងជើង ។ ស្តេចអង្គនេះក៏បានសម្តែងឲ្យឃើញនូវជំនាញការទូតយ៉ាងពិសេស ក្នុងការបញ្ចៀសការលូកដៃរបស់ចិនចូលមកក្នុងសង្គ្រាមឥតឈប់ឈរជាមួយអាណាម ។ ការបរិយាយរបស់វៀតណាម បានចាត់ទុកស្តេចអង្គនេះថា ជាស្តេចបោកប្រាស់ដែលកាឡៃការពិតដើម្បីជាប្រយោជន៍របស់ខ្លួន និងលេងឆាកល្ខោនជាមួយស្តេចរាជវង្សមិញ យ័ន ចាង (*Yuan Chang*) ។ ឆេ បុង ង៉ា សុគតនៅក្នុងសមរភូមិនៅឆ្នាំ១៣៩០ ។ ការសុគតនេះ បណ្តាលឲ្យចម្ប៉ាធ្លាក់ចុះខ្សោយជាបន្តបន្ទាប់ ដែលនេះជាប្រយោជន៍របស់អាណាមដែលបានពង្រីកទឹកដីឆ្ពោះទៅភាគខាងត្បូងចាប់ពីសតវត្សរ៍ទី១៥ និងចុងក្រោយបង្អស់រំលាយចម្ប៉ាទាំងស្រុងតែម្តងនៅចុងសតវត្សរ៍ទី១៩ ។

នៅក្នុងអំឡុងនៃការកាន់អំណាចរយៈពេល៣០ឆ្នាំរបស់ស្តេចអង្គនេះ ដែលគេហៅថាសង្គ្រាមរយៈពេល៣០ឆ្នាំរវាងចម្ប៉ា និងអាណាម អាណាមទទួលរងនូវបរាជ័យ និងភាពអាម៉ាស់ជាច្រើនដងនៅក្រោមដៃរបស់ ឆេ បុង ង៉ា ។ នៅឆ្នាំ១៣៦១ ឆេ បុង ង៉ា បានធ្វើការឈ្លានពានកំពង់ផែភាគខាងត្បូងរបស់ ដា លី របស់អាណាម លួចប្លន់ទីក្រុងនេះ សម្លាប់រង្គាលប្រជាជន និងបានវិលត្រឡប់ទៅសមុទ្រវិញជាមួយនឹងជ័យភណ្ឌ ។ នៅពេលវៀតណាមឆ្លើយតបវិញតាមរយៈបេសកម្មតូចមួយប្រឆាំងនឹងតំបន់ភាគខាងជើងរបស់ចម្ប៉ានៅខែមករា ឆ្នាំ១៣៦៨ ឆេ បុង ង៉ា បានលាក់កងទ័ពរបស់គាត់នៅក្នុងកន្លែងមួយដែលគេហៅថា រូងចាម ដើម្បីលួចវាយប្រហារកងទ័ពវៀតណាម ។ ពួកគេទទួលបានជ័យជម្នះ និងបានចាប់មេទ័ពដឹកនាំបេសកម្មនោះជាអ្នកទោស ។

នៅក្នុងអំឡុងពេលនៃការគ្រប់គ្រងរបស់គាត់ ឆេ បុង ង៉ា មិនដែលខកខានបញ្ជូនសួយសារអាករយ៉ាងច្រើនទៅស្តេច យ័ន ចាង ទេ បើទោះបីរបស់នោះជាជ័យភណ្ឌសង្គ្រាម របស់របរលួចពីគេ ឬរបស់ពីប្រទេសរបស់គាត់ ។ នៅក្នុងឆ្នាំ១៣៦៩ ឆេ បុង ង៉ា



ជនជាតិចាម នៅភូមិកោះគរ ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម (បច្ចុប្បន្ន ខេត្តត្បូងឃ្មុំ)

បានបញ្ជូនសត្វដំរី ខ្លា និងផលិតផលពីព្រៃ ទៅឲ្យស្តេច យ័ន ចាង ដែលឡើងគ្រងរាជ្យនៅក្នុងឆ្នាំនោះ ។ យ័ន ចាង សប្បាយចិត្តនឹងការសម្តែងការចុះចូលនេះ ។ យ័ន ចាង បានផ្ញើញត្តិមួយទទួលស្គាល់ ឆេ បុង ង៉ា ថាជា«ស្តេច របស់ចម្ប៉ា ត្រាមួយ ប្រតិទិនចំនួន៣ពាន់ និងសូត្រចម្រុះពណ៌ចំនួន៤០ដុំ» ។ នៅក្នុងឆ្នាំ១៣៨៦ កូនប្រុសៗរបស់ ឆេ បុង ង៉ា បានថ្វាយ យ័ន ចាង នូវសត្វដំរីចំនួន៤៤ និងក្នុង

ឆ្នាំ១៣៨៧ សត្វដំរីចំនួន៥១ ខ្ទឹមចន្ទន៍ និងកុយរមាស ។

នៅក្នុងឆ្នាំ១៣៧១ ឆេ បុង ង៉ា បានទទួលព័ត៌មានសម្ងាត់អំពីរបនាសម្ព័ន្ធការពារជាតិរបស់អាណាម ពីមាត់របស់អតីតស្តេចអាណាមម្នាក់ ដែលបានជ្រកកោននៅចម្ប៉ាបន្ទាប់ពីមានជម្លោះរាជវង្ស ។ បន្ទាប់មក ព្រះអង្គបានធ្វើដំណើរតាមទូកទៅកាន់រាជធានីរបស់អាណាម និងបានចូលតាមកំពង់ផែដៃអាន (*Dai An*) ។ ដោយសារការមកដល់របស់ព្រះអង្គមានភាពស្ងៀមស្ងាត់ ព្រះអង្គ



បានកាន់កាប់រាជធានីនេះយ៉ាងងាយស្រួល ។ កងទ័ពរបស់ព្រះអង្គ "បានចាប់យកស្ត្រីក្មេងៗ ដកហូតត្បូង និងសម្លៀកបំពាក់មានតម្លៃ ដុតកម្ទេចរាជវាំង ដុតបំផ្លាញបណ្ណសារ និងរបស់ទាំងឡាយដែលចាក់សោទុកនៅទីនោះ" ។ ប៉ុន្តែ ដោយយល់ឃើញថាការវាយប្រហារនោះមិនមែនបង្កហេតុឡើងដោយភាគីមួយទៀតនោះ ឆេ បុង ង៉ា បានផ្ញើលិខិតមួយជូនចិន ដើម្បីយកចិត្តព្រះចៅអធិរាជដែលបានស្នើឲ្យប្រទេសទាំងពីររស់នៅក្បែរគ្នាដោយសន្តិភាពៈ "ថ្ងៃនេះ អាណាមបានលើកទ័ពមកដណ្តើមទឹកដីរបស់ខ្ញុំ និងបានលួចប្លន់ប្រជាជននៅទីនោះ ។ ដូច្នេះ ខ្ញុំមកស្នើសុំឲ្យព្រះចៅអធិរាជផ្តល់សម្ភារយោធា សម្ភារភ្លេង និងអ្នកភ្លេង ។ ដូច្នេះ អាណាមនឹងមើលឃើញថា រាជាណាចក្រចម្ប៉ារបស់ខ្ញុំគឺជាប្រទេសចំណុះឲ្យព្រះចៅអធិរាជ និងមិនហ៊ានរំលោភបំពានទេ" ។ យ៉ែន ចាង ប្រហែលជាបានស្វែងយល់អំពីភាពមិនប្រក្រតីនៃលិខិតនេះ មិនបានផ្ញើអ្វីមកឲ្យ ឆេ បុង ង៉ា ទេ និងបានស្នើឲ្យប្រទេសជិតខាងទាំងពីរដកទ័ពរៀងៗខ្លួនវិញ ។

នៅក្នុងឆ្នាំ១៣៧៣ ឆេ បុង ង៉ា បានបន្ថែមសួយសារអាករថែមទៀតឲ្យទៅចិន នៅក្នុងកិច្ចប្រឹងប្រែងមួយដើម្បីបំបាត់ចោរសមុទ្រពីសមុទ្រចិនខាងត្បូង ដែលបានគំរាមកំហែងដល់បណ្តាញទំនាក់ទំនង និងពាណិជ្ជកម្មរវាងប្រទេសចិន និងប្រទេសផ្សេងៗ ។ ឆេ បុង ង៉ា បានតាមរកចោរសមុទ្រទាំងនេះ ចាប់បានខ្លះ សម្លាប់នាវិកចោល និងដកហូតកប៉ាល់ចំនួន២០ និងឈើមានតម្លៃចំនួន៧ម៉ឺនផោន ។ ឆេ បុង ង៉ា បានប្រគល់របស់ទាំងអស់នេះឲ្យទៅ យ៉ែន ចាង ដែលមានការសប្បាយចិត្តយ៉ាងខ្លាំងចំពោះការសម្តែងការចុះចូលសហប្រតិបត្តិការ និងមានប្រយោជន៍ចំពោះប្រទេសចិន ។ យ៉ែន ចាង បានផ្តល់អំណោយច្រើនដល់ចម្ប៉ា ខុសពីទម្លាប់កន្លងមកនៅក្នុងវាំងចិន ។ បើទោះបីជា ឆេ បុង ង៉ា មានជំនាញយោធាគ្រប់គ្រាន់ដើម្បីការពារប្រទេសខ្លួន និងដើម្បីឈ្លានពានអាណាមក៏ដោយ ឆេ បុង ង៉ា មានអារម្មណ៍ថា វាមានសារសំខាន់ក្នុងការផ្តល់ព័ត៌មានទាំងពិត និងកុហក ទៅប្រទេសចិនអំពីទំនាក់ទំនងរបស់ចម្ប៉ាជាមួយអាណាម ។ ការនេះនឹងអាចជួយរារាំងនូវការយល់ច្រឡំរវាងចិន និងចម្ប៉ាដែលថា ដោយការឈ្លានពានអាណាម ចម្ប៉ាមិនមែនប្រឆាំងនឹងឆន្ទៈរបស់ចិនដែលចង់ឲ្យមានសន្តិភាពក្នុងចំណោមរដ្ឋចំណុះរបស់ខ្លួនទេ ។ យ៉ែន ចាង បានសរសេរថាៈ "មហាក្សត្រត្រូវដាក់កម្រិតខ្លួនឯងនៅត្រឹមការពារព្រំដែនរបស់ខ្លួន និងផ្តល់សន្តិភាពដល់ប្រជាជន ។ មានតែតាមរយៈការធ្វើបែបនេះទេ ទើបក្សត្រទាំងនេះមានសេចក្តីសប្បាយរីករាយល្អឥតខ្ចោះ ។ ប្រើចុងអាវុធនៅក្នុងយុទ្ធនាការ និងធ្វើសង្គ្រាមគួរឲ្យភ័យខ្លាច គឺកំពុងតែលេងល្បែងដ៏គ្រោះថ្នាក់ ព្រោះជ័យជម្នះដូចបរាជ័យ ដែរ គឺជារឿងមិនប្រាកដទេ" ។

នៅចុងឆ្នាំ១៣៧៣ នៅពេលដែលស្តេចអាណាមបង្កើន

អាវុធដោយកសាងកប៉ាល់សង្គ្រាម ឆេ បុង ង៉ា បានបញ្ជូនលិខិតមួយទៅប្រទេសចិន ប្រាប់ព្រះចៅអធិរាជអំពីលទ្ធភាពនៃការវាយប្រហារដោយអាណាម ។ ប៉ុន្តែ ប្រទេសចិនគ្រាន់តែសុំឲ្យប្រទេសទាំងពីររស់នៅដោយសន្តិភាពប៉ុណ្ណោះ ។

នៅក្នុងឆ្នាំ១៣៧៧ ពីររយឆ្នាំគត់បន្ទាប់ពីជ័យជម្នះរបស់ចម្ប៉ានៅអង្គរ ឆេ បុង ង៉ា បានធ្វើការវាយប្រហារតបយ៉ាងធ្ងន់ប្រឆាំងនឹងអាណាម ។ អាណាមបានត្រៀមធ្វើសង្គ្រាមជាមួយចម្ប៉ាតាំងពីឆ្នាំ១៣៧៣ និងបានត្រៀមខ្លួនរួចជាស្រេចដើម្បីប្រយុទ្ធគិតត្រឹមឆ្នាំ១៣៧៧ ។ ស្តេចអាណាមឈ្មោះ ខាំ ហ័ង (Kham Hoang) បានដឹកនាំទ័ពមានចំនួន១សែន២ម៉ឺនឆ្ពោះទៅចម្ប៉ាតាមឆ្នេរសមុទ្រ ។ ឆេ បុង ង៉ា បានផ្ញើសំណូកទៅឲ្យមេទ័ពអាណាម ប៉ុន្តែត្រូវគេចាប់បាន ។ នេះប្រហែលជាការសម្តែងឲ្យឃើញអំពីការភ័យខ្លាចៈ កលល្បិចដែលធ្វើឲ្យអាណាមជឿថា ចម្ប៉ាមានការភ័យខ្លាច និងមិនអាចតបតទៅនឹងកងទ័ពទ្រង់ទ្រាយធំដែលកំពុងតែធ្វើដំណើរឆ្ពោះទៅកាន់វីចាយ៉ា ។ កងទ័ពទាំងនេះ បោះជំរំនៅខាងក្រៅវីចាយ៉ា ដែលត្រូវការពារដោយរបងយ៉ាងរឹងមាំ ត្រៀមចាំឱកាសល្អដើម្បីធ្វើការវាយប្រហារលើរាជធានីចាមនេះ ។ ជាថ្មីម្តងទៀត ចាមម្នាក់ដែលប្រហែលជាបញ្ជូនទៅដោយ ឆេ បុង ង៉ា បានទូលថ្វាយ ខាំ ហ័ង ថា រាជធានីនេះលែងមានមនុស្សហើយ និងថា ឆេ បុង ង៉ា កំពុងភៀសខ្លួន ។ ប្រសិនបើការវាយប្រហារធ្វើដោយប្រញាប់នោះ ឆេ បុង ង៉ា ប្រហែលជាអាចត្រូវបានចាប់ខ្លួនយ៉ាងងាយ ។ ដោយមិនបានផ្ទៀងផ្ទាត់ព័ត៌មាននេះ និងជំទាស់ទៅនឹងយោបល់របស់មេទ័ពជំនិតៗរបស់ព្រះអង្គ ខាំ ហ័ង បានដឹកនាំទ័ពឆ្ពោះទៅវីចាយ៉ា ។ ការដឹកនាំទ័ពនេះត្រូវជួបប្រទះនឹងការលបវាយឆ្មក់ ហើយទ័ពរបស់ព្រះអង្គត្រូវបានសម្លាប់យ៉ាងរង្គាល ។ នៅក្នុងភាពចលាចលនៅពេលនោះ ខាំ ហ័ង ត្រូវធ្វើគតបន្ទាប់ពីធ្លាក់ពីលើខ្នងសេះ ។ ឆេ បុង ង៉ា បានយកជ័យជម្នះលើទ័ពដែលនៅសេសសល់ ហើយភ្លាមនោះបានដឹកនាំនាវាចម្បាំងឆ្ពោះទៅដីសណ្តទន្លេក្រហម ដើម្បីធ្វើការវាយប្រហារលើរាជធានីរបស់អាណាម ។ ឆេ បុង ង៉ា បានឆ្លងផុតរបាំងទ័ពការពារ និងចូលទៅកាន់រាជធានីដោយមានការប្រឆាំងតបតិចតួចប៉ុណ្ណោះ ។ រាជធានីនោះត្រូវដុតបំផ្លាញ និងលួចប្លន់ ។ ជោគជ័យនេះបានបង្កនូវការភ័យខ្លាច ឆេ បុង ង៉ា នៅក្នុងចំណោមប្រជាជនអាណាម ។

នៅក្នុងឆ្នាំ១៣៨៣ ឆេ បុង ង៉ា បានរៀបចំផែនការធំមួយដើម្បីធ្វើការវាយប្រហាររាជធានីអាណាមចេញពីជួរភ្នំនៅភាគខាងជើងនៃដីសណ្តទន្លេក្រហម ។ ផែនការនេះបានក្លាយជាពិតបន្ទាប់ពីកងទ័ពរបស់គាត់ត្រូវបានលួចវាយឆ្មក់នៅជ្រោះមួយនៅចន្លោះថាញ់ហ័រ (Thanh Hoa) និង និញបិញ (Ninh Binh) ក៏ដូចជាទទួលបានជោគជ័យនៅលើផ្ទៃសមុទ្រ ។ កងទ័ពរបស់ ឆេ បុង ង៉ា បានផុសឡើងនៅភាគខាងជើងរាជធានី ។ គាត់ទទួលបានជ័យជម្នះលើកងទ័ពអាណាមនៅទីនោះ បង្កឲ្យមានភាពភ័យខ្លាចនៅក្នុងចំណោមប្រជាជន និងបានដកទ័ពវិញនៅក្នុងឆ្នាំ១៣៨៤ ។

ប្រហែលជានៅឆ្នាំ១៣៩០ ឆេ បុង ង៉ា ទទួលបានជោគជ័យមួយយ៉ាងធំទៅលើអាណាម ។ នេះគឺជាការវាយបកលើការលុកលុយរបស់អាណាមមកកាន់តំបន់ភាគខាងជើងរបស់ចម្ប៉ា ។ ឆេ បុង ង៉ា បានរៀបចំការលួចវាយឆ្មក់ទ័ពអាណាមដែលដឹកនាំដោយ ឡេ ឈួយលី (Le Qui Ly) ដែលបោះជំរំនៅច្រកទន្លេដែលហូរចូលសមុទ្រដែលមានការការពារដោយកប៉ាល់នៅតាមឆ្នេរ ។ ប៉ុន្តែ ឆេ បុង ង៉ា លាក់ទ័ព និងសត្វដំរីយ៉ាងសម្ងាត់នៅភាគខាងលើទន្លេ និងកាន់កាប់ទំនប់នៅទីនោះ ។ ឆេ បុង ង៉ា បានបើកទំនប់ទឹកបំផ្លាញកប៉ាល់ជាច្រើន និងបានសម្លាប់កងទ័ពជាច្រើនរបស់ ឡេ ឈួយលី ដែលកងទ័ពទាំងនេះ មិនបានជោគជ័យក្នុងការព្យាយាមលើកទីមួយក្នុងការកំណត់ទីតាំង និងកម្ទេចទ័ពរបស់ ឆេ បុង ង៉ា នៅក្នុងព្រៃ ។ ឆេ បុង ង៉ា តាមកម្ទេចទ័ពដែលនៅសេសសល់រហូតទៅដល់ដីសណ្តទន្លេក្រហម បង្កភាពភ័យខ្លាចនៅក្នុងរាជធានី ។ ចច ម៉ាស្ពឺរ៉ូ (George Maspero) បានសរសេរថា “ភាពភ័យខ្លាចដែលបង្កដោយស្តេចចាម និងកងទ័ពរបស់ស្តេចនេះ គឺមានសភាពខ្លាំងមែនទែនរហូតដល់ពេលដែលមេទ័ពនេះចូលបង្គំគាល់ព្រះចៅចាស់ មេទ័ពនេះមិនអាចទប់ទឹកភ្នែកបានបើទោះបីជាមានភាពក្លាហានយ៉ាងណាក៏ដោយ ហើយស្តេចអាណាមអង្គនេះក៏បង្ហូរទឹកភ្នែកដែរ” ។ ប៉ុន្តែ ទាហានរត់ចោលជួរម្នាក់របស់ ឆេ បុង ង៉ា បានទម្លាយព័ត៌មានសំខាន់អំពីនាវារបស់ ឆេ បុង ង៉ា ។ ទាហានរត់ចោលជួរម្នាក់នេះបានប្រាប់មេទ័ពអាណាមថា “នាវារបស់ស្តេចចម្ប៉ា ងាយចំណាំជាងគេដោយសារមានរចនាពណ៌បៃតង” ។ នាវាវៀតណាមបានផ្តោតការវាយប្រហារ

លើនាវានោះ រហូតដល់អាចធ្វើគត និងកាត់ព្រះកេសរបស់ ឆេ បុង ង៉ា នៅលើនាវានោះ ។

## ២) បែបបទក្នុងការផ្លាស់ប្តូរទីលំនៅរបស់ជនជាតិចាមមកកម្ពុជា

ជនជាតិចាម និងម៉ាឡេ បានរស់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេលប៉ុន្មានរយឆ្នាំមកហើយ ។ ជនជាតិម៉ាឡេ មកដល់កម្ពុជាតាមរយៈការធ្វើពាណិជ្ជកម្ម និងបានមកដល់ប្រទេសកម្ពុជាមុនការមកដល់របស់ជនជាតិចាម ។ ជនជាតិម៉ាឡេ ជួនកាលត្រូវបានគេហៅថា ជ្វា ដែលមកពីបណ្តុំកោះនៅប្រជុំកោះ ឥណ្ឌូនេស៊ី,ម៉ាឡេស៊ី ជាពិសេសពីកោះជ្វា និងឧបទ្វីបម៉ាឡេស៊ី ។ ជនជាតិម៉ាឡេគឺជាមូស្លីមទៅហើយ នៅពេលមកដល់កម្ពុជានោះ ។ ក្នុងនាមជាពាណិជ្ជករមូស្លីម ពួកគេទាញយកផលប្រយោជន៍ពីបណ្តាញពាណិជ្ជករមូស្លីមដែលនៅតាមបណ្តុំកោះ និងនៅអាស៊ីអាគ្នេយ៍ ដោយផ្តោតសំខាន់ទៅលើការទុកចិត្តគ្នានៅក្នុងចំណោមបងប្អូនមូស្លីមដូចគ្នា ។

ជនជាតិចាមមកដល់កម្ពុជាជាលើកដំបូងក្នុងឆ្នាំ១៤៧១ នៅពេលប្រទេសកំណើតរបស់ចម្ប៉ា ត្រូវបានកាន់កាប់ដោយវៀតណាម ។ ពួកគេបន្តផ្លាស់ទីលំនៅមកកាន់កម្ពុជាជាដំណាក់កាល។ អាស្រ័យទៅលើជម្លោះរវាងចម្ប៉ា និងវៀតណាម ។ ការកាន់កាប់ចម្ប៉ាដោយវៀតណាមពេញលេញនៅពាក់កណ្តាលសតវត្សរ៍ទី១៩ នៅពេលដែលជនជាតិចាមដំណាក់កាលចុងក្រោយ ដែលរួមទាំងសមាជិកញាតិវង្ស បានភៀសខ្លួនមកកម្ពុជា ។

វិល្លៀម ខូលីន *(William Collins)* បានកំណត់នូវដំណាក់កាលសំខាន់ៗចំនួន៤នៃការផ្លាស់ប្តូរមកប្រទេសកម្ពុជាដែលកើតឡើងនៅក្នុងឆ្នាំ១៤៧១, ១៦៩២, ១៧៩៥-៩៦ និង១៨៣០-៣៥ ។ នៅក្នុងចន្លោះដំណាក់កាលទាំងនេះ គឺជាលំហូរចូលនូវជនជាតិចាមជាបន្តបន្ទាប់មកកាន់កម្ពុជា ប៉ុន្តែមានចំនួនទាបនៅក្នុងអំឡុងពេលដែលមិនសូវមានសារសំខាន់ផ្នែកប្រវត្តិសាស្ត្រ ។ ការដួលរលំនៃក្រុងវីចាយ៉ា នៅក្នុងឆ្នាំ១៤៧១ ទៅវៀតណាមប្រហែលជាបង្កឲ្យញាតិវង្សភៀសខ្លួនទៅជាមួយជនជាតិចាមធម្មតាតាមទិសដៅផ្សេងៗ ។ ក្រុមចាមដំបូងដែលភៀសខ្លួនទៅទិសខាងត្បូងទៅកាន់តំបន់ភាគខាងត្បូង ក្លាយទៅជាជនភៀសសឹកនៅក្នុងប្រទេស ។ ក្រុមនេះមានទាំងអ្នកកាន់សាសនាហិណ្ឌូ និងអ៊ីស្លាម ។ ក្រុមទីពីរបានធ្វើនាវាចរណ៍ទៅតំបន់ប្រជុំកោះ និងបានបោះទីលំនៅនៅម៉ាឡាកា ។ ក្រុមនេះមានអ្នកធ្វើជំនួញតាមសមុទ្រ ដែលមានទំនាក់ទំនងយូរមកហើយជាមួយជនជាតិម៉ាឡេនៅម៉ាឡាកា និងផ្សាយរកបានកប៉ាល់ ។ ក្រុមទីបីធ្វើដំណើរទៅទិសខាងលិច កាត់តាមជួរភ្នំអាណាម ទៅកាន់ប្រទេសកម្ពុជាដែលនៅជិតខាង ។ ក្រុមនេះក៏ធ្វើដំណើរទៅកម្ពុជាតាមកប៉ាល់ និងបន្ទាប់មក បើកឡើងទៅដីសណ្តទន្លេមេគង្គទៅកាន់ចូវដុក បន្ទាប់មកទៅទិសខាងជើងតាមបណ្តោយទន្លេបាសាក់ ទៅកាន់រាជធានីកម្ពុជា នៅឧដុង្គ ។

ការកាន់កាប់ក្រុងវីចាយ៉ាដោយវៀតណាម កើតឡើងទន្ទឹមនឹងពេលធ្លាក់ចុះនៃប្រទេសកម្ពុជា បន្ទាប់ពីសម័យចក្រភពអង្គរ ។ ប្រទេសកម្ពុជាខ្លួនឯងកំពុងស្ថិតនៅក្រោមការគំរាមកំហែងពីជនជាតិថៃនៅខាងលិច ។ នៅពេលដែលជនជាតិចាមភៀសខ្លួនមកដល់កម្ពុជា ប្រទេសនេះបានផ្លាស់ប្តូររាជធានី មកកាន់ឧដុង្គរួចហើយ ។ នៅក្នុងចំណោមក្រុមនេះ គឺជាអ្នកកាន់សាសនាអ៊ីស្លាម ក៏ដូចជាអ្នកកាន់សាសនាហិណ្ឌូ ដែលមានចំណេះដឹងខាងធ្វើកាំភ្លើងមកពីការធ្វើទំនាក់ទំនងជាមួយអ្នកជំនួញកាន់សាសនាអ៊ីស្លាម នេះអាចជាហេតុផលមួយដែលក្រុមនេះ ទទួលបានការស្វាគមន៍នៅក្នុងប្រទេសកម្ពុជា ។ ជនជាតិចាមជួបជនជាតិជ្វាកាន់សាសនាអ៊ីស្លាមដែលមករស់នៅកម្ពុជាយូរមុនការមកដល់របស់ជនជាតិចាម ។

រយៈពេលពិតប្រាកដដែលជនជាតិម៉ាឡេ និងជ្វា មកដល់នៅកម្ពុជាមិនទាន់ត្រូវបានកំណត់ទេ ។ ទាំងជ័យវរ្ម័នទី២ និងជ័យវរ្ម័នទី៧ បានចំណាយពេលនៅក្រៅប្រទេសនៅក្រុងស្រីវិជ្ជ័យ *(Srivijaya)* ។ ដោយសារព្រះរាជាពីរអង្គនេះក្រោយមកបានក្លាយជាព្រះរាជាកម្ពុជា ដែលទំនងជាព្រះអង្គទាំងពីរបាននាំមកជាមួយនូវទំនៀមទម្លាប់សិល្បៈគ្រប់គ្រងរដ្ឋាភិបាល និងការទូត និងចំណេះដឹងផ្សេងទៀត ទាក់ទងនឹងរដ្ឋាភិបាល និងសង្គ្រាមរបស់ជ្វានិងម៉ាឡេ នៅពេលព្រះអង្គត្រឡប់មកកម្ពុជាវិញ ។ វាមានភាពងាយស្រួលសម្រាប់ជនជាតិម៉ាឡេ និងជ្វា ដែលតាំងទីលំនៅនៅកម្ពុជា និងបានផ្តល់ការគាំទ្របន្ថែមទៀតដល់ព្រះរាជា ។ ជាងនេះទៅទៀត វាមានភាពងាយស្រួលសម្រាប់ជនជាតិម៉ាឡេ និងជ្វា ក្នុងការបើកកប៉ាល់ឡើងតាមទន្លេមេគង្គទៅកម្ពុជា និងបោះទីលំនៅនៅលើដីសណ្តទន្លេមេគង្គ ។

ប្រជាជនម៉ាឡេ-ជ្វាទាំងនេះប្រហែលជាអាចមកដល់កម្ពុជាមុនសតវត្សរ៍ទី១៤ ។ ដោយសារតែពួកគេទាំងនោះជា

អ្នកកាន់សាសនាអ៊ីស្លាម និងដោយសារតែស៊ូម៉ាត្រាទើបតែនឹងប្តូរទៅកាន់សាសនាអ៊ីស្លាមនៅដើមសតវត្សរ៍ទី១៣ ជនជាតិម៉ាឡេគួរតែបានចាកចេញទៅកាន់កម្ពុជាបន្ទាប់ពីដំណាក់កាលនេះ ។ មិនយូរប៉ុន្មានក្រោយមក ជនជាតិជ្វាបានទៅតាម ។ ក្រោយមក ជនជាតិម៉ាឡេ និងជ្វា បានក្លាយជាក្រុមតែមួយដែលគេស្គាល់ថា ជ្វា ។

ការផ្លាស់ទីលំនៅធំទីពីររបស់ជនជាតិចាមមកកម្ពុជា ធ្វើឡើងនៅប្រហែលជាឆ្នាំ១៦៩២ ។ គិតត្រឹមពេលនេះ វៀតណាមបានគ្រប់គ្រងដីសណ្តទន្លេមេគង្គ រួចហើយកាត់ផ្តាច់ទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជា ។ ចម្ប៉ា ក៏បានរួមតូចមកនៅត្រឹមតែមុំតំបន់ប៉ាន់ឌូរ៉ាំងហ្កា ដែលព័ទ្ធជុំវិញទៅដោយប្រទេសផ្សេង ។ គិតដល់ត្រឹមចុងសតវត្សរ៍ទី១៧ ឥទ្ធិពលរបស់ម៉ាឡេ និងសាសនាអ៊ីស្លាម បានចាក់ចូលយ៉ាងជ្រៅទៅក្នុងតំបន់ប៉ាន់ឌូរ៉ាំងហ្កា ដែលប្រជាជននៅទីនោះក្នុងចំនួនធំប្រហែលជាបានប្តូរទៅកាន់សាសនាអ៊ីស្លាម ប៉ុន្តែ នៅថែរក្សាជំនឿកាលពីមុនពេលប្តូរទៅសាសនាអ៊ីស្លាមដដែល ។ នៅពេលនេះដែរ ភាសាម៉ាឡេបានក្លាយជាភាសាអន្តរជាតិនៅក្នុងចំណោមអ្នកជំនួញនៅអាស៊ីអាគ្នេយ៍ ។ ចំណាត់ការចុងក្រោយរបស់វៀតណាមក្នុងការភ្ជាប់ប៉ាន់ឌូរ៉ាំងហ្កា បន្ទាប់ពីបរាជ័យរបស់ចាមក្នុងការដណ្តើមមកវិញនូវខូសឺរ៉ា បានបណ្តាលឲ្យមានបំលាស់ទីលើកទីពីររបស់ជនជាតិចាម ។ មនុស្សប្រហែលប្រាំពាន់នាក់ បានធ្វើដំណើរមកដឹកនាំដោយសមាជិកញាតិវង្ស ។ វាប្រហែលជានៅក្នុងរាជវង្សរបស់ព្រះបាទជ័យជេដ្ឋាទីបី (១៦៧៧-១៧០៩) ។ ទាំងនេះគឺជាអ្នកដែលត្រូវបានចុះនៅក្នុងពង្សាវតារខ្មែរ ប៉ុន្តែ ជនជាតិចាមសាមញ្ញទំនងជាមកដល់នៅឆ្នាំក្រោយមកៗប៉ុណ្ណោះ ។

ជនភៀសខ្លួនចាមត្រូវបានអនុញ្ញាតឲ្យបោះទីលំនៅនៅតំបន់ជាច្រើនក្នុងប្រទេសកម្ពុជា ។ ក្រុមចាមដំបូងបោះទីលំនៅនៅជុំវិញរាជធានីឧដុង្គ ។ ក្រុមនេះរួមមានសមាជិកញាតិវង្សចាមរបស់ស្តេចនៅប៉ាន់ឌូរ៉ាំងហ្កា ។ ក្រុមទីពីរបោះទីលំនៅនៅត្បូងឃ្មុំនៅក្នុងខេត្តកំពង់ចាម នៅភូមិភាគកណ្តាលកម្ពុជាសព្វថ្ងៃនេះ ។ ជនជាតិចាមនៅតំបន់នេះមានចំនួនច្រើនណាស់រហូតដល់ខេត្តនេះត្រូវបានឲ្យឈ្មោះជាភាសាម៉ាឡេថា កំពង់ចាម ។ កំពង់ចាមមានន័យថា ជាកំពង់របស់ចាម (វាមានទីតាំងនៅតាមដងទន្លេមេគង្គ) ។ ក្រុមទីបីបោះទីលំនៅតាំងនៅតាមដងទន្លេមេគង្គ ក្បែរភ្នំពេញសព្វថ្ងៃនេះ ។ ក្រោយមក ប្រជាជនទាំងនេះ បានរៀនជំនាញយ៉ាងពូកែខាងផ្នែកនេសាទ ។

ចំណាកស្រុកលើកទីបីមកកាន់កម្ពុជា កើតឡើងក្នុងឆ្នាំ ១៧៩៥-១៧៩៦ ។ វាកើតឡើងនៅអំឡុងពេលនៃការបះបោរទីសុន (Ty Son) នៅក្នុងចំណោមក្រុមជម្លោះវៀតណាមផ្សេងៗដែលបណ្តាលឲ្យមានសង្គ្រាមនៅប៉ាន់ឌូរ៉ាំងហ្កា ។ ចំនួនមនុស្សចំណាកស្រុកលើកនេះ គឺមិនច្បាស់លាស់ទេ ប៉ុន្តែ ភាគច្រើនអ្នកទាំងនេះជាអ្នកកាន់សាសនាអ៊ីស្លាម និងត្រូវបានដឹកនាំដោយ ទួន សេត អាសមិត (Set Asmit) ។ នៅប្រទេសកម្ពុជានៅអំឡុងពេលនេះ សៀមបានដាក់ព្រះបាទ អង្គអេង (១៧៩៤-១៧៩៦) ឲ្យឡើងគ្រងរាជ្យនៅកម្ពុជា និងបានភ្ជាប់ខេត្តសៀមរាប និងបាត់ដំបង ទៅក្នុងដឹកដីរបស់សៀម ។ ខេត្តទាំងនេះត្រូវបានប្រគល់មកវិញនៅក្រោមអាណាព្យាបាលបារាំង ប៉ុន្តែ ប្រទេសថៃបានយកទៅវិញនៅអំឡុងពេលនៃសង្គ្រាមលោកលើកទីពីរ ។ ខេត្តទាំងនេះត្រូវប្រគល់មកវិញម្តងទៀតក្នុងឆ្នាំ១៩៤៦ ។ ព្រះបាទអង្គអេង ក្រោយមកបានតែងតាំងទួន អាសមិត ជាអភិបាលខេត្តត្បូងឃ្មុំ ។

នៅក្នុងរាជវង្សរបស់ព្រះបាទអង្គច័ន្ទ (១៧៩៦-១៨៣៤) ការគំរាមកំហែងដោយសៀមបានកើនឡើងខ្លាំង ។ ព្រះរាជាបានបញ្ជូនបេសកជនកម្ពុជា ដែលរួមមានទាំង អាសមិត ទៅកាន់វៀតណាម ដើម្បីទៅរកជំនួយ ។ វៀតណាម ដោយយល់ថា អាសមិតជាអតីតមេដឹកនាំបះបោរនៅ ប៉ាន់ឌូរ៉ាំងហ្កា បានទាមទារឲ្យព្រះបាទអង្គ ច័ន្ទ ប្រហារជីវិត អាសមិត ដើម្បីដោះដូរនឹងជំនួយប្រឆាំងនឹងសៀម ។ ព្រះបាទអង្គច័ន្ទ បានប្រហារជីវិតអាសមិតប៉ុន្តែ សេចក្តីសម្រេចចិត្តនេះបានបណ្តាលឲ្យមានការបែកបាក់នៅក្នុងចំណោមអ្នកគាំទ្រកាន់សាសនាអ៊ីស្លាមរបស់គាត់នៅកម្ពុជា ។

នៅពាក់កណ្តាលសតវត្សរ៍ទី១៩ ជ្វាមួយចំនួនធំបានផ្លាស់ទីលំនៅទៅ ចូវដុក ។ នៅដំណាក់កាលក្រោយមក កូនប្រុសម្នាក់របស់អាសមិត ត្រូវបានឲ្យងារជា“សម្តេចចៅពញា” ដោយព្រះបាទនរោត្តម (១៨៦៤-១៩០៤) ។ យ៉ាងហោចណាស់ ចាប់តាំងពីរជ្ជកាលព្រះបាទ អង្គ ឌួង (១៨៤១-១៨៦០) ងាររបិនលើសពីប្រាំបីត្រូវបានប្រគល់ទៅឲ្យអ្នកមុខអ្នកការជនជាតិចាម ដែលរួមមានៈ ឧកញ៉ាបរពិត្រស្នេហា, ឧកញ៉ាបទេសមន្ត្រី *Oknha Bautés*

Montrey, ឧកញ៉ាមន្ត្រីរាជា Oknha Montrey Réachéa, ឧកញ៉ាសេនាចក្រវេទ Oknha Sêna Chahk Vet, ឧកញ៉ាសេនីបទេស Oknha Sêney Bautés, ឧកញ៉ាទេសា Oknha Tésa Norés, ឧកញ៉ាវិសេសសេនី Oknha Visês Séney និង ឧកញ៉ាវិសេសទេសី and Oknha Visês Tésey ។

ការផ្លាស់ទីលើកទីបួនរបស់ចាមមកកម្ពុជាកើតឡើងនៅចន្លោះឆ្នាំ១៨៣០ និង១៨៣៥ ។ នៅអំឡុងពេលនេះ កម្ពុជាស្ថិតនៅក្រោមការគ្រប់គ្រងរបស់វៀតណាមកាន់តែខ្លាំង ។ វៀតណាមនៅពេលនោះ គ្រងរាជ្យដោយព្រះចៅ មិញ ម៉ាង (Minh Mang) (១៨២០-៤០) ដែលជាអ្នកគ្រប់គ្រងត្រកូលង្វៀនទីពីរ ។ វៀតណាមបានដាក់មហាក្សត្រី អង្គ មី (១៨៣៥-៤១) ដែលជាបុត្រីរបស់ព្រះបាទ អង្គ ច័ន្ទ ឲ្យឡើងគ្រងរាជ្យជាមហាក្សត្រីដំបូង និងដែលមានតែមួយគត់របស់កម្ពុជា ។ វៀតណាមមិនបានគ្រប់គ្រងកម្ពុជា ដូចដែលធ្វើចំពោះចម្ប៉ាទេ ប៉ុន្តែ បានរៀបផែនការធ្វើឲ្យក្លាយជាវៀតណាមប៉ុន្មានដងដែរ ឧទាហរណ៍ដូចជាលើកទឹកចិត្តឲ្យប្រើប្រាស់ភាសាវៀតណាម និងទំនៀមទម្លាប់វៀតណាម ។ ដំណើរការធ្វើឲ្យក្លាយទៅជាវៀតណាមស្រដៀងគ្នានេះ ក៏ត្រូវបានដាក់ឲ្យប្រតិបត្តិដែរ នៅប៉ាន់ឌូរាំងហ្កាដែលជាដែនដីនៅសេសសល់ចុងក្រោយរបស់ចម្ប៉ា ។ ការប្រតិបត្តិសាសនា និងប្រពៃណីរបស់ជនជាតិចាមត្រូវបានគាបសង្កត់ ។ អ្នកកាន់សាសនាអ៊ីស្លាមត្រូវបង្ខំឲ្យបរិភោគសាច់ជ្រូក ចំណែកអ្នកកាន់សាសនាហិណ្ឌូត្រូវបង្ខំឲ្យបរិភោគសាច់គោ ។

នៅក្នុងឆ្នាំ១៨៣៥ វៀតណាមបានដាក់ការគ្រប់គ្រងយ៉ាងពេញលេញនៅប៉ាន់ឌូរាំងហ្កា ។ នេះ គឺជាការរលាយបាត់នូវចម្ប៉ាក្នុងនាមជាអាណាចក្រដែនដីសមុទ្រ ។ នៅអំឡុងពេលនេះ ចាមបានភៀសខ្លួនទៅកម្ពុជានៅក្នុងដំណាក់កាលជាច្រើន តាមរយៈសមុទ្រ ឬឆ្លងកាត់តាមដែនដីកូសាំងស៊ីន ។ ជនភៀសខ្លួនចាមទាំងនេះរួមមានសមាជិកញាតិវង្ស និងអ្នកគាំទ្រ ។

ការផ្លាស់ទីលំនៅធំចុងក្រោយមកកម្ពុជា កើតឡើងប្រហែលបន្ទាប់ពីការបះបោររបស់ចាមប្រឆាំងនឹងការគ្រប់គ្រងនឹងការគាបសង្កត់របស់វៀតណាម ។ ការបះបោរលើកទីមួយដែលគេស្គាល់ត្រូវបានដឹកនាំដោយជនជាតិចាមម្នាក់ឈ្មោះ កាទីប ស៊ូម៉ាត់ (Katip Sumat) ដែលបានត្រឡប់ពីទីក្រុងម៉ិកកា មកកម្ពុជា នៅក្នុងឆ្នាំ១៨៣៣ មុនពេលធ្វើដំណើរទៅវៀតណាម ។ ក្រោយមក ស៊ូម៉ាត់ត្រូវបានជ្រើសរើសដោយជនជាតិចាមកាន់សាសនាអ៊ីស្លាមឲ្យដឹកនាំការតស៊ូ ដើម្បីសេរីភាពចេញពីឥទ្ធិពលរបស់វៀតណាម ។ ទ័ពរបស់គាត់រួមមានចាមរស់នៅតាមតំបន់ខ្ពង់រាប ក៏ដូចជាចាមនៅតាមតំបន់ទំនាប ។ ការបះបោររបស់ស៊ូម៉ាត់មិនទទួលបាននូវជោគជ័យធំដុំអ្វីទេ ។ ទ័ពដែលខ្សោយ និងខ្វះការហ្វឹកហ្វឺន ត្រូវបានបង្ក្រាបយ៉ាងឆាប់រហ័សដោយវៀតណាម ។ ការបះបោរលើកទីពីរត្រូវ បានដឹកនាំដោយចាមកាន់សាសនាអ៊ីស្លាមម្នាក់ឈ្មោះ ចា ថាក់ វ៉ា (Ja Thak Va) ។ ដូច ស៊ូម៉ាត់ដែរ ចា ថាក់ វ៉ា គឺជាទួន (គ្រូបង្រៀនសាសនាអ៊ីស្លាម) ប៉ុន្តែ មិនមែនជាអ្នកកាន់សាសនាអ៊ីស្លាមធម្មតាដូច ស៊ូម៉ាត់ទេ ។ គាត់ជាសមាជិកម្នាក់របស់ក្រុមអ៊ីម៉ាំសាន់ (Imam Sann) ដែលបានថែរក្សាការប្រតិបត្តិតាមប្រពៃណីខ្លួន ទន្ទឹមនឹងការប្រតិបត្តិសាសនាអ៊ីស្លាម ។ បន្ទាប់ពីទទួលបានជោគជ័យដំបូង ការបះបោរនេះបានបាត់បង់នូវសន្ទុះរបស់ខ្លួនទៅវិញ ។ វៀតណាមបានប្រើប្រាស់យុទ្ធសាស្ត្រនយោបាយ ដែលរួមមានការដោះស្រាយជម្លោះថ្នាក់ក្រោមក្នុងចំណោមជនជាតិចាម និងអំពើអយុត្តិធម៌មកលើក្រុមនេះដោយអាជ្ញាធរវៀតណាម ។ ការគាំទ្រដល់ ចា ថាក់ វ៉ា បានធ្លាក់ចុះ ។ ចា ថាក់ វ៉ា ត្រូវតាមចាប់ខ្លួនដោយវៀតណាម ។ មិនមានព័ត៌មានច្បាស់ទេថាតើមេដឹកនាំទាំងពីរនេះត្រូវបានចាប់ខ្លួន ឬពួកគេអាចគេចខ្លួនបាន ។ **(នៅមានត)**

**អេង កុកថាយ**


# អានទស្សនាវដ្តីតាមគេហទំព័រ

ទស្សនាវដ្តីស្វែងរកការពិតទាំងអស់ត្រូវបានផ្សព្វផ្សាយតាមគេហទំព័ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកអានអាចរកបានតាមៈ http://d.dccam.org/Projects/Magazines/Magazine_Searching.htm ។ ព័ត៌មានបន្ថែម សូមទាក់ទង សោម ប៊ុនថន ទូរស័ព្ទលេខ ០១២ ៩៩៦ ៧៥០ ឬ ០២៣ ២១១ ៨៧៥ ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥

## សេចក្តីប្រកាសព័ត៌មាន
## របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៣

នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់ មាស មុត ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ពីបទឧក្រិដ្ឋដូចខាងក្រោម៖ មនុស្សឃាត ដែលជាការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងទៀតដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខវត្តឥន្ទ្រញាណ កំពង់សោម ក្រចេះ និងមន្ទីរសន្តិសុខ ស-២១ និងបានប្រព្រឹត្តលើជនជាតិវៀតណាម ជនជាតិថៃ និងជនបរទេសផ្សេងទៀតនៅដែនសមុទ្រ និងនៅលើកោះ ដែលកម្ពុជាប្រជាធិបតេយ្យបានអះអាងថាស្ថិតនៅក្រោមអធិបតេយ្យភាពរបស់ខ្លួន និងអំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ឆ្នាំ ១៩៤៩(តាមរយៈការប្រព្រឹត្តិបទឧក្រិដ្ឋដែលក្នុងនោះមាន ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់ ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់ ការធ្វើមនុស្សឃាតដោយចេតនា ការនិរទេស ឬការផ្លាស់ទីដោយខុសច្បាប់ ការបង្កដោយចេតនាឲ្យមានរបួសធ្ងន់ធ្ងរ ឬឲ្យមានការឈឺចាប់ធ្ងន់ធ្ងរដល់រាងកាយ ឬសុខភាព និងការធ្វើទារុណកម្ម)ដែលបានចោទប្រកាន់ថាបានប្រព្រឹត្តនៅកំពង់សោម ក្រចេះ និងមន្ទីរសន្តិសុខ ស-២១ និងបានប្រព្រឹត្តលើជនជាតិវៀតណាម ជនជាតិថៃ និងជនបរទេសផ្សេងទៀតនៅដែនសមុទ្រ និងនៅលើកោះ ដែលកម្ពុជាប្រជាធិបតេយ្យបានអះអាងថាស្ថិតនៅក្រោមអធិបតេយ្យភាពរបស់ខ្លួន។

ដោយសារការដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*ពីបទចោទប្រកាន់ទាំងនេះ វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក អនុញ្ញាតឲ្យ មាស មុត តាមរយៈមេធាវីរបស់គាត់ មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង និងចូលរួមកិច្ចស៊ើបសួរ ដូច្នេះនឹងជួយបង្កើនល្បឿនដំណើរការស៊ើបសួរ។ ការធ្វើដូច្នេះនឹងអនុញ្ញាតឲ្យកិច្ចស៊ើបសួរ ដំណើរការបានទៅដោយគោរពសិទ្ធិរបស់ភាគីទាំងអស់បានពេញលេញ និងអាចបញ្ចប់កិច្ចស៊ើបសួរក្នុងចិរវេលាសមស្រប ហើយនឹងចេញដីកាដំណោះស្រាយ។

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥) ០២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ០២៣ ៨៦១៥៥៥ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555 www.eccc.gov.kh

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក ឡាស អូលសិន
មន្ត្រីច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ 0២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh

# ដំណឹងស្វែងរកឪពុកមា

ខ្ញុំបាទឈ្មោះ ច័ន្ទ រិទ្ធី បច្ចុប្បន្នរស់នៅខណ្ឌសែនសុខ សង្កាត់ភ្នំពេញថ្មី ក្រុងភ្នំពេញ ។ ខ្ញុំបាទសូមប្រកាសរកឪពុកមា ឈ្មោះ សាប់ សំផន ដែលបានបាត់ខ្លួនក្នុងឆ្នាំ១៩៧៥ ក្រោយខ្មែរក្រហមរំដោះទីក្រុងភ្នំពេញ ។ លោកមា សាប់ សំផន មានស្រុកកំណើតនៅភូមិព្រៃលាភ ខេត្តកណ្តាល ។ គាត់មានឪពុកឈ្មោះ សាប់ ឈុន (ស្លាប់) និងម្តាយ ងួន វ៉ាន់ (រស់) និងមានបងប្អូនប្រុសស្រី៦នាក់ រួមមាន ៖

១) សាប់ សេរីឈុំ ភេទស្រី (ស្លាប់ក្នុងរបបខ្មែរក្រហម)

២) សាប់ សំផន ភេទប្រុស (បាត់ខ្លួនក្នុងរបបខ្មែរក្រហម)

៣) សាប់ ធីតន្ទ ភេទស្រី (ស្លាប់ក្នុងរបបខ្មែរក្រហម)

៤) សាប់ សុខារី ភេទស្រី

៥) សាប់ វ៉ាន់នីន ភេទប្រុស

៦) សាប់ ភូមិរិន្ទ ភេទស្រី

សូមរំឭកថា ក្នុងរបបសាធារណរដ្ឋខ្មែរ លោកមា សាប់ សំផន ជាទាហាននៅបន្ទាយស៊ឹងមានជ័យ និងក្រោយមក ផ្លាស់ទៅធ្វើជាទាហានជើងទឹកនៅកំពង់សោម ខេត្តព្រះសីហនុ ។ ក្រោយថ្ងៃរំដោះ១៧មេសា ឆ្នាំ១៩៧៥ កូនទាហានម្នាក់បានជូនគាត់ឡើងគោក ក្នុងគោលបំណងជូនលោកមាមករកក្រុមគ្រួសារ ហើយក៏បាត់ដំណឹងតាំងពីពេលនោះមក ។

អាស្រ័យហេតុនេះ បើបងប្អូនណាបានឃើញ និងស្គាល់លោកមារបស់ខ្ញុំឈ្មោះ សាប់ សំផន ដូចដែលបានរៀបរាប់ខាងលើ សូមទាក់ទងមកខ្ញុំបាទតាមទូរស័ព្ទលេខ៖ ០១៦ ៨៧៩ ៣៩៨ ឬ ទំនាក់ទំនងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦, មហាវិថីព្រះសីហនុ, រាជធានីភ្នំពេញ ឬ តាមរយៈទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

***សូមអរគុណ!***

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥

## សេចក្តីប្រកាសព័ត៌មាន
## របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៤

នៅថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់ អ៊ឹម ចែម ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ* ពីបទឧក្រិដ្ឋដូចខាងក្រោម៖ មនុស្សឃាត ដែលជាការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងការដ្ឋានស្ពានស្រែង ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងអំពើអមនុស្សធម៌ផ្សេងទៀតនៅមន្ទីរសន្តិសុខភ្នំទ្រយោង និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការធ្វើឲ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀតនៅការដ្ឋានស្ពានស្រែង។

ដោយសារការដាក់ឲ្យស្ថិតក្រោមការពិនិត្យ *ដោយកំបាំងមុខ*ពីបទចោទប្រកាន់ទាំងនេះ វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក អនុញ្ញាតឲ្យ អ៊ឹម ចែម តាមរយៈមេធាវីរបស់គាត់ មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង និងចូលរួមកិច្ចស៊ើបសួរ ដូច្នេះនឹងជួយបង្កើនល្បឿនដំណើរការស៊ើបសួរ។ ការធ្វើដូច្នេះនឹងអនុញ្ញាតឲ្យកិច្ចស៊ើបសួរ ដំណើរការបានទៅដោយគោរពសិទ្ធិរបស់ភាគីទាំងអស់បានពេញលេញ និងអាចបញ្ចប់កិច្ចស៊ើបសួរក្នុងថិរវេលាសមស្រប ហើយនឹងចេញដីកាដំណោះស្រាយ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

| | |
|---|---|
| លោក ឡាស អូលសិន | លោក នេត្រ ភក្ត្រា |
| មន្ត្រីច្បាប់ | មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម |
| ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣ | ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦ |
| ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩ | ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤ |
| សារអេឡិចត្រូនិក: olsenl@un.org | សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh |

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា ទូរស័ព្ទ (៨៥៥) ០២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ០២៣ ៨៦១៥៥៥ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555 www.eccc.gov.kh

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥

## សេចក្តីថ្លែងការណ៍របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទាក់ទងនឹងសំណុំរឿង ០០៤

នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៥ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់ អោ អាន ឱ្យស្ថិតក្រោមការពិនិត្យពីបទឧក្រិដ្ឋដែលបានចោទប្រកាន់ដូចខាងក្រោម៖ មនុស្សឃាតដោយចេតនា ជាការរំលោភបំពានក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ដែលត្រូវបានចោទប្រកាន់ថាបានប្រព្រឹត្តឡើងនៅទីកន្លែងសម្លាប់មនុស្សគោកព្រីង មន្ទីរសន្តិសុខទួលបេង និងមន្ទីរសន្តិសុខវត្តអូរត្រកួន ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងសាសនា ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត(ដូចជា ស្ថានភាពអមនុស្សធម៌នៃការឃុំឃាំង)នៅទីកន្លែងសម្លាប់មនុស្សគោកព្រីង និងមន្ទីរសន្តិសុខទួលបេង ព្រមទាំងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលក្នុងនោះមាន ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ និងសាសនា ការដាក់ក្នុងមន្ទីរឃុំឃាំង និងអំពើអមនុស្សធម៌ផ្សេងទៀត (ដូចជាស្ថានភាពអមនុស្សធម៌នៃការឃុំឃាំង)នៅមន្ទីរសុខវត្តអូរត្រកួន។

ដោយសារការដាក់ឱ្យស្ថិតក្រោមការពិនិត្យពីបទចោទប្រកាន់ទាំងនេះ វិធានផ្ទៃក្នុងរបស់ អ.វ.ត.ក អនុញ្ញាតឱ្យ អោ អាន តាមរយៈមេធាវីរបស់គាត់ មានសិទ្ធិចូលពិនិត្យមើលសំណុំរឿង និងចូលរួមកិច្ចស៊ើបសួរ ដូច្នេះនឹងជួយបង្កើនល្បឿនដំណើរការស៊ើបសួរ។ ការធ្វើដូច្នេះនឹងអនុញ្ញាតឱ្យកិច្ចស៊ើបសួរ បន្តដំណើរការទៅមុខ ដោយគោរពសិទ្ធិរបស់ភាគីទាំងអស់បានពេញលេញ និងអាចបញ្ចប់កិច្ចស៊ើបសួរក្នុងថិរវេលាសមស្រប ហើយនឹងចេញដីកាដំណោះស្រាយ។

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*

លោក ឡាស អូលសិន
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក: olsenl@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃលេខ៖ +៨៥៥ (0)១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុលេខ៖ +៨៥៥ (0)២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh

ផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ប្រអប់សំបុត្រ ៧១ ភ្នំពេញ កម្ពុជា ទូរសព្ទ (៨៥៥) ០២៣ ៨៦១ ៥០០ ទូរសារ (៨៥៥) ០២៣ ៨៦១៥៥៥ គេហទំព័រ www.eccc.gov.kh
National Road 4, Chaom Chao, Porsenchey, P.O. Box 71, Phnom Penh Cambodia Tel: (855) 023 861 500 Fax :(855) 023 861 555 www.eccc.gov.kh

# ស្វែងយល់អំពីគេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## www.cambodiatribunal.org

គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *www.cambodiatribunal.org* គឺជាប្រភពឈានមុខគេនៃសារព័ត៌មានដំណឹងវិវឌ្ឍថ្មីៗ ព្រមទាំងបទអត្ថាធិប្បាយរបស់អ្នកជំនាញជាច្រើនទៅលើដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទាំងមូល ។ រយៈពេលកន្លងមកនេះព័ត៌មានយ៉ាងច្រើនត្រូវបានផ្សព្វផ្សាយ នៅលើគេហទំព័រនេះ ។ គេហទំព័រនេះបង្កលក្ខណៈងាយស្រួលបំផុតសម្រាប់សាធារណជនទាំងឡាយក្នុងការស្វែងយល់អំពីដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

សំណុំរឿងព្រហ្មទណ្ឌលេខ០០២ដែលទាក់ទិននឹងជនជាប់ចោទពីរនាក់ទៀតគឺ ខៀវ សំផន គណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អនុលេខាបក្សនិងជាប្រធានរដ្ឋសភានៃរបបកម្ពុជាប្រជាធិបតេយ្យបានចាប់ផ្តើមបើកសវនាការកាលពីខែវិច្ឆិកា ឆ្នាំ២០១១ និងបានប្រកាសសាលក្រមលើកទីមួយកាលពីខែសីហា ឆ្នាំ២០១៤ ។

ដើម្បីជួយកាត់បន្ថយចំនួនអ្នកខកខានមិនបានតាមដានដំណើរការដោយផ្ទាល់ឲ្យមកនៅត្រឹមកម្រិតតូចមួយ គេហទំព័រឃ្លាំមើលការវិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា *www.cambodiatribunal.org* ត្រូវបានបង្កើតដោយមានផ្នែកជាច្រើនទាក់ទិននឹងរបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ វីដេអូសវនាការទាំងមូលនិងយោបល់ផ្សេងៗរបស់ជនរងគ្រោះទាក់ទងនឹងសវនាការ សារព័ត៌មានផ្សេងៗជុំវិញតុលាការ របាយការណ៍របស់តុលាការ និងអង្គការក្រៅរដ្ឋាភិបាល ដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះ ប្រវត្តិសាស្ត្រ ប្រវត្តិរបស់តុលាការនេះ និងបទអត្ថាធិប្បាយរបស់អ្នកជំនាញ ។

គេហទំព័រនេះនឹងជួយបង្កលក្ខណៈងាយស្រួលគ្រប់គ្រាន់សម្រាប់និស្សិតគ្រប់គ្រឹះស្ថានសិក្សាដែលមានបំណងចង់សិក្សាស្វែងយល់អំពីដំណើរនីតិវិធីអង្គជំនុំជម្រះវិសាមញ្ញដែលជាដំណើរការមានលក្ខណៈចម្រុះជាតិ និងអន្តរជាតិ ។ ឧទាហរណ៍ ការយកទ្រឹស្តីច្បាប់មួយដែលមានលក្ខណៈស្មុគស្មាញ និងចម្រូងចម្រាសមកអនុវត្តដោយអង្គជំនុំជម្រះវិសាមញ្ញគឺទ្រឹស្តី "សហកម្មខក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "*Join Criminal Enterprise*" ដែលតាមរយៈទ្រឹស្តីនេះ ជនសង្ស័យអាចត្រូវបានដាក់ឲ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋទាំងឡាយដែលប្រព្រឹត្តឡើងទៅតាម "ផែនការឧក្រិដ្ឋកម្មរួម" ដែលភាសាអង់គ្លេសហៅថា "*Common Criminal Plan*" ។ដូច្នេះ យើងអាចចូលទៅរកដំណើរការនីតិវិធីផ្សេងៗនៃអង្គជំនុំជម្រះឬបទអត្ថាធិប្បាយរបស់អ្នកជំនាញដើម្បីស្វែងយល់ថាតើចៅក្រមបានសម្រេចយ៉ាងដូចម្តេចចំពោះការដែលយកទ្រឹស្តីនេះមកអនុវត្តនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ តើមានភាគីផ្សេងទៀតដែរឬទេដែលមានយោបល់ទៅលើបញ្ហានេះ?

ប្រសិនបើមិនចង់ចំណាយពេលវេលាច្រើនដើម្បីមើលវីដេអូសវនាការដែលប្រព្រឹត្តឡើងពេញមួយថ្ងៃដែលអាចចំណាយពេលពី៦ទៅ៨ម៉ោងនោះ សាធារណជនអាចចូលទៅក្នុងផ្នែករបាយការណ៍ប្រចាំថ្ងៃអំពីសវនាការ ។ ក្នុងផ្នែកនេះ យើងមានអ្នកឃ្លាំមើលសវនាការម្នាក់ដែលត្រូវបានបញ្ជូនឲ្យទៅអង្គុយនៅក្នុងបន្ទប់សវនាការផ្ទាល់ បន្ទាប់មកអ្នកឃ្លាំមើលនេះសរសេររបាយការណ៍ខ្លីមួយដែលរៀបរាប់អំពីខ្លឹមសារសំខាន់ៗទាំងឡាយទាក់ទិននឹងសវនាការពេញមួយថ្ងៃនោះតែម្តង ។ របាយការណ៍បែបនេះមានជាភាសាខ្មែរដែរ ។

**វ៉ាន់ថាន់ ពៅដារ៉ា**

# ការិយាល័យព័ត៌មានសាធារណៈ

“ការិយាល័យព័ត៌មានសាធារណៈ” របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបបកម្ពុជាប្រជាធិបតេយ្យ និងព្រឹត្តិការណ៍វិវឌ្ឍរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ ។ ប្រភេទឯកសារទីពីរគឺជាបទសម្ភាសដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសជាមួយជនរងគ្រោះនិងអតីតកម្មាភិបាលខ្មែរក្រហម ។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម ។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារប្រភេទទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត ។

តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននឹងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារខ្លះទៀតរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លិនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ជា ផល្លា តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែល truthphalla.c@dccam.org ។





















# ថ្នាក់រៀននៅទួលស្លែង

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតថ្នាក់រៀនសាធារណៈមួយនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ ថ្នាក់រៀននេះត្រូវបានបង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០១១ ដោយមានកិច្ចសហការរវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។ សារមន្ទីរទួលស្លែងគឺជាអតីតសាលារៀនដ៏ទំនើបមួយដែលបានសង់ឡើងជាលើកដំបូងនៅក្នុងឆ្នាំ១៩៦២ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែក្លាយសាលារៀននេះទៅជាគុកដ៏សម្ងាត់បំផុតមួយក្នុងចំណោមគុកចំនួន១៩៦ទូទាំងប្រទេស ។ អ្នកទោសភាគច្រើនដែលត្រូវបញ្ជូនទៅទួលស្លែង គឺជាកម្មាភិបាលខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើក្បត់ជាតិដូចជា ការសហការជាមួយរដ្ឋាភិបាលបរទេស ឬធ្វើជាអ្នកស៊ើបការណ៍ឲ្យសេ.អ៊ី.អា ឬ កា.ហ្សេ.បេ ជាដើម ។



ចាប់តាំងពីការប្រែក្លាយពីកន្លែងរៀនសូត្រមួយទៅជាកន្លែងដ៏គួរឲ្យរន្ធត់ និងមហន្តរាយមួយ ទួលស្លែងមិនដែលទទួលបានមុខងាររបស់ខ្លួនដូចកាលពីដើមវិញឡើយ ។ ទោះបីជាយ៉ាងនេះក្តី នៅពេលអនាគតដើម្បីទាមទារមកវិញនូវកេរដំណែលអប់រំដែលមានលក្ខណៈវិជ្ជមានរបស់ទួលស្លែង និងដើម្បីបន្ថែមសមាសភាពអប់រំមួយទៅក្នុងសារមន្ទីរនេះ ថ្នាក់រៀននេះ ត្រូវបានបង្កើតឡើងដើម្បីផ្តល់ការបង្រៀន និងការពិភាក្សាដោយឥតគិតថ្លៃអំពីប្រវត្តិសាស្ត្ររបបខ្មែរក្រហម និងប្រធានបទដែលជាប់ទាក់ទង ដូចជា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ថ្នាក់រៀននេះ ក៏ជាវេទិកាសាធារណៈមួយសម្រាប់ឲ្យអ្នកមកទស្សនា និងអ្នកដែលនៅរស់រានមានជីវិតចែករំលែកព័ត៌មានគ្នាក្នុងការថែរក្សារយៈកាលនៃប្រវត្តិសាស្ត្រកម្ពុជាដ៏មានសារសំខាន់មួយទុកឲ្យអ្នកជំនាន់ក្រោយបានរៀនសូត្រ ។

បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលមានសញ្ញាបត្រមកពីបរទេស និងបានទទួលវិញ្ញាបនបត្រពីក្រសួងអប់រំ យុវជន និងកីឡា ផ្នែកការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-៧៩) ព្រមទាំងមានការចូលរួមពីអ្នកជំនាញជាតិ និងអន្តរជាតិដែលមានជំនាញលើប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងអ្នកដែលនៅរស់រានមានជីវិតពីមន្ទីរស-២១ នឹងបង្រៀននៅថ្នាក់រៀននេះ ។ ព័ត៌មានទាក់ទងនឹងថ្នាក់រៀននេះ សូមទាក់ទង ម៉ែន ពិចិត្រ តាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬអ៊ីម៉ែលៈ truthpechet@dccam.org ។

**◆ ទីកន្លែង ៖ អគារ “ក” ជាន់លើ ◆ ពេលវេលា ៖ ច័ន្ទ ២-៣រសៀល, ពុធ ៩-១០ព្រឹក, សុក្រ ២-៣រសៀល**

# តើអ្វីជា «ភាពទិសាមញ្ញ» ចំពោះ ពាក្យយុត្តិធម៌ អន្តរជាតិនៅក្នុងប្រទេសកម្ពុជា?

កាលពីថ្ងៃទី៤ ខែកុម្ភៈ អ្នករស់រានមានជីវិតម្នាក់ពីរបប ប៉ុល ពត ដែលបានគ្រប់គ្រងប្រទេសកម្ពុជា ក្នុងអំឡុងទសវត្សរ៍ឆ្នាំ ១៩៧០ បានផ្តល់សក្ខីកម្មនៅក្នុងសាលសវនាការនាទីក្រុងភ្នំពេញ ថា ក្នុងនាមជាក្មេងដែលមានអាយុ១៥ឆ្នាំម្នាក់ គាត់បានឃើញកូនក្មេងជាច្រើនត្រូវបានបោកទៅនឹងគល់ត្នោត ដោយខ្មែរក្រហម ហើយពួកខ្មែរក្រហមបានវះយកថង់ប្រមាត់ចេញរួចចងព្យួរ ។

កាលពីថ្ងៃទី២១ ខែមករា ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ទៀត ឈ្មោះ មាស សុខា បានជម្រាបជូនចៅក្រម និងអ្នកចូលរួមទស្សនារាប់រយនាក់នៅក្នុងសាលសវនាការថា គាត់បានឃើញខ្មែរក្រហមអារកអ្នកទោសប្រមាណជាង១០០នាក់ក្នុងមួយថ្ងៃៗ ហើយក្រោយមកអ្នកទាំងនោះត្រូវយកទៅបោះចោលនៅរណ្តៅសាកសពរួម ។ អ្នកយាមគុកនៅទីនោះ បានបរិភោគប្រមាត់របស់អ្នកទោស ដោយក្លែមជាមួយស្រាស ។ នៅថ្ងៃ២៩ ខែមករា សាក្សី ចាំង ស្រីមុំ បានផ្តល់សក្ខីកម្មអំពីការបង្ខំរបស់ខ្មែរក្រហម ឲ្យគាត់រៀបការជាមួយបុរសដែលខ្លួនស្អប់បន្ទាប់ពីឪពុករបស់គាត់ត្រូវខ្មែរក្រហមយកទៅសម្លាប់ ។

សក្ខីកម្មរបស់សាក្សីត្រូវបានផ្តល់នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អស់រយៈពេលជាច្រើនឆ្នាំ ។ ភស្តុតាងដែលបង្ហាញឲ្យឃើញពីភាពរន្ធត់ក្នុងរយៈពេលបួនឆ្នាំនៃប្រវត្តិសាស្ត្រពិភពលោក ដែលមនុស្សជាច្រើនបានស្លាប់ដោយសារអំពើឧក្រិដ្ឋកម្មនៅក្រោមការគ្រប់គ្រងនៃរបប ប៉ុល ពត ដែលមានចំនួនច្រើនជាងអ្នកស្លាប់នៅក្នុងជម្លោះសម័យក្រោយៗ ដែលជាគោលដៅនៃការដាក់ឲ្យទទួលខុសត្រូវជាអន្តរជាតិ ។

ឆ្នាំនេះគឺជាខួប១០ឆ្នាំនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ យើងក៏កំពុងចូលដល់ខួបលើកទី៤០នៃការចាប់ផ្តើមឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងនៃរបប ប៉ុល ពត នៅក្នុងប្រទេសកម្ពុជា ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ជារយៈពេលដ៏មហន្តរាយ នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលបានបន្តជាប់រហូតស្ទើរគ្រប់បួនឆ្នាំ គិតត្រឹមថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

ដូច្នេះ នេះគឺជាពេលវេលាសមស្របមួយដើម្បីឆ្លុះបញ្ចាំងពីពេលបច្ចុប្បន្ន រួចសម្លឹងមើលទៅអនាគត អំពីកំណត់ត្រានៃទសវត្សរ៍ចុងក្រោយក្នុងដំណើរការនៃអង្គជំនុំជម្រះវិសាមញ្ញ ។ ខណៈពេល ដែលខ្ញុំកំពុងនិយាយនៅថ្ងៃនេះក្នុងឋានៈជាអ្នកជំនាញពិសេសនៃអគ្គលេខាធិការអង្គការសហប្រជាជាតិជំនួយដល់សាលាក្តីខ្មែរក្រហម ទស្សនៈរបស់ខ្ញុំ ពុំបានឆ្លុះបញ្ចាំងពីទស្សនៈទាំងឡាយរបស់អង្គការសហប្រជាជាតិនោះទេ ។

អង្គជំនុំជម្រះវិសាមញ្ញ បានចែករំលែកភាពលំបាករបស់ខ្លួនទៅតុលាការព្រហ្មទណ្ឌអន្តរជាតិ និងតុលាការដែលមានការចូលរួមពីអន្តរជាតិទាំងអស់ក្នុងរយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ។ បើទោះបីជាអាណត្តិការងារមានកំណត់ តុលាការនេះជាតុលាការដែលពុំធ្លាប់មានពីមុនមក និងជាតុលាការ ដែលបានខិតខំប្រឹងប្រែងផ្តល់ផលប្រយោជន៍ ដើម្បីសម្រេចបាននូវគោលដៅយុត្តិធម៌ សម្រាប់ប្រជាជនខ្មែរប្រមាណ១.៧លាននាក់ ដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ និងជនរងគ្រោះកម្ពុជា ដែលនៅរស់រានមានជីវិត ។ គ្មាននរណាម្នាក់ ដែលដើរឆ្លងកាត់ផ្លូវណាមួយនៅក្នុងទីក្រុង ឬផ្លូវលំតូចៗ នៅតាមទីជនបទនៃប្រទេសកម្ពុជា ដោយពុំជួបប្រទះការប៉ះទង្គិចផ្លូវចិត្តធ្ងន់ធ្ងរ ដោយសារឧក្រិដ្ឋកម្មដ៏សាហាវយង់ឃ្នងកាលពីអតីតកាលនោះទេ ។ ប្រជាជនជាច្រើនទាំងចាស់ ទាំងក្មេង ដែលជាជនរងគ្រោះដោយផ្ទាល់ ឬដោយប្រយោល ដោយសារអ្វីដែលកើតឡើងចំពោះសមាជិកគ្រួសារ និងបុព្វជន កាលពី៤០ឆ្នាំមុន នៅតែបន្តញាំញីនៅក្នុងកម្រិតខុសៗគ្នានៃជំងឺបាក់ទឹកចិត្ត

និងការនឹកឃើញនូវរឿងរ៉ាវទួញសោកកាលពីអតីតកាល ។

អង្គជំនុំជម្រះវិសាមញ្ញ ជាតុលាការក្នុងស្រុកដែលមានជំនួយពីភាគីបរទេស ដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ តាមកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា (កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា) ។ អង្គជំនុំជម្រះវិសាមញ្ញចាប់ផ្ដើមអនុវត្តការងាររបស់ខ្លួននៅក្នុងខែកុម្ភៈ ឆ្នាំ២០០៦ និងបានដំណើរការពេញលេញ បន្ទាប់ពីអនុម័តិវិធានផ្ទៃក្នុងកាលពីខែមិថុនា ឆ្នាំ២០០៧ ។ តុលាការនេះមានទីតាំងស្ថិតនៅក្នុងប្រទេសកម្ពុជា ហើយពុំមែនជាតុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍ដូចជា តុលាការព្រហ្មទណ្ឌអន្តរជាតិ ឬតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី និង រ៉្វាន់ដា ឬតុលាការព្រហ្មទណ្ឌអន្តរជាតិទេ ប៉ុន្តែតុលាការនេះមានលក្ខណៈពិសេស ដូចជាតុលាការពិសេសសម្រាប់ប្រទេសលីបាណន់ ឬអតីតតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលេអូន ។ តុលាការទាំងនោះត្រូវបានបង្កើតឡើង ដោយក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ ឬដោយកិច្ចព្រមព្រៀងតាមតុលាការនីមួយៗ ដោយគោរពច្បាប់អន្តរជាតិផ្ទាល់ខ្លួន និងស្ថិតនៅដាច់ៗពីគ្នាតាមប្រព័ន្ធតុលាការនៃប្រទេសរៀងៗខ្លួន ។ តុលាការទាំងនោះ ត្រូវបានផ្ដល់ជូននូវចៅក្រមអន្តរជាតិ ព្រះរាជអាជ្ញាអន្តរជាតិ បុគ្គលិករដ្ឋបាលអន្តរជាតិ និងមេធាវីការពារក្ដីអន្តរជាតិយ៉ាងច្រើនលើសលុប ដើម្បីបំពេញកិច្ចការ ។ ទោះជាយ៉ាងណា តុលាការមួយចំនួននៃតុលាការទាំងនេះប្រើប្រាស់ច្បាប់ក្នុងស្រុកដែលជាប់ពាក់ព័ន្ធនឹងបញ្ហាដ៏សាហាវយង់ឃ្នង ។ តុលាការប្រទេសសេរ៉ាលេអូន និងប្រទេសលីបាណន់បញ្ចូលចៅក្រមសំខាន់ៗមួយចំនួន ដែលមានជាតិសាសន៍ផ្ទាល់ខ្លួន ។

ផ្ទុយទៅវិញ អង្គជំនុំជម្រះវិសាមញ្ញ កែប្រែភាពស្មើគ្នាហើយប្រកាន់ជំហរជាតុលាការ ដែលប្រើប្រាស់ប្រព័ន្ធច្បាប់ជាតិកម្ពុជា ។ សូម្បីតែរចនាសម្ព័ន្ធរបស់តុលាការក៏មានលក្ខណៈប្លែកដោយតម្រូវឲ្យមានការចូលរួមផ្ទាល់ពីអង្គការសហប្រជាជាតិ និងចៅក្រមអន្តរជាតិជាច្រើនរូប ។ ការផ្ដល់បុគ្គលិក និងការគ្រប់គ្រងធ្វើឡើងដោយកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក៏ដូចជាច្បាប់ក្នុងស្រុកនៃប្រទេសកម្ពុជា កំពុងគ្រប់គ្រងអង្គជំនុំជម្រះវិសាមញ្ញ ដែលអនុម័តិនៅឆ្នាំ២០០១ និងត្រូវធ្វើវិសោធនកម្មនៅឆ្នាំ២០០៤ (ច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា) ។ គោលបំណងនៃបញ្ហាយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញដំបូងធ្វើចេញពីច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ក៏ដូចជាក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។ ចៅក្រមដែលមានសញ្ជាតិកម្ពុជាកាន់កាប់តួនាទីច្រើនលើសលប់នៅគ្រប់ដំណាក់កាលនៃតុលាការក្នុងការជំនុំជម្រះ ៖ អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ។ សហព្រះរាជអាជ្ញាជាតិ ធ្វើការងាររួមគ្នា ជាមួយសហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការដាក់សំណុំរឿងដើម្បីធ្វើការស៊ើបអង្កេតតាមផ្លូវតុលាការ ។

ចៅក្រមស៊ើបអង្កេតជាតិធ្វើការរួមគ្នាជាមួយនឹងចៅក្រមស៊ើបអង្កេតអន្តរជាតិ ដើម្បីបើកការស៊ើបអង្កេតតាមផ្លូវតុលាការនៃការបញ្ជូនសំណុំរឿងរបស់សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ រួចចេញដីកាចោទប្រកាន់ ។ នីតិវិធីនៃការដោះស្រាយជម្លោះ ត្រូវធ្វើឡើងដូចមានចែងនៅក្នុងច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញ ដើម្បីដោះស្រាយជម្លោះដែលអាចកើតមានរវាងសហព្រះរាជអាជ្ញាទាំងពីររូប ឬសហចៅក្រមស៊ើបអង្កេតទាំងពីររូប ។ សំណងជាសមូហភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះ និងត្រូវបានទទួលស្គាល់ជាផ្លូវការដោយសារការជាប់ទាក់ទងទៅនឹងឧក្រិដ្ឋកម្ម ដែលបានចោទប្រកាន់នៅក្នុងសំណុំរឿងដែលត្រូវជំនុំជម្រះ ក៏ត្រូវបានការពារតាមផ្លូវច្បាប់ ក្នុងបន្ទប់សវនាការជំនុំជម្រះ ដោយមេធាវីការពារដើមបណ្ដឹងរដ្ឋប្បវេណីជាតិ និងអន្តរជាតិ ។ មេធាវីការពារក្ដីជនជាប់ចោទនីមួយៗក៏មានការចូលរួមដោយមេធាវីការពារក្ដីជាតិ និងអន្តរជាតិដែរ ។

យុត្តាធិការបុគ្គលនៃអង្គជំនុំជម្រះវិសាមញ្ញត្រូវបានកម្រិត និងគ្របដណ្ដប់តែទៅលើ «មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម និងអំពើហិង្សាធ្ងន់ធ្ងរ» នៃច្បាប់ព្រហ្មទណ្ឌកម្ពុជា និងច្បាប់អន្តរជាតិជាក់លាក់ដែលមាននៅក្នុងច្បាប់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ។ យុត្តាធិការពេលវេលារបស់តុលាការ ពន្យាតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ

១៩៧៩ គឺជារយៈពេលស្ថិតក្នុងរបបខ្មែរក្រហមរបស់ ប៉ុល ពត បានកាន់អំណាចនៅក្នុងទីក្រុងភ្នំពេញ ។ ដំណើរការនៃស្តង់ដាអន្តរជាតិ គឺជាផ្នែកសំខាន់នៃនីតិវិធីច្បាប់របស់តុលាការ ហើយត្រូវបានពង្រីកយ៉ាងលម្អិតនៅក្នុងវិធានផ្ទៃក្នុងដែលបានចំណាយពេលមួយឆ្នាំ ដើម្បីចរចាក្នុង ចំណោមចៅក្រមគ្រប់រូបទាំងភាគីជាតិ និងអន្តរជាតិ ។ កម្រិតខ្ពស់បំផុតនៃការផ្តន្ទាទោស ដែលអាចចេញនៅក្នុងសាលក្រមលើពិរុទ្ធភាព ផ្តន្ទាទោសដោយតុលាការគឺជាប់ពន្ធនាគារអស់មួយជីវិត ។

នៅក្នុងបរិបទដោយឡែកក្នុងចំណោម អង្គការសហប្រជាជាតិ និងតុលាការព្រហ្មទណ្ឌ ដែលមានការគាំទ្រពីអង្គការសហប្រជាជាតិ ការស៊ើបអង្កេត និងការជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញ ប្រព្រឹត្តទៅនៅប៉ុន្មានសតវត្សរ៍ បន្ទាប់ពីគណៈកម្មការនៃឧក្រិដ្ឋកម្មយង់ឃ្នងបានបំផ្លិចបំផ្លាញប្រទេសកម្ពុជានៅចុងទសវត្សទី៧០ ។ ការពិតបង្ហាញពីសារសំខាន់ និងពេលវេលាដ៏លំបាកមួយជាពិសេស នៅក្នុង : **ក)** ការកំណត់អត្តសញ្ញាណសាក្សី និងការទទួលបាននូវសក្ខីកម្មពីសាក្សី ដែលមានវ័យចាស់ជរា **ខ)** ការទទួលបាននូវវត្ថុតាងជាសាកសពរលួយសុះ ហើយបានបញ្ចុះនៅក្នុងរណ្តៅសាកសពរួម ដែលសាកសពទាំងនោះត្រូវគេរកឃើញ និងគាស់ចេញមកយ៉ាងផ្ចិតផ្ចង់ **គ)** ចំនួនបកប្រែដ៏មានតម្លៃនៃឯកសារដែលបានរក្សាទុកស្តីពីព្រឹត្តិការណ៍នៅក្នុងអំឡុងរបបខ្មែរក្រហម ដែលបានកន្លងផុតទៅ ដែលទាមទារឲ្យមានការចំណាយពេលច្រើនក្នុងការពិនិត្យ និងវិភាគតាមរបៀបប្រវត្តិសាស្ត្រ និងសង្គមវិទ្យា និង **ឃ)** ការទាមទារឲ្យមានកម្មវិធីផ្តល់ព័ត៌មានដើម្បីអប់រំដល់សាធារណជនដល់ក្មេងជំនាន់ក្រោយអំពីការងារ និងដំណើរការតុលាការទាក់ទងនឹងព្រឹត្តិការណ៍ កាលពីប៉ុន្មានទសវត្សរ៍មុន និងរំឭកពីសារសំខាន់នៃកិច្ចការរបស់តុលាការសម្រាប់យុត្តិធម៌ និងការផ្សះផ្សា ដូចពេលវេលាដែលធ្លាប់ឆ្លងកាត់ ។

ជាចុងក្រោយ ជនសង្ស័យ និងមេធាវីការពារក្តីនៅក្នុងសំណុំរឿងសុទ្ធតែមានវ័យចំណាស់ និងធ្លាប់បានពន្យារពេលជំនុំជម្រះដោយសារបញ្ហាសុខភាពអស់ជាច្រើនដង ។ នៅក្នុងការជំនុំជម្រះនាពេលបច្ចុប្បន្ន ជនជាប់ចោទ ខៀវ សំផន មានវ័យ៨៣ឆ្នាំ ហើយជនជាប់ចោទ នួន ជា មានវ័យ៨៨ឆ្នាំ ។ ជាអកុសល មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ដូចជា ប៉ុល ពត សុន សេន តាម៉ុក និង កែ ពក បានស្លាប់នៅប៉ុន្មានឆ្នាំពេលដែលត្រូវបានកោះហៅឲ្យចូលខ្លួន ។ អៀង សារី អនុរដ្ឋមន្ត្រីនៃរបបកម្ពុជាប្រជាធិបតេយ្យ និងជាជនជាប់ចោទសំខាន់នៅក្នុងសំណុំរឿងកំពុងជំនុំជម្រះបច្ចុប្បន្ន បានស្លាប់នៅក្នុងអាយុ៨៧ឆ្នាំ កាលពីខែមីនា ឆ្នាំ២០១៣ នាពាក់កណ្តាលពេលជំនុំជម្រះ ។ ប្រពន្ធរបស់ អៀង សារី គឺ អៀង ធីរិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៃរបបកម្ពុជាប្រជាធិបតេយ្យ បច្ចុប្បន្នមានវ័យ៨៣ឆ្នាំ ក៏ជាជនជាប់ចោទនៅក្នុងសំណុំរឿង ០០២ ប៉ុន្តែជនជាប់ចោទ ត្រូវតុលាការសម្រេចថា ពុំមានសម្បទាគ្រប់គ្រាន់ផ្នែកបញ្ញាស្មារតី តាមរយៈការធ្វើរោគវិនិច្ឆ័យពីជំងឺវង្វេងវង្វាន់ ហើយនីតិវិធីប្រឆាំងនឹងជនជាប់ចោទនេះត្រូវបានផ្អាកយោងតាមលទ្ធផលនេះ ។

អង្គការសហប្រជាជាតិភ្ជាប់វិធានការចាំបាច់ជាមួយអង្គជំនុំជម្រះវិសាមញ្ញ ដោយផ្អែកលើការប្តេជ្ញាចិត្តខ្ពស់របស់ខ្លួនក្នុងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជា ។ សមាសភាពចម្បងនៃដំណើរការរបស់តុលាការ គឺគម្រោងជំនួយការបច្ចេកទេសរបស់អង្គការសហប្រជាជាតិជាផ្លូវការ ឈ្មោះថា អ្នកសម្របសម្រួលនៃអង្គការសហប្រជាជាតិផ្នែកផ្តល់ជំនួយដល់តុលាការខ្មែរក្រហម ឬ *UNAKRT* ដែលផ្គត់ផ្គង់មន្ត្រី និងបុគ្គលិកអន្តរជាតិដល់ការិយាល័យខុសៗគ្នារបស់តុលាការ ។ គ្រប់បុគ្គលិក និងរាល់ប្រតិបត្តិការផ្នែកហិរញ្ញវត្ថុរបស់ *UNAKRT* គឺជាសកម្មភាពរបស់ទីបញ្ជាការនៃអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ មេធាវីការពារក្តី និងផ្នែកហិរញ្ញវត្ថុ និងបុគ្គលិក ការិយាល័យដើម្បីធានាថាអង្គការសហប្រជាជាតិ និងស្តង់ដាអន្តរជាតិផ្សេងទៀតត្រូវបានអនុវត្តពេញលេញ ។ ខណៈដែលរដ្ឋាភិបាលកម្ពុជាផ្តល់ជំនួយផ្នែកថវិកាដល់ភាគីជាតិនៃអង្គជំនុំជម្រះវិសាមញ្ញចេញពីធនធានរបស់ខ្លួនផ្ទាល់ និងវិភាគទានស្ម័គ្រចិត្តរបស់រដ្ឋាភិបាលបរទេស អគ្គលេខាធិការអង្គការសហប្រជាជាតិ និង *UNAKRT* ត្រូវទទួលខុសត្រូវគ្រប់គ្រងជំនួយ ដែលបានបង្វែរមកពីធនធានរបស់អន្តរជាតិសម្រាប់ផ្នែករបស់ភាគីអន្តរជាតិដែលមានតម្លៃច្រើនជាង ។ ដូច្នេះ នេះគឺជារចនាសម្ព័ន្ធគ្រប់គ្រងមានលក្ខណៈទំនងជាស្មុគស្មាញបន្តិច ខុសប្លែកបន្តិច បើប្រៀបធៀបនឹងតុលាការ

ដែលមានការគ្រប់គ្រងដោយខ្លួនឯង ។

ការចរចាដែលនាំទៅរកការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ បានធ្វើអស់ជាច្រើនឆ្នាំ នៅក្នុងរបៀបរបបសាំញុាំរវាងអង្គការសហប្រជាជាតិ ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាផ្នែកច្បាប់របស់អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ប្រើពេលយ៉ាងយូរចាប់ពីខែមិថុនា ឆ្នាំ១៩៩៧ រហូតដល់ខែមិថុនា ឆ្នាំ២០០៣ នៅពេលដែលកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានចុះហត្ថលេខា ។ មានរឿងមួយគឺថា នៅដើមឆ្នាំ២០០២ ការចរចាបានដាច់គាំង ។ ប៉ុន្តែ មហាសន្និបាតដែលមានសេចក្តីសម្រេចលេខ ៥៧.២២៨ ធ្វើនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ ដឹកនាំដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ បានភ្ជាប់កិច្ចព្រមព្រៀងឡើងវិញ ជាមួយរាជរដ្ឋាភិបាលកម្ពុជាដើម្បីធ្វើឲ្យតុលាការលេចចេញរូបរាងឡើង ។ តាមរយៈការពិភាក្សាគ្នាបន្ថែម ភាគីរាជរដ្ឋាភិបាលបានស្នើ និងឯកភាពធ្វើវិសោធនកម្មច្បាប់របស់ អ.វ.ត.ក ។ ចុងបញ្ចប់ភាគីទាំងពីរ ឯកភាពលើកិច្ចព្រមព្រៀងរវាងកម្ពុជា និងអង្គការសហប្រជាជាតិ ។ ច្បាប់ អ.វ.ត.ក ត្រូវបានធ្វើវិសោធនកម្មប្រកបដោយជោគជ័យ នៅខែតុលា ឆ្នាំ២០០៤ ។

ក្រោយមកដំណាក់កាលវង់ចាំ បានកើតឡើងដោយហេតុថា អង្គការសហប្រជាជាតិបានស្វែងរកការសន្យាផ្តល់ជំនួយស្ម័គ្រចិត្តពីរដ្ឋាភិបាល ដើម្បីបំពេញការចំណាយរយៈពេលបីឆ្នាំរបស់ប្រតិបត្តិការអង្គជំនុំជម្រះវិសាមញ្ញ និងធានាបាននូវវិភាគទានជាក់លាក់សម្រាប់ការងារនៅឆ្នាំដំបូង ។ គោលដៅទាំងនេះសម្រេចបានដល់ត្រឹមខែ មេសា ឆ្នាំ២០០៥ ។

ពុំមានអ្វីដែលអាចបញ្ចប់យុត្តាធិការ និងដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញនោះទេ ។ ទាំងយុត្តិធម៌ព្រហ្មទណ្ឌជាតិ និងអន្តរជាតិ បានទទួលនូវផលប្រយោជន៍នៅក្នុងកម្រិតខុសៗគ្នាពីយុត្តាធិការរបស់អង្គជំនុំជម្រះ និងបទពិសោធដែលទទួលបាន ។ សំខាន់បំផុត អង្គជំនុំជម្រះវិសាមញ្ញបានសម្រេចសមិទ្ធផលសំខាន់ៗឆ្ពោះទៅរកការបំពេញអាណត្តិការងាររបស់ខ្លួន ។ ជាការពិតយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ រួមបញ្ចូលទាំងសេចក្តីសម្រេចលើកិច្ចដំណើរការនីតិវិធី និងការសម្រេចលើអង្គសេចក្តី និងសាលក្រមលើការដាក់ឲ្យមានពិរុទ្ធភាព ឬឲ្យរួចខ្លួន នៅពេលនេះគឺជាកំណត់ត្រាដ៏ទូលំទូលាយមួយនៃយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិដែលបានអនុវត្តនៅតុលាការក្នុងស្រុកដែលមានលក្ខណៈជាអន្តរជាតិ និងមានការរីកចម្រើនរហូតមកដល់ពេលបច្ចុប្បន្ន ។ តុលាការផ្សេងៗទៀត កំពុងដកស្រង់យកយុត្តិសាស្ត្រនៃអង្គជំនុំជម្រះវិសាមញ្ញ ។ វាក៏បានបម្រើដល់ចំណុចពាក់ព័ន្ធសំខាន់ៗ រួមមានជាគំរូសម្រាប់បង្កើតតុលាការស្រដៀងគ្នាមួយដោយមានទំនាក់ទំនងគ្នាយ៉ាងខ្លាំងជាមួយប្រព័ន្ធតុលាការក្នុងស្រុក ក្រោមជំនួយពីខាងក្រៅ ដូចជា អង្គជំនុំជម្រះវិសាមញ្ញអាហ្វ្រិក នៅក្នុងតុលាការសេណេហ្គាល់ បង្កើតឡើងដើម្បីស៊ើបអង្កេត និងចោទប្រកាន់លើអតីតមេដឹកនាំជនជាតិ ឆាដ គឺលោក ហ៊ីសស៊ែន ហាប្រេ ជាលទ្ធផលនៃកិច្ចព្រមព្រៀងរួមគ្នា រវាងប្រទេសសេណេហ្គាល់ និងសហគមន៍អាហ្វ្រិក ។ នៅពេលដែលបុគ្គលណាម្នាក់ ឬប្រទេសណាមួយ បង្កើតតុលាការក្នុងប្រទេសផ្សេងទៀតដែលទទួលរងដោយឧក្រិដ្ឋកម្មអន្តរជាតិ បុគ្គល ឬ ប្រទេសនោះ ត្រូវយកគំរូតាមសេចក្តីសម្រេចមុនៗដែលចេញដោយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

នៅក្នុងបរិបទនៃការជំនុំជម្រះទំនើបលើឧក្រិដ្ឋកម្មអន្តរជាតិដែលបានប្រព្រឹត្តនៅទសវត្សរ៍ទី៧០ មានបញ្ហាប្រឈមផ្នែកច្បាប់ជាច្រើនបានលេចឡើង ប៉ុន្តែបញ្ហាទាំងនោះត្រូវបានគេដោះស្រាយក្នុង មធ្យោបាយផ្សេងៗគ្នា ។ កិច្ចខិតខំប្រឹងប្រែងបញ្ចូលរបៀបថ្មីដោយអង្គជំនុំជម្រះវិសាមញ្ញទទួលបាន បម្រើឲ្យមានការចូលរួមរបស់ជនរងគ្រោះ នៅក្នុងការជំនុំជម្រះលើឧក្រិដ្ឋកម្មអន្តរជាតិដើម្បីធ្វើឲ្យការជំនុំជម្រះប្រកបដោយយុត្តិធម៌រួមជាមួយការរំពឹងទុកថា នឹងមានចំនួនជនរងគ្រោះជាច្រើនអាចចូលរួម ។ ទាំងអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា ការពង្រីកទម្រង់នៃការចូលរួមប្រព្រឹត្តបទល្មើស ចន្លោះឆ្នាំ១៩៧៥ ដល់១៩៧៩ ដែលត្រូវស្គាល់ថា "សហឧក្រិដ្ឋកម្មរួមប្រភេទទី៣" ត្រូវបានរៀបចំយ៉ាងហ្មត់ចត់នៅកន្លែងផ្សេងៗ ពុំមែនជាផ្នែកនៃទម្រង់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងពុំមែនជាគោលការណ៍ទូទៅនៃច្បាប់ដែលអនុវត្តនៅក្នុងដំណើរការនីតិវិធីតុលាការឡើយ ។ អង្គជំនុំជម្រះតុលាការកំពូលបច្ចុប្បន្នកំពុងទទួលយកបណ្តឹងសារទុក្ខពីសហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ ពាក់ព័ន្ធនឹងបញ្ហាច្បាប់ដែល

ត្រូវផ្តោតលើ ។ អង្គជំនុំជម្រះវិសាមញ្ញធ្វើការដោយមានការប្រុងប្រយ័ត្នខ្ពស់ ដើម្បីស្វែងយល់ចំណុចសំខាន់ៗនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលស្ថិតក្នុងយុត្តាធិការពេលវេលារបស់តុលាការ ជាពិសេសបទឧក្រិដ្ឋការធ្វើទុក្ខបុកម្នេញ ការធ្វើឲ្យទៅជាទាសករ ទារុណកម្ម និងបទល្មើសរំលោភ ។ នៅក្នុងការវែកញែកអង្គជំនុំជម្រះតុលាការកំពូលរកឃើញថា ជាឧទាហរណ៍ បទល្មើសរំលោភមិនត្រូវបានញែកឲ្យដាច់ពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិទេក្នុងអំឡុងឆ្នាំ១៩៧៥ - ១៩៧៩ នៅក្នុងសិទ្ធិអំណាចរបស់តុលាការ ទោះយ៉ាងណា បទល្មើសរំលោភបានចាត់ទុកថា ជាទារុណកម្មដូចជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ ។

អង្គជំនុំជម្រះតុលាការកំពូល បានយល់ស្របជាមួយអង្គជំនុំជម្រះសាលាដំបូងថា “ទោះបីជា ចរិតលក្ខណៈអសីលធម៌ ឬភាពឃោរឃៅនៃទង្វើមួយ ពុំមានធាតុផ្សំគ្រប់គ្រាន់ដើម្បីចោទប្រកាន់ថា ជាបទឧក្រិដ្ឋនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ប៉ុន្តែ អាចជំទាស់ទៅនឹងការតវ៉ារបស់មេធាវីការពារក្តីដែលមិនស្គាល់ពីចរិតលក្ខណៈឧក្រិដ្ឋនៃទង្វើទាំងនោះ” ។ នៅក្នុងសំណុំរឿង០០២ អង្គជំនុំជម្រះវិសាមញ្ញអះអាងថា ភាពជាប់ទាក់ទងនឹងជម្លោះប្រដាប់អាវុធ ពុំមែនជាផ្នែកនៃនិយមន័យឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅក្នុងក្របខណ្ឌនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ទេ ។ អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល ក៏បានដោះស្រាយបញ្ហាលំបាក ដោយបង្រួមការជំនុំជម្រះឲ្យកាន់តែចង្អៀតតាមរបៀបញែកសំណុំរឿងទៅជាដំណាក់កាល ដោយសារសំណុំរឿង០០២ ប្រឆាំងនឹងជនជាប់ចោទ ខៀវ សំផន និង នួន ជា ជាសំណុំរឿងធំ និងមានលក្ខណៈស្មុគស្មាញ ហើយដំណើរការពិភាក្សាដែលបានដាក់ក្នុងពេលវេលាមួយសមស្រប ដើម្បីយកមកជំនុំជម្រះនោះ បច្ចុប្បន្ននីតិវិធីនេះត្រូវបានបើកហើយ ។

ទាក់ទងនឹងសំណុំរឿង០០២ អង្គជំនុំជម្រះតុលាការកំពូលបានដោះស្រាយបញ្ហាសំខាន់ៗ ដែលតុលាការកំពុងជួបប្រទះដែលជាការពឹងផ្អែកលើវិភាគទានស្ម័គ្រចិត្ត និងផលប៉ះពាល់ដល់ការពិចារណា ពីហិរញ្ញវត្ថុស្តីពីការងារចម្បងរបស់តុលាការ ។ ភាពពាក់ព័ន្ធនោះ ចៅក្រមរកឃើញថា “ការរំពឹងរបស់អង្គជំនុំជម្រះសាលាដំបូងលើវិបត្តិសេដ្ឋកិច្ច (នៅក្នុងការឈានដល់បញ្ហាបំបែកសំណុំរឿងជាក់លាក់) មិនជាប់ពាក់ព័ន្ធនឹងដំណើរការចេញសេចក្តីសម្រេចនៅពេលបច្ចុប្បន្ននេះទេ” ។ សេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលបានដកស្រង់យ៉ាងវែងថា ៈ “គ្រប់ពេលដែលចៅក្រមមានកាតព្វកិច្ចច្បាស់លាស់ ចៅក្រមត្រូវយកចិត្តទុកដាក់ពីប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី ។ ចៅក្រមត្រូវតែគោរពតាមច្បាប់ជានិច្ច មិនអាចបិទបាំងនីតិវិធីណាមួយ ដោយសារតែកង្វះខាតថវិកានោះទេ...នៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌអន្តរជាតិ គោលនយោបាយហិរញ្ញវត្ថុអាចធ្វើដោយស្របច្បាប់នៅក្នុងសមភាព និងប្រសិទ្ធភាពទៅលើវិសាលភាពនៃការចោទប្រកាន់នៅក្នុងវិធីបីយ៉ាង ៈ តាមរយៈការសម្រេចសេចក្តីដោយផ្អែកលើច្បាប់ចំពោះយុត្តាធិការបុគ្គល និងយុត្តាធិការលើរឿងក្តីដោយសារប្រសិទ្ធភាពអនុវត្តសេចក្តីសម្រេចចោទប្រកាន់ក្នុងសំណុំរឿងហើយ ទោះបីជា ប្រសិទ្ធភាពលើការអនុវត្តសេចក្តីសម្រេចត្រូវដកចេញ ឬកាត់បន្ថយបទចោទក៏ដោយ ក៏ពេលក្រោយមកត្រូវគេអះអាងតាមលក្ខណៈវិនិច្ឆ័យនៃភាពជាតំណាងសមហេតុផលនៅក្នុងដីកាចោទប្រកាន់ ។ ក្រៅពីការលើកឡើងទាំងនេះ ចៅក្រមសាលាដំបូងមិនអាចបញ្ចេញបញ្ចូលភាពដែលអាចយល់ដឹងរបស់ខ្លួនលើបញ្ហាខកខានទៅក្នុងការសន្សំសំចៃបានទេ ។ ប្រសិនបើ ជំនួយពុំគ្រប់គ្រាន់ដើម្បីធានាដល់ការជំនុំជម្រះស្របតាមផ្លូវច្បាប់នោះ នីតិវិធីទាំងអស់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវតែបញ្ចប់ ហើយតុលាការត្រូវតែបិទ ។ ក្រៅពីនេះ នីតិវិធីត្រូវតែបន្តដោយគ្មានសេចក្តីសម្រេចលក្ខណៈបុគ្គលស្តីពីបញ្ហាច្បាប់ និងអង្គហេតុដែលត្រូវប៉ះពាល់ហួសហេតុដោយសារការពិចារណាលើផ្នែកហិរញ្ញវត្ថុ” ។

អង្គជំនុំជម្រះតុលាការកំពូល ក៏បានចែករំលែកនូវការយល់ដឹងដ៏ប្រសើរ ដល់បញ្ហានីតិវិធីស្តីពីសម្បទាមិនគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មអន្តរជាតិ ។ អង្គជំនុំជម្រះតុលាការកំពូលរក្សាទុកសេចក្តីសម្រេចដែលចែងថា តុលាការត្រូវមានកាតព្វកិច្ចប្រើប្រាស់គ្រប់វិធានការដែល នៅមានទាំងអស់ដើម្បីអាចជួយឲ្យជនជាប់ចោទអាចប្រសើរឡើង ដើម្បីមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមជំនុំជម្រះ” ។ អង្គជំនុំជម្រះតុលាការ

កំពូល បានបញ្ជាក់ពីទស្សនៈរបស់អង្គជំនុំជម្រះសាលាដំបូង ដោយគោរពចំពោះជនជាប់ចោទ អៀង ធីរិទ្ធ នៅក្នុងសំណុំរឿង០០២ ថា "នៅតែមានករណីលើកលែងដែលថា នីតិវិធីប្រឆាំងនឹងជនជាប់ចោទ ដែលមានសម្បទាមិនគ្រប់គ្រាន់ជាអចិន្ត្រៃយ៍ត្រូវបានបញ្ចប់ ហើយថា តុលាការធ្វើឲ្យបាត់បង់យុត្តាធិការរបស់ខ្លួន ជាពិសេសនៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ។ ត្រឹមតែអង្គហេតុជាប់ពាក់ព័ន្ធនឹងនីតិវិធីប្រឆាំងនឹងជនជាប់ចោទ ដែលមានសម្បទាមិនគ្រប់គ្រាន់ ដែលត្រូវចោទពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរនៅតែបន្តខកខាន ទោះបីជាពុំមានសម្បទាគ្រប់គ្រាន់ជាអចិន្ត្រៃយ៍ ជាទូទៅ មិនត្រូវបានពិចារណា ដូចជា ការរំលោភច្បាប់ដោយមិនមានហេតុផលសមស្របលើសិទ្ធិមូលដ្ឋានរបស់ជនជាប់ចោទ ជាពិសេស សិទ្ធិទទួលបានការជំនុំជម្រះទាន់ពេលវេលា" ។

លទ្ធផលនៃអង្គជំនុំជម្រះវិសាមញ្ញនៅលើប្រព័ន្ធច្បាប់កម្ពុជាគឺជាការងារមួយកំពុងធ្វើឲ្យមានការរីកសាយពីមួយថ្ងៃទៅមួយថ្ងៃ ។ ផ្អែកលើបទពិសោធរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សញ្ញាណទូទៅនាពេលថ្មីៗនៃរដ្ឋបាលតុលាការត្រូវបានគេបញ្ចូលទៅក្នុងតុលាការជាតិ ហើយលក្ខណៈសំខាន់មួយចំនួនបានរួមបញ្ចូលទៅក្នុងច្បាប់ថ្មីនៃការរៀបចំតុលាការជាតិជាមួយគម្រោងការងារផ្នែកច្បាប់ និងការកែប្រែប្រព័ន្ធ យុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ។ តាមរយៈទំនាក់ទំនងការងារទៅវិញទៅមកប្រចាំថ្ងៃរវាងបុគ្គលិក តុលាការខាងភាគីជាតិ និងភាគីអន្តរជាតិ អង្គជំនុំជម្រះវិសាមញ្ញបានបណ្តុះបណ្តាលចៅក្រម ព្រះរាជអាជ្ញា មេធាវី រដ្ឋបាលតុលាការ និងអ្នកជំនាញផ្សេងទៀតរបស់ភាគីកម្ពុជា ដែលអ្នកទាំងនោះមានតំណែងនៅក្នុងតុលាការជាតិ ឬនឹងមានតួនាទីណាមួយនាពេលអនាគត ។ ជាមួយនឹងវិធានសម្រាប់ដំណើរការនីតិវិធីរបស់ខ្លួន ផ្តោតយ៉ាងសំខាន់លើក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា អង្គជំនុំជម្រះវិសាមញ្ញ បានបង្កើតនូវយុត្តិសាស្ត្រស្តីពីការជាប់ពាក់ព័ន្ធនឹងបញ្ហានីតិវិធី សម្រាប់តុលាការជាតិ ។ តាមរយៈគំនិតផ្តួចផ្តើមដូចជា ការិយាល័យឧត្តមស្នងការនៃអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សធ្វើការកត់សម្គាល់ទស្សនវិស័យនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា យោងលើចំណេះដឹងនៃយុត្តិសាស្ត្រអង្គជំនុំជម្រះវិសាមញ្ញ គួរតែជួយជ្រោមជ្រែងចៅក្រម និងអ្នកអនុវត្តច្បាប់ក្នុងក្របខណ្ឌតុលាការជាតិ ។

ដោយគោរពចំពោះមេធាវីការពារក្តី និងជនជាប់ចោទ អង្គជំនុំជម្រះវិសាមញ្ញបានធ្វើឲ្យមានវឌ្ឍនភាពកើតឡើង ។ នៅក្នុងសំណុំរឿងដំបូងរបស់តុលាការ គឺសំណុំរឿង០០១ អង្គជំនុំជម្រះតុលាការកំពូល តម្កល់សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយផ្តន្ទាទោស កាំង ហ្គេកអ៊ាវ (ហៅ ឌុច) នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ ក៏ប៉ុន្តែបន្ថែមការកាត់ទោសពី៣៥ឆ្នាំរហូតដល់ជាប់ពន្ធនាគារអស់មួយជីវិត ។ ឌុច ជាអតីតប្រធានគុកទួលស្លែង (ស-២១) នៅក្នុងអំឡុងពេលខ្មែរក្រហម ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការធ្វើទុក្ខបុកម្នេញ និងការសម្លាប់ (ជុំវិញការសម្លាប់) ការដាក់ទៅជាទាសករ ការដាក់គុក ការធ្វើទារុណកម្ម និងទង្វើអមនុស្សធម៌ផ្សេងទៀត ។ ***(នៅមានត)***

**រដនីដ សេហ្សហ្វើ**

# រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាន និងកំពុងសរសេរអត្ថបទ ឬ សៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរស័ព្ទលេខៈ (៨៥៥) (១២) ៩៩៦ ៧៥០

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

Email: truthbunthorn.s@dccam.org

Home page: www.dccam.org

# ដំណើរវិវឌ្ឍមានឆ្ពោះទៅរកការកាត់ទោសលើជនសង្ស័យ ក្នុងសំណុំរឿង០០៣ និង០០៤

ក្រោយពីមានការស៊ើបអង្កេតជាផ្លូវការពីសំណាក់សហចៅក្រមស៊ើបអង្កេតអស់រយៈពេលជាច្រើនឆ្នាំ នៅទីបំផុតជនសង្ស័យពីររូបក្នុងចំណោមជនសង្ស័យចំនួន៥រូប ដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ ត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិលោក ម៉ាក ហាមិន សម្រេចបង្ហាញអត្តសញ្ញាណជាសាធារណៈ និងដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យដោយកំបាំងមុខ ទោះបីជាជនទាំងពីររូបនៅពុំទាន់ត្រូវបានចាប់ខ្លួននៅឡើយ ។ ជនត្រូវចោទទាំងពីររូបនោះរួមមាន មាស មុត ជាជនត្រូវចោទក្នុងសំណុំរឿង០០៣ និង អ៊ឹម ចែម ជាជនត្រូវចោទក្នុងសំណុំរឿង០០៤ ។ ចំណែកឯជនសង្ស័យផ្សេងទៀត ពុំទាន់ត្រូវបានសហចៅក្រមអន្តរជាតិបង្ហាញអំពីអត្តសញ្ញាណនៅឡើយ ។

មាស មុត ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខពីបទប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ ។ រីឯ អ៊ឹម ចែម ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ ពីបទប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ និងការប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។

ការដាក់ជនត្រូវចោទទាំងពីររូបឲ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខនេះ គឺធ្វើឡើងក្នុងគោលបំណងដើម្បីបើកផ្លូវឲ្យមេធាវីតំណាងរបស់ជនត្រូវចោទ អាចមានសិទ្ធិចូលពិនិត្យមើលឯកសារក្នុងសំណុំរឿង និងចូលរួមក្នុងកិច្ចនីតិវិធីស៊ើបសួរ ព្រោះចាប់តាំងពីមានការចាត់តាំងមេធាវីតំណាងពីសំណាក់អង្គភាពគាំពារក្ដីឲ្យជនសង្ស័យទាំងអស់ដែលមាននៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤រួចមក មេធាវីតំណាងឲ្យជនសង្ស័យទាំងនោះ ពុំត្រូវបានអនុញ្ញាតឲ្យចូលពិនិត្យឯកសារដែលមាននៅក្នុងសំណុំរឿង និងចូលរួមក្នុងដំណើរការកិច្ចស៊ើបសួរទេ ។ ការផ្ដល់សិទ្ធិឲ្យមេធាវីតំណាងរបស់ជនត្រូវចោទអាចចូលពិនិត្យមើលឯកសារក្នុងសំណុំរឿងនាពេលនេះ គឺជាការធានាចំពោះសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌របស់ជនត្រូវចោទ ឬជនជាប់ចោទ និងដើម្បីលើកស្ទួយប្រសិទ្ធភាពនៃការស៊ើបអង្កេត ។

យោងតាមគម្រោងផែនការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចុះនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៤ បានរំពឹងថា កិច្ចដំណើរការស៊ើបអង្កេតនៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ អាចនឹងបិទបញ្ចប់នៅក្នុងត្រីមាសទី១ ឬត្រីមាសទី២ ក្នុងឆ្នាំ២០១៥ ហើយដីកាដំណោះស្រាយអាចនឹងចេញនៅត្រឹមត្រីមាសទី៣ ឬទី៤នៃឆ្នាំ២០១៥ ។ នៅពេលចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតអាចនឹងសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ឬសម្រេចមិនចោទប្រកាន់ អាស្រ័យទៅលើភស្តុតាងដែលទទួលបានពីការស៊ើបអង្កេត ។

ទោះបីជាអត្តសញ្ញាណរបស់ជនសង្ស័យផ្សេងទៀតនៅពុំទាន់ត្រូវបានបង្ហាញយ៉ាងណាក្ដី ប៉ុន្តែការសម្រេចបង្ហាញអត្តសញ្ញាណរបស់ជនត្រូវចោទចំនួនពីររូបនៅក្នុងសំណុំរឿង០០៣ និងសំណុំរឿង០០៤ និងការអនុញ្ញាតឲ្យក្រុមមេធាវីតំណាងរបស់ជនសង្ស័យទាំងពីររូបមានសិទ្ធិចូលមើលឯកសារក្នុងសំណុំរឿង និងចូលរួមកិច្ចស៊ើបអង្កេតពីសំណាក់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៅពេលនេះត្រូវបានមើលឃើញថា ជាដំណើរវិវឌ្ឍឆ្ពោះទៅមុខប្រកបដោយភាពវិជ្ជមាន ដើម្បីនាំយកអ្នកទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មដែលបណ្ដាលឲ្យប្រជាជនកម្ពុជារាប់សិបម៉ឺននាក់បាត់បង់ជីវិតមកជំនុំជម្រះទោស និងប្រឈមមុខនឹងយុត្តិធម៌ និងដើម្បីផ្ដល់យុត្តិធម៌ជូនជនរងគ្រោះដែលបានទន្ទឹងរង់ចាំអស់រយៈពេលជិត៤០ឆ្នាំ ។

**លីម ជ័យធក្ក**

# មានទោសព្រោះអ្វី?

***(តពីលេខមុន)***

*ពេលនោះក្បួនរទេះក៏ចាប់ចេញដំណើរបន្តទៀត ។ បងស្រីខ្ញុំ គាត់ដើរតាមរទេះដែលដឹកខ្ញុំ និង អាការា ស្រែកផ្ដាំហើយផ្ដាំទៀត ខ្លាចខ្ញុំភ្លេចបណ្ដាំគាត់ ។ រទេះគោបានទាញខ្ញុំឲ្យឃ្លាតឆ្ងាយពីបងស្រីបន្តិចម្ដងៗ ឆ្ងាយទៅៗ រហូតមើលគ្នាលែងឃើញ រទេះបានឆ្លងកាត់ចម្ការកៅស៊ូ ហើយក៏ឈប់សម្រាកហូបបាយថ្ងៃត្រង់នៅទីនោះទៅ ។ ខ្ញុំលាកញ្ចប់បាយដែលបងស្រីខ្ញុំយកមកឲ្យហូបពីរនាក់អាការា ដែលមានម្ហូបសាច់មាន់ចៀន ។ ខ្ញុំហូបបាយផង ស្រក់ទឹកភ្នែកផង ព្រោះស្រណោះម្ដាយ និងពាក្យបណ្ដាំបងស្រី ពេលនោះ បាយលាយទឹកភ្នែកប្រឡូកប្រឡល់គ្នាពេញអារម្មណ៍របស់ខ្ញុំ ព្រោះឃ្លាតឆ្ងាយពីម្ដាយ ពីបងស្រីជាច្រើនឆ្នាំ ហើយបានជួបគ្នាតែមួយប៉ប្រិចភ្នែក មិនទាន់ទាំងបានសួរសុខទុក្ខគ្នាផង ក៏ត្រូវឃ្លាតឆ្ងាយទៅទៀត តើអ្នកណាមិនយំ មិនស្រណោះនោះ? អាការា វានិយាយលួងលោមខ្ញុំ*

*- នែអាភា! យើងជាកូនប្រុស យើងមិនត្រូវសម្រក់ទឹកភ្នែកនៅចំពោះមុខការឈឺចាប់នោះទេ ឯងត្រូវតាំងចិត្តឲ្យរឹងប៉ឹង ហើយតស៊ូទៅមុខទៀត ។*

*អ្នកជម្លៀសទាំងអស់ និងខ្ញុំទាំងពីរបានបន្តដំណើរទៅមុខទៀត ។ ខ្ញុំមានទឹកមុខស្រពាប់ស្រពោនខ្លាំងណាស់ ដែលក្នុងចិត្តខ្ញុំកំពុងតែគិតពីការនិរាសប្រាសព្រាត់នេះ ។ សង្គ្រាមចប់ហើយ ហេតុអ្វីក៏ទុក្ខសោកវេទនានេះនៅតែមានមកលើជនកម្ពុជាដដែលទៀត? តើពេលណាទើបទឹកភ្នែកអ្នកម្ដាយខ្ញុំឈប់ហូរ? ពីថ្ងៃនេះតទៅមុខប្រហែលទឹកភ្នែកដែលហូរនេះក្លាយទៅជាឈាមទៀតផងក៏មិនដឹង ព្រោះទុក្ខដែលព្រាត់កូននៅរស់ វាមានទំហំធំធេងជាងទុក្ខដែលកូនព្រាត់ស្លាប់ទៅទៀត ។*

*ក្បួនរទេះបានមកឈប់សម្រាកនៅភូមិទេពនិមិត្ត ព្រោះដល់ពេលព្រលប់ហើយ ។ នៅភូមិនេះ អង្គការរៀបចំបាយទឹកទទួលដូចនៅផ្សារស្នួលដែរ ។ ខ្ញុំពីរនាក់ ដេកនៅលើគ្រែឫស្សីដែលនៅមុខផ្ទះអ្នកភូមិនោះ លក់យ៉ាងស្កប់ស្កល់ ព្រោះទឹកភ្នែកខ្ញុំដែលហូរស្ទើរខ្សោះពីខ្លួនទៅហើយ នៅពេលជួបម្ដាយ និងបងស្រី ហើយណាមួយខ្ញុំកាត់ចិត្តបានខ្លះៗ ព្រោះទុក្ខសោកខ្លោចផ្សានេះ មិនមែនមានតែលើគ្រួសារខ្ញុំតែមួយនោះទេ ហើយក៏មិនមែនតែចំពោះអ្នកទីក្រុងដែរ គឺមានទូទៅក្នុងស្រទាប់ជនជាតិខ្មែរទាំងអស់ដែលរស់នៅលើមាតុភូមិដីអាណោចអាធ័មនេះគ្រាន់តែតិច និងច្រើនប៉ុណ្ណោះ ។*

*ស្អែកឡើងនៅពេលរសៀល ទើបក្បួនរទេះទៅដល់ភូមិជ័យសម្បត្តិ ស្រុកតំបែរ ដែលជាគោលដៅទីតាំងថ្មីរបស់អ្នកទីក្រុង ។ នៅទីនេះ អង្គការឲ្យខ្ញុំ និងអាការា នៅក្នុងផ្ទះមួយដែលដាក់ចម្រុះគ្នារហូតដល់១២គ្រួសារ ប៉ុន្តែ អង្គការមិនទាន់ចាត់តាំងជាក្រុម ជាពួកទេ ហើយនៅរង់ចាំអ្នកជម្លៀសគ្រប់ចំនួនសិន គឺគ្រាន់តែឲ្យអ្នកទៅដល់មុនរៀបចំជម្រះស្មៅ បោសសម្អាតទីកន្លែងស្នាក់អាស្រ័យតែប៉ុណ្ណោះ ។*

*៥ថ្ងៃកន្លងមកទៀត ទើបអ្នកជម្លៀសមកដល់គ្រប់ចំនួន ។ អង្គការចាត់តាំងឲ្យមានក្រុម មានពួក ចំណែកអ្នកមានគ្រួសារ បងប្អូនមកជាមួយអង្គការឲ្យនៅតាមគ្រួសាររបស់ខ្លួន ចំណែក ខ្ញុំទាំងពីរក៏បានទទួលសមាជិកពីរនាក់ថ្មីទៀត ដែលជាមនុស្សអនាថា គ្មានបងប្អូនឪពុកម្ដាយមកជាមួយដូចគ្នាដែរឲ្យរស់នៅជាគ្រួសារតែមួយ ។ ខ្ញុំទាំង៤នាក់ស្រឡាញ់រាប់អានគ្នាខ្លាំងណាស់ គឺប្រៀបដូចបងប្អូនរួមផ្ទៃ ម្ដាយតែមួយអ៊ីចឹង ។ ចំពោះជីវិតទាំង៤នេះ ក៏បានមូលមតិគ្នា ត្រូវប្ដូរឈ្មោះកំណើតចេញជាវិធីលាក់ប្រវត្តិ កុំឲ្យអ្នកណាស្គាល់ ហើយក៏មានបងប្រុសម្នាក់ដែលមានវ័យច្រើនជាងគេហើយជានិស្សិតនៅមហាវិទ្យាល័យច្បាប់ឆ្នាំទី២ ក៏បានចាត់គាត់ឲ្យធ្វើជាបងសម្រាប់ផ្ដល់គំនិតដាស់តឿនដល់ប្អូនទាំងបីនាក់ គាត់មានឈ្មោះ*

*- ប៉េង មេងសៀ ដូរមកឈ្មោះ ប៉េង*

*- វ៉ុន មករា ដូរមកឈ្មោះ ប៉ក់*

*- ខ្ញុំ ជូ សុភា ដូរមកឈ្មោះ ពីង*

*- ទីវ សុងព័រ ដូរមកឈ្មោះ ប៉ែន*

*ចំណែកអាម្នាក់ទៀតរាងដូចខ្មែរអ៊ីស្លាម ហើយរាងខ្មៅជាង*

គេបន្តិច តែវាមកជាមួយបងវាឈ្មោះ ហែម ម៉ុយ(សព្វថ្ងៃគាត់ជាមន្ត្រីចូលនិវត្តន៍នៅស្រុកត្បូងឃ្មុំ) តែវាចូលចិត្តនៅជាមួយពួកខ្ញុំណាស់ វាឈ្មោះហែម ក្រួច ដូរមកឈ្មោះ អាលាស់ វិញ ។ ខ្ញុំទាំង៤នាក់មានអាយុប្រហែល ៗគ្នា ហើយរៀនត្រឹមវិទ្យាល័យដូចគ្នា ។ ខ្ញុំជាយុវជនទាំង៤នាក់ អង្គការច្រើនចាត់តាំងឲ្យទៅធ្វើការនៅទីឆ្ងាយ ៗ នៅក្នុងព្រៃរយៈពេលពីរ ឬបីខែទើបបានវិលមកភូមិវិញម្តង យើងទាំងអស់គ្នារស់នៅក្នុងស្ថានភាពបែបនេះ អស់រយៈពេលយ៉ាងយូរទើបឲ្យមកធ្វើការនៅក្នុងភូមិវិញ ។ នៅក្នុងភូមិអង្គការចាត់ឲ្យធ្វើស្រែ ដូចគេ ដូចឯង ហើយនឹងចែករបបអង្ករមួយកំប៉ុងអំបិលមួយកូនស្លាបព្រាម្នាក់ក្នុង១ថ្ងៃ របបនេះ ខ្ញុំទាំងអស់គ្នាមិនដែលហូបឆ្អែតសោះឡើយ ព្រោះសុទ្ធតែវ័យកំពុងលូតលាស់ ។ នៅទីនោះបានប្រហែល៦ខែ អាប៉ក់ កើតជំងឺគ្រុនចាញ់ ហើយចុះរាកយ៉ាងខ្លាំងទៀត យើងអាណិតវាណាស់ តែគ្មានមធ្យោបាយនឹងជួយបានសោះ ព្រោះអង្គការមិនឲ្យយើងដើរទៅណាមកណានេះទេ អង្គការមិនដាក់គុកយើងមែនតែ យើងមិនអាចដើរទាក់ទងរកថ្នាំមកជួយព្យាបាលវាបានសោះ ហើយយើងត្រូវទៅធ្វើការរហូតល្ងាចទើបបានត្រឡប់មកជួយថែទាំ អាប៉ក់ ចំណែកម្ហូបគឺគ្មានអ្វីក្រៅពីក្តាមខ្យងដែលឆ្លៀតរកនៅពេលឈប់ សម្រាកថ្ងៃត្រង់នោះ ។ មកដល់ផ្ទះភ្លាម ខ្ញុំឆ្លៀតពេលដើររកសំបកឈើ ឫសឈើដែលគេប្រាប់ថា ជាថ្នាំសម្រាប់ព្យាបាលជំងឺ អាប៉ក់ យកមកស្ងោរឲ្យវាផឹក ហើយរបបរបស់យើងទាំងអស់បានរំលែកទុកឲ្យវាច្រើនជាងគេដែរ ព្រោះវាឃ្លានខ្លាំងណាស់ ។ ចំណែក បងប៉េង គាត់បានយកនាឡិកាដៃគាត់ទៅលួចដូរយកថ្នាំពេទ្យពីយោធាបានខ្លះដែរទុកឲ្យ អាប៉ក់ លេបក្រែងបានធូរស្រាលខ្លះឡើងវិញ ។ តែពីមួយថ្ងៃទៅមួយថ្ងៃ ជំងឺរបស់វារឹតតែធ្ងន់ទៅៗ ខ្លួនប្រាណសល់តែស្បែកដណ្តប់ឆ្អឹង ភ្នែកឡើងល្អក់ស្លឹង តែវានៅតែខំប្រឹងប្រមែប្រមូលកម្លាំងដែលសេសសល់បន្តិចបន្តួចរបស់វា ប្រវេប្រវាធ្វើការងារស្រាលៗដល់យើងទៀត វាខំអង្គុយដេរប៉ះខោអាវដែលរហែកទុកឲ្យយើងទាំងអស់គ្នាទៀត ។ ល្ងាចថ្ងៃមួយនៅពេលខ្ញុំ និងបងប៉េង ត្រឡប់មកពីធ្វើចម្ការពោតដែលនៅក្នុងព្រៃឆ្ងាយដាច់ស្រយាលពីភូមិ ខ្ញុំបានជួបយោធា៣នាក់បាញ់បានសត្វឈ្លូសមួយក្បាល កំពុងឈប់អង្គុយនៅតាមផ្លូវក្នុងព្រៃ ។ ខ្ញុំឃើញសាច់ឈ្លូសក៏នឹកអាណិត អាប៉ក់ ដែលកំពុងដេកឈឺនៅឯផ្ទះ ហើយទាំងពីរនាក់ចាកចេញពីភ្នំពេញមកដល់ឥឡូវរហូតមានជំងឺទៀត វាមិនដែលស្គាល់រស់ជាតិសាច់គោ សាច់ជ្រូកម្តងណាឡើយ ក្រៅពីកូនត្រីក្តាម ខ្យង ដែលយើងរកបាននោះឡើយ ។

- បង បើយើងបានសាច់នេះឲ្យ អាប៉ក់ ស៊ីម្តងប្រហែលជាវាឆាប់មានកម្លាំងហើយមើល ទៅ?

- អឺ! តែធ្វើម៉េចយើងនឹងបាននោះ?

ដោយសេចក្តីអាណិត អាប៉ក់ ខ្លាំងពេកខ្ញុំក៏ដាច់ចិត្តសុំគេ

- បងទាំងបី! ឲ្យខ្ញុំសុំសាច់ឈ្លូសនេះ ឲ្យមិត្តខ្ញុំបន្តិចបានទេ? ព្រោះវាមានជំងឺនៅឯភូមិ ឯណោះ ។

យោធាទាំងបីសម្លឹងមកខ្ញុំ ដោយកែវភ្នែករាងសោះអង្គើយនឹងសំណើនេះ ហើយតបថា ៈ

- បើឈឺ ម៉េចមិនយកទៅឲ្យពេទ្យព្យាបាលទៅ?

- ភូមិខ្ញុំអត់ទាន់មានមន្ទីរពេទ្យទេ ។

ម្នាក់ទៀតក៏បន្តសំដីឡើង

- ហ៊ឺ ឲ្យគាត់បន្តិចទៅ!

និយាយផង ព្រមទាំងទាញកាំបិតស្នៀតទាហានដែលសៀតនៅចង្កេះ មកចៀរសាច់ឈ្លូសទាំង ស្បែកទាំងរោមឲ្យខ្ញុំប៉ុនបាតដៃ ។

- ខ្ញុំអរគុណនឹងបងៗទាំងអស់ហើយ ។

អ្នកទាំងបីមិនឆ្លើយតប ឬក៏គិតអ្វីចំពោះខ្ញុំទេ ហើយខ្ញុំក៏មិនខ្វល់ដែរ ព្រោះចិត្តខ្ញុំត្រេកអរយ៉ាងខ្លាំង នៅពេលបានសាច់នេះមកឲ្យ អាប៉ក់ ។ មកដល់ភូមិ ខ្ញុំប្រញាប់យកសាច់នេះទៅលាងទឹកនៅអណ្តូងខាងមុខផ្ទះ ស្រាប់តែឮបងប៉េង ស្រែកហៅខ្ញុំៈ

- អាពីង អាពីង មកឲ្យលឿនមក អាប៉ក់ វាក្តៅខ្លាំងណាស់ ។

ខ្ញុំស្ទុះរត់ចូលទៅ ឃើញភ្នែក អាប៉ក់ ឡើងសស្កុស ខ្លួនវាសន្ធប់ស្តូកស្តឹង បងប៉េង គាត់រឹត ប្របាច់ និងជួយធ្វើចលនាបេះដូងឲ្យវាមួយសន្ទុះទើបវាដឹងខ្លួនវិញ ។

- នែ! អាពីង ឯងឆាប់ទៅដាំបបរឲ្យវា បងទៅបូតស្លឹកគ យកមកបំពោកជួយបន្ថយកំដៅឲ្យវាសិន ។

- បាទបង! ឯងទៅឲ្យឆាប់ឡើង កិច្ចការនេះទុកខ្ញុំចាត់ចែង ។

ខ្ញុំបង្កាត់ភ្លើងលាងឆ្នាំងដាក់ដាំបបរ និងប្រឡាក់សាច់ឈ្លូសអាំងយ៉ាងញាប់ដៃ ។ អាប៉ក់ ដេកសម្លឹងមកខ្ញុំហើយកែវភ្នែកស្លក់

របស់វា ខ្ញុំចាក់ទឹកថ្នាំមួយត្រឡោកយកមកឲ្យវាផឹក

- ណេះ! ឯងផឹកថ្នាំនេះទៅ ។

ខ្ញុំជួយលើកវាឲ្យអង្គុយផ្អែកទៅជញ្ជាំងផ្ទះ

- ឯងចាប់ផ្តើមក្តៅខ្លួនពីពេលណា?

វានិយាយតបមកខ្ញុំហើយសំឡេងខ្សាវៗរកស្តាប់ស្ទើរមិនបាន ។

- អញរងាញាក់តាំងពីពេលរសៀល ហើយនៅក្នុងផ្ទះនេះគ្មានមនុស្សទេ គេចេញទៅធ្វើការអស់ហើយ ។

ខ្ញុំប្រចាប់ដៃជើងឲ្យវា ដែលមានតែឆ្អឹង ជួយឲ្យវាបានស្រួលខ្លួនខ្លះ ។ វាសួរខ្ញុំវិញថាៈ

- ចុះអាប៉ែន និងអាលាស់ វាទៅណាអស់ហើយ?

- អាពីរនាក់ហ្នឹង អង្គការឲ្យវានៅចាំដេញសេក នៅចម្ការពោតហើយ ចំណែកអញ និងបងប៉េង បានសុំអង្គការមកវិញ ព្រោះឯងឈឺគ្មានអ្នកណាជួយថែទាំទេ ។

- ស្អែកនេះ ពេលទៅចម្ការ ឯងយកម្ជូកស្លឹកត្នោតនេះឲ្យអាប៉ែនផង អញដេររួចហើយ ។

- ចុះឯងឈឺប៉ុណ្ណឹងហើយ នៅប្រឹងដេរធ្វើអីទៀត ឯងកុំគិតពីយើងទាំងអស់គ្នាអី គិតតែសម្រាកខ្លួនឲ្យឆាប់ជាទៅបានហើយ ។

វាក្រវីក្បាលយឺតៗ

- អញប្រហែលគ្មានសង្ឃឹមទេ អាពីង!

- ឯងកុំអស់សង្ឃឹម យើងទាំងអស់គ្នានឹងជួយឯងឲ្យទាល់តែជា ហើយឯងត្រូវតែរស់ ដើម្បីបានជួបនឹងម្តាយរបស់ឯងវិញណា អាប៉ក់!

- គ្នាសូមអរគុណដល់ បងប៉េង និងអ្នកទាំងអស់គ្នាខ្លាំងណាស់ ដែលបានជួយថែទាំគ្នាហើយ អំពើល្អនេះ ប្រហែលគ្នាមិនបានសងពួកឯងវិញទេ ។

- មិនមែនជាគុណបំណាច់អីទេ អាប៉ក់ នេះជាពេលដែលយើងត្រូវជួយគ្នាទៅវិញទៅមក ក្នុងគ្រាមានទុក្ខលំបាក

- តែគ្នាដឹងថា នឹងត្រូវឃ្លាតឆ្ងាយពីឯងទាំងអស់គ្នានៅពេលឆាប់ៗនេះហើយ ។ គ្នាទៅនឹងបានដុតទុក្ខកង្វល់អស់ហើយ តែឯងរាល់គ្នាដែលនៅរស់នេះទេ ដែលត្រូវរែកពុនសំពាយកម្មដែលពោរពេញទៅដោយភាពសោកសៅនិរាសព្រាត់ប្រាស និងអម្រែកដ៏ធ្ងន់មួយទៀតដែលឯងទាំងអស់គ្នា ត្រូវតែទទួលយកក្នុងឋានៈជាទាសករ នោះគឺភារកិច្ចរបស់អង្គការយ៉ាងធ្ងន់មកលើពួកឯងហើយ ត្រូវអនុវត្តត្រង់ត្រាប់តាមបញ្ជាឲ្យបានល្អ ដោយគ្មានទាមទារតវ៉ាអ្វីទាំងអស់ ។ ដូច្នេះឯងទាំងអស់គ្នាត្រូវតែប្រមូលកម្លាំងកាយដើម្បីត្រៀមចាំទទួលបន្ទុកនេះឲ្យបានប្រសើរបំផុត បើពុំដូច្នោះទេ ឯងទាំងអស់គ្នាមិនអាចទៅដល់ទីដៅមួយដែលយើងទន្ទឹងរង់ចាំនោះឡើយ ។

- បានគ្នាស្តាប់បានគ្រប់ម៉ាត់ហើយនូវពាក្យរំឭករបស់ឯង តែឯងត្រូវតែខំសម្រាកឲ្យបានច្រើន កុំគិតទៀតអីរឿងថ្ងៃនេះ យើងធ្វើតាមថ្ងៃនេះ ឯរឿងថ្ងៃស្អែកយើងធ្វើតាមថ្ងៃស្អែក ។ អូ! បបរ និងសាច់ឈ្លូសឆ្អិនអស់ហើយ ចាំអញទៅយកមកឲ្យឯងស៊ី ក្រែងឆាប់មានកម្លាំងណា៎

- គ្នាលែងឃ្លានអ្វីទៀតហើយ ឯងទុកស៊ីពីរនាក់បងប៉េងចុះ!

- ទោះយ៉ាងណាឯងត្រូវតែខំប្រឹងស៊ីដែរ ព្រោះអញ និងបងប៉េង ខំសុំគេយកមកឲ្យឯង ដូច្នេះ ឯងត្រូវតែស៊ីដើម្បីផ្តល់កម្លាំងចិត្តដល់អញពួទេ ។

វាងក់ក្បាល ។ ខ្ញុំយកបបរ និងសាច់ឈ្លូសអាំងចោលក្លិនឈ្ងុយគួរឲ្យឆ្ងាញ់ណាស់មកឲ្យវាៈ

- នេះបបរមកដល់ហើយ ឯងប្រឹងស៊ីឲ្យអស់ណា ចាំគ្នាបញ្ចុក!

- មិនបាច់ទេ គ្នាស៊ីខ្លួនឯងបានហើយ ឯងទៅដួសទឹកចុះ!

- អឺ! អីចឹងក៏បាន តែឯងត្រូវឆាប់ស៊ីទៅ តែបងប៉េងមកវិញគាត់បំពោកស្លឹកគឲ្យឯងហើយ ព្រោះខ្លួនឯងនៅក្តៅខ្លាំងណាស់ ។

វាប្រឹងលេបបបរទាំងខ្លួនវាមិនត្រូវការ វាស៊ីដើម្បីលើទឹកចិត្តខ្ញុំកុំឲ្យអស់សង្ឃឹមដោយសារវាតែប៉ុណ្ណោះ ។ ពេលវាស៊ីបបររួច វាបែកញើសពេញខ្លួន ខ្ញុំជូតខ្លួនហើយបក់ផ្ចិតស្រទបស្លាឲ្យវា ។ បងប៉េងក៏មកដល់ដោយមានទាំងស្លឹកគប្រចាប់រួចស្រេចមួយផ្តិលធំមកជាមួយផង ។

- ម៉េចហើយ អាប៉ក់ ឯងស្រួលខ្លួនវិញហើយឬ?

វាខំញញឹមទាំងស្បែកថ្ពាល់ផតជ្រីវជ្រួញ

- ខ្ញុំស្រួលខ្លួនបន្តិចហើយបង បងទៅដួសទឹកហើយពិសាបបរចុះ

- ទេ! បងមិនទាន់ឃ្លានទេ ឯងដេកទៅ ចាំបងស្ងំស្លឹកគនេះ

ឲ្យត្រជាក់ខ្លួន

ខ្ញុំ និងបងប៉េង គ្រាហ៍វាឲ្យដេកវិញ ហើយបងប៉េងយកស្លឹកគមកបំពោកពេញខ្លួនវា វាសម្ងំដេក ។ ខ្ញុំ និងបងប៉េង ទៅដួតទឹកហើយរៀបចំហូបបបរ ភ្លើងចន្ទះភ្លឺដួងៗ នៅចុងជើង ខ្ញុំអង្គុយបក់ផ្ចិតឲ្យ អាប៉ក់ និងអាប៉េង កំពុងដេកដោយអស់កម្លាំង ហើយខ្ញុំខស្បូរហ៍មើលស្លឹកគ កាលណាវាស្ងួតទឹក ខ្ញុំដូរដាក់ស្លឹកថ្មីថែមទៀត ។ ខ្ញុំអង្គុយម្នាក់ឯង សម្លឹងមើលរូបរាង អាប៉ក់ ដែលវាកំពុងតែដេកកើយបង្ហែចតូចមួយគួរឲ្យសង្វេគណាស់ ។

ឱ!ជីវិតយុវជន អ្នកធ្លាប់តែកៀវក្លាមាំមួននឹងស្រស់បំព្រងចុះឥឡូវម្ដេចក៏ប្រែទៅជាស្វិតក្រៀមក្រញ៉ង់ ស្គមកំព្រឹងបែបនេះទៅវិញ ។ នេះឬជាទណ្ឌកម្មរបស់ព្រហ្មលិខិត? ឬក៏ជាទុក្ខសោកដែលបន្សល់ពីសង្គ្រាម? ទេ មិនមែនទេ ព្រោះសង្គ្រាមបានរលត់ទៅហើយ រីឯទំហំនៃការឈឺចាប់របស់ប្រជាជនខ្មែរនៅក្នុងសង្គ្រាមក៏ត្រូវបញ្ចប់ដែរ តែនេះវាជាទុក្ខសោកដែលទើបតែកើតថ្មីៗ នៅក្រោយសង្គ្រាមនេះទេ ហើយកាន់តែមានទម្ងន់កើនឡើងជារៀងរាល់ថ្ងៃ តើវាកើតមកពីហេតុអ្វី? ខ្ញុំសម្លឹងមើលរាងកាយវាយូរទៅកាន់តែអាណិតអាសូរវាកាន់តែខ្លាំងឡើង ចុះទំរាំបើម្ដាយបង្កើតរបស់វា មកឃើញសភាពបែបនេះវិញនោះ តើគាត់នឹងសោកសង្រេងអាណិតកូនយ៉ាងណាទៅ? មិនដឹងជាម៉ោងប៉ុន្មានយប់ហើយទេ ខ្ញុំស្ទាបខ្លួនវា ដូចជាត្រជាក់ជាងពេលល្ងាចបន្តិច ។ បងប៉េង ក៏ភ្ញាក់ឡើងៈ

- អាពីង ឯងមិនទាន់ដេកទេឬ?

- បាទ! ខ្ញុំមិនទាន់ងងុយទេបង!

គាត់ស្ទាបខ្លួនអាប៉ក់ មើល

- វាត្រជាក់ខ្លួនវិញហើយ ឯងដេកចុះប្រយ័ត្នឈឺម្នាក់ទៀតវីវរធំហើយ ។ ទៅឯងដេកចុះទុក ឲ្យបងមើលវាម្ដង ។

- អ៊ីចឹងខ្ញុំដេកហើយ តែបើវាត្រជាក់ស្រួលហើយ បងដេកដែរទៅដើម្បីយកកម្លាំងធ្វើការថ្ងៃស្អែកទៀត ។

- នៅពេលព្រលឹម អាប៉ក់ បានដាស់អង្រួនខ្ញុំឲ្យភ្ញាក់ពីដំណេក ខ្ញុំបន្ទាត់ភ្លើងដាំទឹកថ្នាំទុកឲ្យវាផឹក ចំណែក អង្ករបបរវា និងបបរខ្ញុំ ខ្ញុំរៀបចំទុកឲ្យវាទាំងអស់គឺទុកតែរបបបងប៉េង អាប៉ែន និងអាលាស់ យកទៅហូបទាំងអស់គ្នា នៅចម្ការពោត ។

ចំណែកបងប៉េងគាត់រៀបចំបត់មុងភួយរួចរាល់ហើយគាត់ក៏សួរ អាប៉ក់ៈ

- យ៉ាងម៉េចដែរអាប៉ក់ ឯងស្រួលខ្លួនទេ? បើមិនស្រួលខ្លួនទេ ចាំបងសុំប្រធានក្រុមឈប់មួយថ្ងៃនៅជួយ មើលឯងទៀត ។

- មិនអីទេបង! បងទៅធ្វើការចុះកុំឲ្យគេថ្នាំងថ្នាក់នឹងយើង ។

- រឿងនេះវាមិនសំខាន់ទេ ព្រោះបងចេញទៅធ្វើការរាល់ថ្ងៃ គ្រាន់តែសុំគេឈប់មួយថ្ងៃពីរ ក៏មិនទាន់ជាអីដែរ សំខាន់គឺឯងទេ ដែលត្រូវយកចិត្តទុកដាក់នោះ ដូច្នេះឯងត្រូវតែប្រាប់បងឲ្យត្រង់កុំលាក់លៀម បៀមសម្ងំទ្រាំលំបាកតែម្នាក់ឯងនោះ ។

វាញញឹមស្ងួតដើម្បីលួងចិត្តបងប៉េង និងខ្ញុំ

- ថាមិនអីទេបង ខ្ញុំអាចស៊ូបានណា បងកុំព្រួយបារម្ភអី ។

ខ្ញុំឃើញវាញញឹមហាក់ដូចជារាងធូរស្រាលក្នុងចិត្តបន្តិច

- អ៊ីចឹង ទឹកថ្នាំអញដាំរួចហើយ ទុកនៅចុងជើងឯងនេះ ចំណែកអង្ករ និងសាច់ឈ្លូសនៅសល់១ដុំទៀត អញយកទៅផ្ញើមីងរឿន ឲ្យគាត់ជួយដាំបបរឲ្យឯងរួចហើយ ហើយបើមិនស្រួលខ្លួនឯងហៅមីង រឿនឲ្យជួយទៅព្រោះអញបានផ្ដាំផ្ញើគាត់រួចហើយ ។

- អឺ! ឯងទៅធ្វើការចុះ អាពីង!

- បើអ៊ីចឹងអញ និងបងប៉េង ទៅធ្វើការហើយ ចាំល្ងាចអញនឹងឆាប់ត្រឡប់មកវិញ ហើយ អាប៉ែន វាដាក់អន្ទាក់ផង បើបានសេក ចាំអញប្រឡាក់អំបិលយកមកផ្ញើឯងទៀតណា ។

វាងក់ក្បាល ។ ខ្ញុំ និងបងប៉េង ក៏ចាកចេញទៅធ្វើការដូចសព្វដងជាមួយប្រជាជនជម្លៀសជាច្រើននាក់ទៀត ។ ថ្ងៃនេះ ក្រុមពលករអ្នកជម្លៀសបានខិតខំបំពេញការងារយ៉ាងសកម្ម ។ ប្រធានក្រុមក៏បានបញ្ចប់ការងារនេះមុនពេលកំណត់ ។ ខ្ញុំពីរនាក់ បងប៉េងប្រញាប់ស្រូតរូចមកភូមិវិញ ដើម្បីបានជួយថែទាំ អាប៉ក់ និងដើររកថ្នាំជួយសម្រាលជំងឺរបស់វា ។ ចំណែកអាប៉ែន និងអាគ្រួច អង្គការចាត់ឲ្យវានៅដេញសេកដដែល អាប៉ែន វាបានផ្ញើងៀតសត្វសេកដែលហាលថ្ងៃក្រៀមល្អណាស់យកឲ្យ អាប៉ក់ ។ ខ្ញុំទទួលងៀតសេកពីវា ដែលក្នុងចិត្តសប្បាយ ព្រោះ អាប៉ក់ នឹងបានម្ហូបមួយផ្សេងទៀតនៅល្ងាចនេះ ។ មកដល់មុខផ្ទះ ខ្ញុំឃើញពូប្រធានភូមិ និងបងប្អូនអ្នកជម្លៀសប្រុសៗបីនាក់ កំពុងតែក្រងបន្ទះឫស្សី ។ មីងរឿនបានមកប្រាប់ខ្ញុំ និងបងប៉េង ថា អាប៉ក់ ស្លាប់ហើយខ្ញុំ និងបងប៉េង

ស្មើរស្មុះដង្ហើមស្លាប់ ស្ទីកក និងជៀតសត្វសេកដែលខ្ញុំកាន់នៅដៃត្រូវជ្រុះធ្លាក់ដល់ដី ខ្ញុំដើរយ៉ាងលឿនចូលទៅក្នុងផ្ទះ ឃើញខ្មោច អាប៉ក់ ដេកស្លាប់ខ្លួនទទេ មានតែខោខ្លីត្រឹមក្បាលជង្គង់ ។ ខ្ញុំស្ទើរតែស្រែកទ្រហោយំ យំឲ្យខ្លាំងឲ្យសមនឹងទំហំចិត្តរបស់ខ្ញុំដែលអាណិតវា ។ តែខ្ញុំតាំងចិត្តឲ្យបាននៅចំពោះមុខប្រធានភូមិ ។ តែទឹកភ្នែកខ្ញុំនៅតែលួចហូរមករឹមៗជាប់ជានិច្ច ។ ខ្ញុំងាកមកសួរមីង វឿន

- មីង តើវាស្លាប់ពីពេលណាមក?

- ប្រហែលថ្ងៃរសៀលក្មួយ ព្រោះនៅថ្ងៃត្រង់មីងបានដាំបបរ និងអាំងសាច់ឲ្យមីងលើកបបរ បញ្ចុកវា តែវាគ្រវីក្បាល ហើយឲ្យមីងទុកនៅក្បែរខ្លួនវា ។ មីងទុកបបរឲ្យវា ហើយប្រាប់ថា បើឃ្លានក្មួយយកហូបទៅមីងទុកនៅជិតនេះទេ មីងទៅបុកអង្ករវិញហើយ ។

- តើក្នុងខ្លួនក្មួយមានធ្វើទុក្ខខ្លាំងទេ?

- មិនអីទេមីង មីងទៅធ្វើការវិញចុះ ។

- មីងទៅធ្វើការរហូតថ្ងៃរសៀល ទើបអង្គការឲ្យមីងមកកើបស្រូវនៅជង្រុកខាងត្បូងផ្ទះបន្ថែមទៀត ។ មីងក៏ឈៀងចូលមកមើលវាមួយភ្លែត ឃើញវាដាច់ខ្យល់ស្លាប់ទៅហើយ ។ មីងក៏ប្រញាប់ទៅប្រាប់ប្រធានភូមិឲ្យមកមើលនឹងចាត់ចែងទុកដាក់ខ្មោចវា ។

ខ្ញុំពីរនាក់ បងប៉េង បានលើកសពវាពាក់អាវកញ្ចាស់ដែលមានបំណាស់ស្មើរស្មុះសាច់ក្រណាត់ ។ ខ្លួនវានៅទន់ល្មើយប្រហែលទើបតែស្លាប់ដែរទេ ។ ប្រធានភូមិបានស្ដីតបមកយើងទាំងពីរថាៈ

- មិនបាច់ស្លៀកពាក់ឲ្យវាធ្វើអីទេ ទុកស្លៀកពាក់ធ្វើការខ្លួនឯងទៅ ជួយសន្សំសំចៃព្រោះ អង្គការយើងនៅក្រ ។

- មិនអីទេពូ! ខោអាវខ្ញុំនៅមានស្លៀកដែរហើយ អាវមួយនេះ ក៏ចាស់ផុយដែរហើយ ពាក់ឲ្យវាចុះ ។

បងប៉េង និយាយព្រមទាំងលាតត្រដាងខោអាវចាស់ផុយដែលមានបំណាស់ ស្មើរស្មុះបង្ហាញប្រធានភូមិៈ

- អើ! ពាក់ទៅអីចឹង!

បន្ទាប់មក គេក៏យកបន្ទះឫស្សីដែលក្រងនោះមកដល់ ។ ប្រធានភូមិចេញបញ្ជាថាៈ

- មិត្តឯងទាំងពីរនាក់លើកខ្មោចវាដាក់ក្នុងគ្រៀសនេះទៅ ហើយរុំចងសែងយកទៅកប់ទៅទាន់នៅភ្លឺ ។

ខ្ញុំពីរនាក់បងប៉េង លើកសព អាប៉ក់ ដាក់ក្នុងគ្រៀសឫស្សីដែលធ្វើរួចស្រេច ហើយសែងចេញពីផ្ទះដោយមានអ្នកមានជម្ងឺសពីរបីនាក់ទៀតដែលប្រធានភូមិចាត់ឲ្យទៅជួយជីករណ្ដៅទៅជាមួយដែរ ។ ពេលលើកសព អាប៉ក់ ដាក់ក្នុងរណ្ដៅរួចហើយ បងប៉េង និយាយថ្លែងវិយោគទុក្ខថាៈ

- អាប៉ក់ ប្អូនប្រុសបងសូមវិញ្ញាណក្ខន្ធប្អូនទៅឲ្យបានសុខ ហើយកើតជាតិណាៗទៀត សូមកុំឲ្យឯងជួបទុក្ខសោកនិរាសប្រាសព្រាត់បែបនេះទៀត ។ ពេលនេះ ឯងឃ្លាតឆ្ងាយពីយើងទាំងអស់ហើយ ហើយយើងក៏ត្រូវបាត់បង់ឯងជារៀងរហូត គ្មានសង្ឃឹមថានឹងមានថ្ងៃបានវិលមកជួបគ្នាវិញបានឡើយ ។ សូមប្អូននៅទីនេះឲ្យបានសុខចុះ បងលាឯងសិនហើយ!

- អាពីង ឯងនៅអង្គុយសញ្ជប់សញ្ជឹងដល់ណាទៀត យើងត្រឡប់ទៅវិញ!

- ខ្ញុំមិនចង់ទៅផ្ទះវិញទេ ខ្ញុំចង់នៅកំដរវានៅទីនេះមួយយប់សិន ។

- មិនបានទេ អាពីង នាំតែអង្គការចោទយើងថាយ៉ាងនេះយ៉ាងនោះទៀតទេ មកយើងទៅវិញ ចាំថ្ងៃណាទំនេរយើងមកលេងនឹងវាទៀបានហើយ ។

ខ្ញុំក្រោកដើរទាំងល្ហិតល្ហៃក្នុងខ្លួន បងប៉េង អូសដៃខ្ញុំដូចកូនក្មេងអីចឹង ។

- បង យុវជន និងយុវនារីនៅស្រុកហ្នឹងហាក់ដូចជាស្អប់ខ្ពើមយើងខ្លាំងម្ល៉េះបង? ពេលយើង យក អាប៉ក់ មកអម្បាញ់មិញ អ្នកទាំងអស់ឃើញយើង នាំគ្នាខកស្ដោះធ្វើបុកដូចខ្ពើមរអើមយើងខ្លាំងណាស់ ។ កាលពីថ្ងៃមុនអង្គការថ្នាក់ឃុំមកប្រជុំនៅភូមិយើងបានថ្លែងថា បដិវត្តន៍ល្អផូរផង់ ដែលកើតចេញពីវណ្ណៈកម្មករកសិករ ហើយគ្មានវណ្ណៈខ្ពស់ទាបដូចរបបមុនៗទេ ។ ចុះហេតុអ្វីអ្នកទាំងនោះ ហៅយើងថា ប្រជាជនថ្មី ឬអ្នក១៧មេសា ចំណែកអ្នកម្ចាស់ភូមិស្រុកហៅប្រជាជនចាស់ ឬអ្នកមូលដ្ឋានទៅវិញ នេះមិនមែនជាការបែងចែកវណ្ណៈទេឬបង?

- នែ៎ឯងកុំឆ្ងល់ច្រើនពេក! នេះឆ្ងល់ត្រឹមបងបាន តែបើឆ្ងល់ហើយហ៊ានក្រោកឈរសួរនៅពេលប្រជុំនោះ ឯងនឹងមានវាសនាអក្រក់ជាមិនខានឯងដឹងទេ? **(តទៅលេខក្រោយ)**

**ឌុំ សុភា**

# ដំណើរភៀសខ្លួនឆ្លងដែនពីរបបកម្ពុជាប្រជាធិបតេយ្យ

***រឿងពិតរបស់ ជា សីហា***

***(តពីលេខមុន)***

ក្រៅពីយំសោកសង្រេងស្តាយមិត្តរួមដំណើរដ៏ស្មោះស្ម័គ្រ តើខ្ញុំអាចធ្វើអ្វីបានលើសពីនេះ បើខ្លួនប្រាណរបស់ខ្ញុំស្ថិតនៅមាត់ជ្រោះមរណៈនៅឡើយ ។ ខ្លួនខ្ញុំរហិតរហៃទន់ ដៃទន់ ជើងស្ទើរនឹងដេកដួលលើដីជាថ្មីទៀត ។ ប៉ុន្តែ ចិត្តតស៊ូអត់ធន់ ដូចព្រះជនក ក្នុងរឿងជាតកត្រង់វិរិយបារមី ។ ទ្រង់តាំងចិត្តថា ទោះបានមួយជំហានទៀតក្តីមុននឹងស្លាប់ក៏ត្រូវតែធ្វើកុំឲ្យសេចក្តីស្លាប់មកយកជីវិតរបស់យើងដោយពុំបានតស៊ូសោះ ។ សេចក្តីផ្ទុយព្រោះអត់កម្លាំងនាំឲ្យខ្ញុំចង់ប្រះខ្លួនដេក ប៉ុន្តែ ខ្ញុំខំអត់ធ្មត់ ហើយបោះជំហានទៅមុខទៀត ។ បានចម្ងាយប្រមាណ១០ម៉ែត្រ ខ្ញុំប្រះខ្លួនដេកម្តង ។ នៅពេលខ្ញុំដឹងខ្លួន ខ្ញុំខំប្រឹងងើបដើរទៅមុខទៀត ។

ខ្ញុំប្រព្រឹត្តដូច្នេះអស់ជាច្រើនថ្ងៃបន្ទាប់មក ។ ខ្ញុំសង្កេតឃើញថា សត្វម្តាយស្ងួន ដែលស្រែកយំកក្អាកកក្អាយជារៀងរាល់ថ្ងៃនោះ ស្រាប់តែបាត់លែងឮសំឡេងនោះទៀត ។ ដោយកុសលផលបុណ្យរបស់ខ្ញុំ ភ្លៀងចាប់ផ្តើមធ្លាក់មកស្ទើរតែរៀងរាល់ថ្ងៃលើព្រៃនាមដូនសំ និងភ្នំម៉ាឡៃ ប៉ុន្តែ ជាភ្លៀងមានតំណក់ទឹកតូចៗ និងរយៈពេលខ្លី ។ ទោះបីជា ពុំមែនជាភ្លៀងធំ ក៏បានធ្វើឲ្យបរិយាកាសមានសំណើម និងឲ្យធាតុអាកាសពុំសូវក្តៅហួតហែងខ្លាំងពេក ។ គ្រប់ពេលក្រោយភ្លៀងម្តងៗ ខ្ញុំតែងដើរលិទ្ធតំណក់ទឹកដែលជាប់នៅលើស្លឹកឈើ ។ បើមានដើមឫស្សី តំណក់ទឹកភ្លៀងតែងដក់ក្នុងសំបកដើមឫស្សីដែលរបកធ្លាក់មកលើដី ។ ទឹកនោះមានបរិមាណច្រើនជាងទឹកដែលនៅជាប់លើស្លឹកឈើ ។ ពុំមានទឹកដក់នៅលើដីទេ ។ ក្រោមតំណក់ទឹកភ្លៀងជារៀងរាល់ថ្ងៃ ទោះបីពុំបានបរិភោគក្តី ក៏បានសម្រន់ការស្រេកទឹកខ្លះដែរ ។ ខ្ញុំដើរតែម្នាក់ឯងលេចវាលចូលព្រៃដូចក្នុងរឿងព្រេង ។ ពេលយប់ក៏ដេកតែម្នាក់ឯងមិនរើសទីកន្លែង ហើយក៏មិនដែលមានអារម្មណ៍ខ្លបខ្លាចអ្វីដែរ ។ ក្រៅពីការស្រេកទឹក និងការឃ្លានអាហារ ពុំមានសត្រូវណាមកយាយីដល់រូបកាយខ្ញុំឡើយ ។ ខ្ញុំស្រឡាញ់ទេសភាពព្រៃភ្នំដែលមានកូនភ្នំរកេតរកូត មានជ្រលងជង្ហុកអូររាក់ៗ មានដងព្រៃស្រោងបាំងបិទពន្លឺព្រះអាទិត្យ មានព្រៃឫស្សី មានវាលស្បូវដ៏ល្ហល្ហេវ មានសម្រែកបក្សី និងពួកមិគជាតិ មានវល្លិតូចធំ ប្រទាក់ប្រទាញប្រទង់ពីដើមមួយទៅដើមមួយ មានវល្លិខ្លះ មានរូបរាងដូចសត្វពស់ ដូចខ្សែពួរដូចបន្ទះស្បែក មានវល្លិផ្កាតូចធំជាច្រើនប្រភេទអាចយកមកធ្វើជាគ្រឿងសម្ភារិម ជាគ្រឿងតុបតែងផ្ទះ ជាកញ្ច្រែង កញ្ឆើ ល្អីបានតាមតម្រូវការ ។ នៅពេលខ្ញុំបានជួបប្រទះវល្លិទឹកម្តងៗ ខ្ញុំត្រេកអរហាក់បានឃើញអាហារពិសេសម្យ៉ាងដែលអាចស្រោចស្រង់ជីវិតខ្ញុំបាន ។ ថ្ងៃមួយ ខ្ញុំជួបកូនភ្នំមួយពោរពេញដោយផ្ទាំងថ្មធំៗ មានថ្មដាជាដើម ។ តាមកម្លាំងកាយរបស់ខ្ញុំ ខ្ញុំពុំគួរហ៊ានដើរកាត់កូនភ្នំនោះទេ ប៉ុន្តែដោយសេចក្តីស្រឡាញ់ទេសភាព និងផ្ទាំងថ្មធំៗនេះ ខ្ញុំក៏ដាច់ចិត្តដើរឡើងតាមចន្លោះថ្មបន្តិចម្តងៗ ខ្ញុំឡើងទៅដល់ផ្ទៃរាបលើខ្នងភ្នំ ។ ខ្ញុំដាក់គូទអង្គុយលើថ្មដា ។ ខ្ញុំលើកដៃបន់ស្រន់ដល់ពួកទេពនិករ សូមលោកប្រទាននូវរុក្ខជាតិ ឬផល្លានុផលអ្វីដែលអាចបរិភោគបានឬយ៉ាងហោចណាស់ស្លឹកថ្មីងក៏បានដែរ ។ មាត់ខ្ញុំពោលពាក្យបន់ស្រន់ ភ្នែកខ្ញុំសម្លឹងរំពៃរកមើលតាមកន្ទុកកន្ទៀតថ្មក្រែងពើបប្រទះអ្វីដែលអាចជាអាហារបាន ។ តាមផ្លូវធ្វើដំណើរមក ខ្ញុំធ្លាប់រើសបានគ្រាប់ធញ្ញជាតិដែលនៅលាយឡំជាមួយផ្លូវធ្វើដំណើរមក ខ្ញុំធ្លាប់រើសបានគ្រាប់ធញ្ញជាតិដែលនៅលាយឡំជាមួយដី និងកម្ទេចកម្ទីនៃមែករុក្ខជាតិ ខ្ញុំពុំអាចស្គាល់ថា គ្រាប់នោះ ជាគ្រាប់រុក្ខជាតិអ្វីដែលមានទំហំប៉ុនគ្រាប់ព្រីងហើយមានឱជារសឈ្ងុយឆ្ងាញ់នោះទេ ។ ដោយស្រេកឃ្លានដៃខ្ញុំតែងវែកស្ទាបរាវរកក្រែងប៉ះនឹងវត្ថុដែលអាចបរិភោគបាន ។ នៅមិនឆ្ងាយប៉ុន្មានពីខ្ញុំ ខ្ញុំឃើញវល្លិតូចមួយប្រវែងប្រមាណមួយតឹកដែលមានស្លឹក និងដើមពណ៌ខៀវខ្ចីតូច ឆ្មារដុះចេញពីស្នៃជាប់ពីលើថ្ម ។ ខ្ញុំដកវល្លិនោះ យកមកដាក់ក្នុងមាត់ហើយញេញ ។ វល្លិនោះមានក្លិន និងរសជាតិដូចវល្លិថ្នឹង ។

ខ្ញុំក៏នឹកដល់ការបន់ស្រន់របស់ខ្ញុំថា មានប្រសិទ្ធភាព ប៉ុន្តែ ទាស់ត្រង់ថា វល្លិនោះតូចពេក មិនអាចឲ្យស្បៀបជើងធ្មេញខ្ញុំបានផង ។ នៅឯនាយដែលមានចម្ងាយប្រមាណ៥០ម៉ែត្រពីខ្ញុំ ខ្ញុំឃើញខ្លាដំបងជំទង់មួយដើរចេញពីដងព្រៃ ហើយស្ទុះចូលទៅក្នុងព្រៃវិញយ៉ាងរហ័ស នៅពេលវាឃើញខ្ញុំនៅទីនោះ ។ ខ្ញុំប្រះខ្លួនដេកលើថ្មដា ភ្នែករំពៃមើលរុក្ខជាតិ និងលតាជាតិនៅពីលើខ្ញុំ ។ វល្លិម្យ៉ាងមានរូបរាងដូចខ្លួនពស់ថ្លាន់ ខាងចុងវល្លិដូចក្បាលពស់ រេចុះរេឡើងពីលើខ្ញុំតាមចលនាខ្យល់បក់ ។ ខ្ញុំធ្លាប់ឮចាស់ៗតំណាលថា នៅក្នុងព្រៃមានវល្លិម្យ៉ាងមានសណ្ឋានដូចពស់ថ្លាន់ឈ្មោះថា វល្លិថ្លាន់ ។ វល្លិនេះរឹងមាំស្វិតពុំអាចកាត់ផ្ដាច់ពីគ្នាដោយកាំបិត ពូថៅ បានទេ លុះណាតែមានគ្រូមន្តអាគមន៍បេះសូត្រផ្លុំបន្ទន់ទើបកាត់ផ្ដាច់បាន ។ វល្លិនោះសម្រាប់ធ្វើថ្នាំគង់ឲ្យមនុស្សផឹក ដើម្បីមានស្បែកស្វិតកាប់មិនមុត ។ នេះគ្រាន់តែជាពាក្យតំណាល ។ នៅពេលនោះ ខ្ញុំពុំមានកម្លាំងដើម្បីសាកល្បងលើវល្លិនោះទេ ។

មកដល់ថ្ងៃទីដប់ នៃដំណើររត់គេចខ្លួនរបស់ខ្ញុំ ។ ខ្ញុំដើរផងដេកផង ទាំងហេវហត់សំដៅទៅទិសខាងលិច ។ ថ្ងៃនោះ ខ្ញុំទៅដល់ភ្នំមួយទៀត ។ ខ្ញុំដើរឡើងភ្នំទាំងលំបាកត្រដាបត្រដួស ពីព្រោះពុំមានផ្លូវវាង ។ នៅពេលរសៀល នៅត្រង់ចង្កេះភ្នំ ខ្ញុំប្រទះឃើញមានធុងទឹកមួយធ្វើពីដែកស័ង្កសីចំណុះមួយម៉ែត្រគ្រីគុណតម្កល់នៅទីនោះ ។ ខ្ញុំនឹកថា ជាធុងទឹករបស់អ្នកកាប់ឈើជំនាន់មុនសង្គ្រាម ។ ខ្ញុំសាកល្បងមួលក្បាលមាន់បើកឲ្យទឹកចេញ ។ ទឹកមិនឃើញចេញមកសោះ ។ ខ្ញុំអស់សង្ឃឹមដោយនឹកថា ក្នុងធុងនោះពុំមានសល់ទឹកទេ ។ ខ្ញុំខំប្រមូលកម្លាំងចំទើតជើងអើតមើលតាមមាត់ធុងចំហ ខ្ញុំឃើញមានសល់ទឹកនៅបាតធុង ។ ខ្ញុំឱនយកមាត់ទៅជួប់នឹងក្បាលមាន់របស់ធុង ហើយប្រឹងផ្លុំខ្យល់ពេញទំហឹង ស្រាប់តែលាន់ឮភុស ហើយទឹកហូរចេញពីក្បាលមាន់ ។ ខ្ញុំប្រញាប់យកមាត់ត្រងទឹកលេបចម្អែតកាយដោយសោមនស្ស និងពោរពេញដោយសេចក្ដីសង្ឃឹម ។ ខ្ញុំឆ្អែតពេញពោះ ដាក់ទឹកពេញកា ហើយក៏ប្រះខ្លួនដេកក្រោមរំហូរទឹកចេញពីក្បាលមាន់បន្តទៀត រហូតដល់ទឹកលែងចេញ ។ ខ្ញុំមានកម្លាំងព្រឺស ហាក់ដូចបានទទួលទឹកអម្រឹតមកពីឋានសួគ៌ ។ បានទឹកចំពើបមាត់បំបាត់សេចក្ដីស្រេក បណ្ដាលចិត្តឲ្យចង់ពាធាជីវិតសតូដទៃទៅតាមសេចក្ដីលោភ ។ ស្រាប់តែមាត់ខ្ញុំបញ្ចេញខទាន ដើម្បីសុំដូនសំជាម្ចាស់ព្រៃឲ្យដាក់ទានសត្វអណ្ដើកមួយយកមកធ្វើអាហារ ។ ស្មើរតែបញ្ចប់ឃ្លាពុំទាន់ស្រួលបួលផង ជើងឆ្វេងរបស់ខ្ញុំរអិលធ្លាក់ចូលក្នុងរណ្ដៅចម្រូងធ្វើឲ្យចម្រូងឫស្សីចាក់ទម្លុះបាតជើងខ្ញុំ ពីក្រោមធ្លាយមកខ្នងជើងលេចចុងចម្រូងមុតស្រួចប្រឡាក់ឈាមឆ្លោឡើង ។ តាមប្រតិកម្មធម្មជាតិ ខ្ញុំក៏លូកជើងស្ដាំទៅក្នុងរណ្ដៅទៀត ហើយផ្ដួកខ្លួនមកខាងក្រោ ។ ជើងស្ដាំខ្ញុំក៏ត្រូវចម្រូងមុតស្រួចមួយទៀត ចាក់កប់ក្នុងស្នូងជើងពីចំហៀងខាងក្នុង ។ ជើងខ្ញុំទាំងពីរត្រូវចម្រូងមុតជាប់ក្នុងរណ្ដៅ ។ ខ្ញុំខំប្រមូលអារម្មណ៍របស់ខ្ញុំឲ្យនឹងនរ ហើយគិតគូររកឧបាយ ដើម្បីរំដោះជើងទាំងគូឲ្យរួចផុតពីរណ្ដៅមរណៈនេះ ។ ខ្ញុំនឹកថា បើខ្ញុំដកជើងខ្ញុំពីចម្រូងមុខជានឹងឈាមហូរខ្លាំង តើខ្ញុំត្រូវទប់យ៉ាងដូម្ដេច? រំពេចនោះ ស្រាប់តែលាន់ឮសំឡេងមនុស្សរអ៊ិះរអ៊ុះពីខាងក្រោមជម្រាលភ្នំ ធ្វើឲ្យខ្ញុំមានចិត្តត្រេកអរ ដោយនឹកថា បានពួកសេរីការរបស់តា អ៊ុន តាំ មកជួយសង្គ្រោះខ្ញុំជាពុំខាន ។ ខ្ញុំដេកនៅស្ងៀមរង់ចាំអ្នកសង្គ្រោះមកដល់ទាំងអាការៈឈឺចុកពើត ។ សំឡេងកាន់តែខិតជិតមក ទើបខ្ញុំដឹងថា មានមនុស្សកំពុងច្រៀងចម្រៀងបដិវត្តន៍របស់ខ្មែរក្រហម ។ ខ្ញុំមានចិត្តភិតភ័យ ហើយស្ទុះស្ទាដកជើងចេញពីចម្រូងទាំងស្ទន់ស្ទោ ។ យោធាខ្មែរក្រហមពីរនាក់លេចក្បាលតាមចន្លោះព្រៃសំដៅមកទីកន្លែងដែលខ្ញុំជួបគ្រោះថ្នាក់ ។ ខ្ញុំដេកផ្កាប់មុខធ្វើពុតជាស្លាប់ ប៉ុន្តែមាត់ខ្ញុំខំភាវនាធម៌ដោយមិនឲ្យឮសំឡេងថា ន.ម.អ. ម.អ.ឧ.ន អ.ឧ.ន.ម ឧ.ន.ម.អ រួចហើយសូត្រ ពុទ្ធំបាំងចក្ខុ ធម្មំបាំងចក្ខុមិ សង្ឃំបាំងចក្ខុមិ ។ ទោះបីខ្ញុំខំភាវនាធម៌យ៉ាងនេះក្ដី ក៏គង់មានចិត្តស្ញើបព្រឺដោយនឹកថា យោធាខ្មែរក្រហមទាំងពីរនេះ នឹងមកផ្ដាច់ជីវិតខ្ញុំឥឡូវនេះជាពុំខាន ។ មួយស្របក់ក្រោយមក ចម្រៀងរបស់ទាហានអាវខ្មៅរស្ងាត់ឆ្ងាយបន្តិចម្ដងៗពីត្រចៀកខ្ញុំទៅ ។ ខ្ញុំនឹកថា ធម៌ដែលខ្ញុំភាវនាពិតជាស័ក្ដិសិទ្ធិប្រាកដមែន ឬមួយមានទេព្ដា ឬទេពារក្សមកជួយបំបាំងកាយរបស់ខ្ញុំពីភ្នែកយោធា ឬមួយក៏យោធានេះខ្ជិលខ្ជាដោយស្មានថា រូបខ្ញុំជារូបអសុភ ។ យោធាដើរឡើងភ្នំទៅបាត់ ។ ខ្ញុំស្រវាក្រោកឡើងយ៉ាងប្រញាប់ ឈាមហូរចេញពីមុខរបួសរបស់ខ្ញុំក្រហមប្រាលលើដី ។ ខ្ញុំមើលទំហំមាត់រណ្ដៅចម្រូងដែលខ្ញុំទើបនឹងបានរំដោះខ្លួនចេញអម្បាញ់មិញនេះ ។ រណ្ដៅនោះ គេជីកនៅក្រោមគុម្ពស្បូវហើយគេទាញស្លឹកស្បូវមករាយគ្របពីលើ ។ នៅ

ខាងក្នុងរណ្តៅមានចម្រូងឫស្សីប្រាំ ប្រាំមួយប៉ុនបីធ្នាប់ប្រវែងប្រមាណ១ម៉ែត្រ ។ ចម្រូងឫស្សីបែបនេះ ជាចម្រូងខ្លាតធំអាចសម្លាប់ មនុស្ស ឬសត្វចតុប្បាទបាន ។ មានចម្រូងមួយបែបទៀតធ្វើអំពីឫស្សីដែរ ប៉ុន្តែ មានប្រវែងខ្លី ប្រមាណបីទៅបួនតឹកកប់ក្នុងរណ្តៅរាក់ៗ ។ ចម្រូងធុននេះ ពុំសូវមានគ្រោះថ្នាក់ទេ ព្រោះគេច្រើនមើលឃើញ ។ ខ្ញុំវាស់ស្ទង់មាត់រណ្តៅថា ល្មមឲ្យខ្ញុំអាចបោះជើង វិលទៅម្ខាងបានដើម្បីបង្ការជាយថា ហេតុក្រែងមានពួកយោធាខ្មែរក្រហមតាមដានឈាមរបស់ខ្ញុំ ។ ខ្ញុំរំកិលគូទចុះតាមជម្រាលភ្នំត្រង់ទៅក្រោម រំលងមាត់ចម្រូង ។ បានចម្ងាយប្រមាណ ៥០ម៉ែត្រ ខ្ញុំថយក្រោយបញ្ឆិតឡើងទៅលើជម្រាលភ្នំ ដោយយកដៃបោចស្លឹកឈើវាប់លុបស្នាមឈាមរបស់ខ្ញុំ ។ បានមួយសន្ទុះទៀត ទើបខ្ញុំឈប់ ហើយរុំរបួសជើងទាំងពីររបស់ខ្ញុំ ដោយហែកក្រមាជាបន្ទះសម្រាប់រុំ ហើយយកស្លឹកដើមទន្ទ្រានខែត្រមកទំពា ហើយបិទលើមុខរបួស ។ មួយសន្ទុះក្រោយមកទៀតទើបឈាមឈប់ហូរ ។ ខ្ញុំខាតបង់ឈាមអស់ជាច្រើន ។ ខ្ញុំប្តូរក្រណាត់ក្រមារុំជាថ្មីម្តងទៀត ទើបរំកិលគូទចុះតាមជម្រាលភ្នំទៅទិសម្ខាងផ្សេងទៀត ។ ខំបត់បែនដំណើររបស់ខ្ញុំចុះឡើងៗយ៉ាងនេះដើម្បីបង្វែងដាន ។ រូបកាយរបស់ខ្ញុំទទួលរងគ្រោះថ្មីមួយទៀត បន្ថែមពីលើភាពស្គមស្គាំងហេវហត់របស់ខ្លួនខ្ញុំ ដែលដាច់អាហាររឹងអស់ដប់ថ្ងៃមកហើយ ។ កម្មពៀរអ្វីបណ្តាលឲ្យរូបខ្ញុំទទួលទុក្ខលំបាកធ្ងន់ធ្ងរយ៉ាងនេះ ឬមួយជាកម្មពៀរដែលខ្ញុំបានបាញ់សម្លាប់សត្វ កាលពីយុវវ័យរបស់ខ្ញុំ ឬមួយតាំងពីបឋមវ័យដែលខ្ញុំបានចាប់ក្តាម ចាក់កង្កែប និងសត្វដទៃទៀត សម្រាប់ធ្វើអាហារ ឬក៏ជាបាបកម្មតាំងពីជាតិមុនៗមក? ។ ទោះបីបាបកម្មរបស់ខ្ញុំដែល បានប្រព្រឹត្តតាំងពីណាមកក៏ដោយ ឥឡូវនេះខ្ញុំកំពុងទទួលផលនៃបាបកម្មទាំងនោះហើយ ។ តើទារុណកម្មឥឡូវនេះ ដែលខ្ញុំកំពុងទទួលជាផលនៃបាបកម្ម ដែលខ្ញុំបានប្រព្រឹត្តពីអតីតកាលនឹងបញ្ចប់នៅពេលណា និងយ៉ាងដូចម្តេច?

ការកកិលគូទ ជារបៀបធ្វើដំណើររបស់ខ្ញុំមានល្បឿនប្រមាណ ១គីឡូម៉ែត្រក្នុងមួយថ្ងៃទៅកាន់គោលដៅពុំជាក់លាក់ ។ មុនពេលចេញដំណើរ ខ្ញុំប៉ងថា ទៅព្រៃតស៊ូ ឬទៅរកពួកសេរីកា ដើម្បីវិលមករំដោះ ស្រុកទេសពីពួកបដិវត្តន៍ព្រៃផ្សៃនេះវិញ ។ ឥឡូវខ្ញុំកំពុងតស៊ូជាមួយ សេចក្តីស្លាប់ ។ កាលពីថ្ងៃមុនសហសេរីកក៏កម្សត់កម្រទាំងពីរនាក់របស់ខ្ញុំគឺពុក គឹម និងហ៊ា ឡាយ បានស្លាប់រួចមកហើយ នៅសល់តែខ្ញុំម្នាក់ឯង ដែលខំត្រដររស់យ៉ាងលំបាកតទៅទៀត ។ រស់ដើម្បីអ្វី បើពុំបានបម្រើជាតិ និងសាសនាដូចពាក្យដែលខ្ញុំបានសច្ចានៅចំពោះវិញ្ញាណក្ខន្ធនៃបុព្វបុរសក្នុងប្រាសាទបាក់បែកគោកប្រដាក មុនពេលចេញដំណើរពីសហករណ៍ស្នួលកោង ។ ខ្ញុំកកិលគូទតគ្រុករុកព្រៃទាំងថ្ងៃទាំងយប់ដោយដេកផង ធ្វើដំណើរផង គ្មានពេលកំណត់ ។ អាហារបានមកពីកម្ទេចឈើ និងគ្រាប់ផ្លែឈើដែលកប់ក្នុងដី ។ ទឹកបានមកពីទឹកសន្សើម និងតំណក់ទឹកភ្លៀងដែលជាប់លើស្លឹកឈើ ។ ថ្ងៃណាគ្មានភ្លៀងជាថ្ងៃដែលខ្ញុំត្រូវសេចក្តីស្លាប់គំរាមកំហែង ។ ភ្លៀងមានស្ទើរតែរាល់ថ្ងៃ ប៉ុន្តែមានចំនួនតិចតួចពុំអាចដក់ជាថ្លុកបានឡើយ ។ ថ្ងៃមួយខ្ញុំធ្វើដំណើរកាត់វាលស្មៅដែលមានដើមឈើមួយៗដាច់ឆ្ងាយពីគ្នា ។ ខ្ញុំសម្លឹងឃើញមេឃខៀវស្រងាត់ដោយអស់សង្ឃឹម ព្រោះ ជាពេលរសៀលទៅហើយ ។ ខ្ញុំស្រែកអំពាវនាវដល់ពួកទេវតាថា ព្រះអង្គអើយ! បើគ្មានភ្លៀងធ្លាក់នៅល្ងាចនេះទេ ខ្ញុំមុខជានឹងស្លាប់ពុំខានឡើយ ។ សូមទេវតាប្រោសប្រទានទឹកភ្លៀងឲ្យខ្ញុំ ដើម្បីបានរស់តទៅទៀត ។ ស្រាប់តែខ្ញុំមានអារម្មណ៍ថា ដូចជា មានអ្វីនៅក្រោមគូទរបស់ខ្ញុំ ។ ខ្ញុំលូកដៃស្ទាបរកមើល ស្រាប់តែប្រទះនឹងផ្លែឈើចំនួនពីរផ្លែ ។ ផ្លែនីមួយៗមានពណ៌លឿងស្ទែត មានទំហំប្រមាណប៉ុនផ្លែក្រសាំងធុនធំ ។ ខ្ញុំពុំស្គាល់ផ្លែទាំងនោះទេប៉ុន្តែ សេចក្តីស្រេកឃ្លានបង្ខំខ្ញុំឲ្យបរិភោគ ។ ខ្ញុំពុំហ៊ានបរិភោគភ្លាមទេ ខ្ញុំខាំផ្លែនោះ សាកល្បងមើលសិន ។ ផ្លែនោះមានរសឆ្ងាញ់ មានរសផ្អែមឡូមៗ ។ ខ្ញុំលេបទឹកផ្លែឈើដែលជាប់នឹងធ្មេញរបស់ខ្ញុំ ។ មួយសន្ទុះក្រោយ ខ្ញុំខាំយកសាច់ផ្លែឈើមួយដុំតូចមកទំពាលេប ។ មួយស្របក់ក្រោយមកទៀត ខ្ញុំយល់ឃើញ ថា ពុំមានប្រតិកម្មអ្វីនៅក្នុងខ្លួនរបស់ខ្ញុំទេ ខ្ញុំក៏បរិភោគផ្លែនោះអស់មួយភាគបីនៃទំហំរបស់វា ។ ខ្ញុំរង់ចាំសង្កេតមើលប្រតិកម្មរបស់ខ្លួនប្រាណខ្ញុំអស់ប្រមាណមួយសន្ទុះធំឥតមានអ្វីកើតឡើងទេ ។ ខ្ញុំក៏បរិភោគអស់ផ្លែទាំងពីរ ។ ផ្លែនោះពីខាងក្រៅរុំព័ទ្ធដោយសំបកទន់ដូចផ្លែត្របែក នៅពីក្នុងសំបកមានសរសៃសាញដូចសាញនោង ហើយមានសាច់ជ្រាយដូចផ្លែប៉ោមផុស ។ ខ្ញុំបានបរិភោគផ្លែឈើជាលើកទីមួយរបស់ខ្ញុំតាំងពីខ្ញុំចេញដំណើរមក គឺជាផ្លែឈើមិនស្គាល់ឈ្មោះដែលមានរសជាតិឆ្ងាញ់ ហើយពុំឃើញមានដើមរបស់វា

នៅជិតនោះទេ ។ នេះហើយជាសំណាងរបស់ខ្ញុំ ឬក៏ជាទេព្តាប្រទាន ។ ខ្ញុំបន្តដំណើរ ខ្វាសៗដូចអណ្តើកវារកាត់វាលស្មៅទៅមុខទៀត ។ ដល់ពេលល្ងាច ខ្ញុំឃើញផ្លែឈើទុំក្រហមធ្លាក់ក្រាលពេញដី ។ ផ្លែទាំងនោះមានទំហំប៉ុនមេដៃ ។ ដើមរបស់វាមានកម្ពស់ប្រហែលនឹងដើមអំពិលទឹក ។ ខ្ញុំរើសយកផ្លែវាមួយគ្រាប់មកលិទ្ធមើលរសជាតិរបស់វាជាផ្លែមានរសផ្អែមល្ងឹង ។ ខ្ញុំអង្គុយសង្កេតមើលសត្វស្លាបតូចៗដែល ហើរប្រវាត់កាត់ទីនោះ ។ សត្វខ្លះចឹកផ្លែទុំទម្លាក់មកដី ប៉ុន្តែ ពុំបរិភោគផ្លែទាំងនោះទេ ។ ខ្ញុំធ្លាប់ឮចាស់ៗផ្តាំថា ឃើញសត្វមិនស៊ីផ្លែឈើនោះទេ ចូរកុំប្រថុយបរិភោគផ្លែនោះឲ្យសោះ វាមានជាតិពុល ។ តាមពាក្យបណ្តាំនោះ ខ្ញុំពុំហ៊ានបរិភោគផ្លែនោះទេ ទោះបីរូបរាងរបស់វាទាក់ទាញភ្នែករបស់ខ្ញុំយ៉ាងណាក៏ដោយ ។ របួសជើងរបស់ខ្ញុំចាប់ផ្តើមហើមតឹង ហើយឈឺពើតម្តងៗ ។ ខ្ញុំធ្វើដំណើរទាំងដេក ទាំងភ្ញាក់ដោយមានសម្បជញ្ញៈជាប់ជានិច្ចថា ត្រូវតែទៅមុខធ្វើដំណើរឲ្យបានមួយថ្ងៃមួយគីឡូម៉ែត្រ ។ ខ្ញុំប៉ាន់ប្រមាណចម្ងាយពីកន្លែងដែលខ្ញុំស្ថិតនៅទៅព្រំដែនថៃពុំលើសពីពាគីឡូម៉ែត្រឡើយ ។ ភ្នែកខ្ញុំតែងរំពៃរកទឹកដក់ ព្រោះភ្លៀងធ្លាក់មកស្ទើររាល់ថ្ងៃ ។ ជួនកាលមានសត្វមេអំបៅទំគរលើគ្នាពីលើដីដូចផ្ការីក ។ ខ្ញុំនឹកថា ទីនោះពិតជាមានទឹកដក់ពីក្រោមមេអំបៅជាពុំខាន ។ ខ្ញុំយកដៃវែកមេអំបៅដូចវែកត្របកផ្កាមើលក្រែងមានទឹកពីក្រោម ប៉ុន្តែ គ្មានទឹកសោះ ប្រហែលជាអាចមាន ចំហាយទឹកទើបពួកមេអំបៅទាំងនោះមកជប់ចំហាយនោះដើម្បីបំបាត់ការស្រេករបស់ពួកវា ។ ស្អែកឡើង ខ្ញុំទៅដល់ព្រៃស្រោង ។ ព្រៃស្រោងមានដើមឈើខ្ពស់ៗ និងមានដើមតូចៗដុះប្រជ្រៀតគ្នាពីក្រោម ។ ព្រៃដូចនេះ ខ្ញុំអាចមានសំណាងបានប្រទះវល្លិទឹក ។ ទោះបីមានវល្លិទឹក ប៉ុន្តែ បើវាស្ថិតនៅខ្ពស់ផុតពីដៃ ក៏ខ្ញុំពុំមានលទ្ធភាពនឹងកាប់វាដល់ដែរ លុះណាតែវល្លិនេះធ្លាក់មកទៀបនឹងដី ។ ម្យ៉ាងទៀត ព្រៃនោះពុំមានចន្លោះធ្វើឲ្យខ្ញុំពិបាករំកិល ។ នៅពេលខ្លះ ខ្ញុំទៅទាល់នឹងព្រៃញឹកឥតច្រកចេញហើយ ដោយខ្ញុំហេវហត់អស់កម្លាំងពេក ក៏ប្រះខ្លួនដេកយកកម្លាំងសិន ។ ខ្ញុំមិនដឹងថាដំណេករបស់ខ្ញុំនោះ មានថេរវេលាប៉ុន្មានទេ នៅពេលដែលខ្ញុំដឹងខ្លួនស្រាប់តែឃើញដានជើងសត្វចតុប្បាទជាន់ជ្រិប្រជ្រៀតគ្នា ទម្ពុះទម្លាយព្រៃទាល់ដែលបានបាំងពីមុខខ្ញុំ ។ គួរឲ្យឆ្ងល់ណាស់ថា តាមចំនួនដានជើងរបស់សត្វទាំងនោះ ឃើញថា សត្វដែលរត់កាត់ទីនោះមានចំនួនច្រើនសិបក្បាល ម្តេចសន្ទឹកនៃជើងសត្វទាំងនោះ ពុំធ្វើឲ្យខ្ញុំ ភ្ញាក់ពីដំណេក? ដោយសារ ដានជើងសត្វទាំងនោះហើយ ទើបធ្វើឲ្យខ្ញុំមានផ្លូវធ្លុះធ្លាយកាត់ព្រៃក្រាស់ទាំងនោះបាន ។ ខ្ញុំកកិលតាមតម្រាយផ្លូវនោះជាប់ជាដរាបមក ព្រោះខ្ញុំយល់ថា សត្វទាំងនោះពិតជា ធ្វើដំណើរទៅរកប្រភពទឹកដែលពួកវាធ្លាប់ស្គាល់ ។ ដូច្នេះ ខ្ញុំនិងសត្វទាំងនោះមានគោលដៅដូចគ្នាមួយ គឺស្វែងរកទឹកបរិភោគ ។ ក្នុងចំណោមដានជើងសត្វទាំងនោះ ខ្ញុំសង្កេតឃើញដានជើងតូចមួយ សមទំនងជាដានកូនក្របី ។ ថាក្របីស្រុកមកដល់ទីនេះ ក៏ពុំសមដែរ ដូច្នេះ មានតែក្របីព្រៃ ។ ខ្ញុំនឹកថា សង្គ្រាមឆាបឆេះមកអស់ជាច្រើនឆ្នាំមកហើយ បានបង្ហិនបង្ហោចសត្វព្រៃស្ទើរគ្មានសល់ ប៉ុន្តែ ឥឡូវក្នុងព្រៃនេះ នៅមានសេសសល់សត្វចតុប្បាទជាច្រើនទៀត មានទាំងក្របីព្រៃផង ។ ខ្ញុំគ្រេកអរចំពោះ វត្តមានរបស់សត្វទាំងនោះ ។ ខ្ញុំលែងបារម្ភអំពីផ្លូវធ្វើដំណើរទៀតហើយ ព្រោះមានផ្លូវស្រាប់ដែលសត្វព្រៃត្រាយទុកឲ្យ ។

ថ្ងៃទីដប់បួននៃដំណើររបស់ខ្ញុំ ខ្ញុំបានមកដល់វាលដ៏ល្ហល្ហេវមួយ ។ វាលនោះ មានផ្ទៃរាបស្មើ មានស្មៅ និងកូនឈើដុះពាសពេញពុំមានដើមឈើធំឡើយ ។ ទទឹងរបស់វាលនេះ មានចម្ងាយប្រមាណមួយគីឡូម៉ែត្រ មានបណ្តោយវែងល្ហឹងល្ហើយប្រមាណមិនបាន ។ ខ្ញុំនឹកឃើញរឿងមួយ កាលណោះ មានរដ្ឋប្រហារទម្លាក់សម្តេចនរោត្តម សីហនុ ពីមុខនាទីជាព្រះប្រមុខរដ្ឋដោយពួកអាមេរិកាំងនិយម ។ មុនពេលនោះ បន្តិចមានពួកខ្មែរសេរីចាប់ទាហានសៀមនិងថៅកែសៀមខាងជំនួញឈើព្រម ទាំងសម្ភារសឹកខ្លះមានទាំងយន្តហោះធុនតូចមួយផង មកប្រគល់ឲ្យកងខេមរភូមិន្ទ រឿងនេះខ្ញុំចងចាំពុំច្បាស់លាស់ទេ (គ្រាន់តែជាការប្រហាក់ប្រហែលប៉ុណ្ណោះ) ។ ខ្ញុំឮថា ពួកខ្មែរសេរីអនុញ្ញាតឲ្យថៅកែឈើសៀមស្តាបនាវាលយន្តហោះមួយ នៅតំបន់ម៉ាឡៃជិតព្រំដែនខ្មែរ-ថៃ ។ ខ្ញុំសន្និដ្ឋាននៅពេលនោះថា វាលនោះហើយពិតជាវាលយន្តហោះរបស់សៀមនៅអតីតតំបន់ត្រួតត្រារបស់ខ្មែរសេរី ។ ខ្ញុំនៅស្ទាក់ស្ទើរពុំហ៊ានឆ្លងកាត់វានោះទេ ព្រោះខ្ញុំគិតថា បើខ្ញុំឆ្លងកាត់ទទឹងវាលនៅព្រឹកនោះ ខ្ញុំត្រូវចំណាយ ពេលមួយថ្ងៃ ។ មួយថ្ងៃ នៅកណ្តាលវាលពិតជាប្រថុយប្រថាននឹងគ្រោះថ្នាក់ពន់ពេកណាស់ ព្រោះនៅជិតព្រំដែនច្បាស់លាស់ជាមានកងទ័ពខ្មែរក្រហមយ៉ាងច្រើនពុំខាន ។ ខ្ញុំដំអក់តាម

ដងព្រៃសិន ដោយនឹកថា ចាំពេលល្ងាចជិតព្រលប់សឹមធ្វើដំណើរចេញទៅ ។ ស្រាប់តែនៅប្រមាណ៣០ម៉ែត្រពីកន្លែង ដែលខ្ញុំអង្គុយ ខ្ញុំឃើញសត្វខ្ទីងមេមួយកូនមួយ នៅស៊ីស្មៅកណ្តាលវាលនោះ ។ មេវាមានស្នែងធំមាំ សម្បុរខ្មៅពាលពីកដល់ឆក សម្បុរសពីត្រឹមជង្គង់ដល់កជើងគ្រប់ជើងទាំងបួន ។ ចំណែកកូនវិញ ជាកូនខ្ទីងដែលមានអាយុប្រមាណមួយអាទិត្យ ។ វាមានសម្បុរត្នោត ។ ខ្ញុំនឹកថា សត្វអ្វីក៏ដោយ កាលបើវាមានកូនខ្ចី វាមានចរិតកាច ព្រោះ វាការកូន ប៉ុន្តែ វត្តមានរបស់វាបានជួយខ្ញុំឲ្យយល់ថា ពុំមានយោធាខ្មែរក្រហមនៅជិតទីនោះទេ ។ ខ្ញុំក៏សម្រេចចិត្តភ្លាមថា ត្រូវតែឆ្លងកាត់វាលនោះឥឡូវនេះ ។ ពេលវេលាមានតម្លៃស្មើនឹងជីវិតរបស់ខ្ញុំ ។ ពីមួយថ្ងៃទៅមួយថ្ងៃ រាងកាយរបស់ខ្ញុំកាន់តែទ្រុឌទ្រោមទៅអាការៈរបួសនៅជើងទាំងពីររបស់ខ្ញុំ កាន់តែហើម និងឈឺចុកចាប់ខ្លាំងឡើង ។ ខ្ញុំពុំគួរពន្យារពេលតទៅទៀតទេ ។ ខ្ញុំកកិលទៅមុខសំដៅសត្វខ្ទីងនោះ ។ សត្វខ្ទីង ហាក់ដូចជាយល់អធ្យាស្រ័យរបស់ខ្ញុំ ហើយអនុគ្រោះឲ្យខ្ញុំបានធ្វើដំណើរទៅជាមួយ ។ ខ្ញុំកកិលទៅមុខសត្វខ្ទីងក៏ខិតទៅមុខនាំកូនស៊ីស្មៅដោយកិរិយាព្រងើយនឹងវត្តមានរបស់ខ្ញុំ ។ រហូតដល់ពេលល្ងាច ខ្ញុំបានទៅដល់ដងព្រៃម្ខាងទៀត ។ ខ្ញុំអាចឆ្លងកាត់វាលបានដោយជោគជ័យ ។ សត្វខ្ទីងទាំងមេ ទាំងកូន បានចូលព្រៃបាត់ទៅ ។ ខ្ញុំក៏ចូលទៅក្នុងព្រៃរកកន្លែងសម្រាក ។ នៅយប់នោះ សំឡេងកាំភ្លើងធំលាន់ឮឆ្លងកាត់ពីលើខ្ញុំទៅផ្ទុះកក្រើកខ្ទរខ្ទារនៅព្រៃខាងក្រោយ ។ រហូតដល់ទៀបភ្លឺទើបស្នូរកាំភ្លើងបានស្ងាត់ ។ ខ្ញុំកកិលទៅមុខជាង ឆៀតដេកយកកម្លាំងខ្លះផង ។ នៅតាមផ្លូវដែលមានដានជើងសត្វ ខ្ញុំសង្កេតឃើញមែកឈើធំៗ ត្រូវគ្រាប់បាក់ទន់មកដី ។ កាលពីយប់មិញ ប្រហែលជាមានការប្រយុទ្ធរវាងកងទ័ពសៀម និងយោធាខ្មែរក្រហម ។ ខ្ញុំដឹងថា ខ្ញុំមកដល់ជិតព្រំដែនខ្មែរ-ថៃហើយ ។ ចិត្តខ្ញុំបារម្ភអំពីដំណើររបស់ខ្ញុំ ។ មុនពេលចេញដំណើរពីផ្ទះខ្ញុំ បានប្ដេជ្ញាថា រត់ចូលព្រៃដើម្បីតស៊ូនឹងរបបខ្មែរក្រហម ។ ឥឡូវនេះ មកដល់ជិតព្រំដែន ខ្ញុំគ្មានជម្រើសអ្វីក្រៅពីឆ្លងដែនទៅប្រទេសថៃទេ ។ ខ្ញុំនឹងទៅជាបុរសកំសាករត់យករួចខ្លួនតែម្នាក់ឯង ទុកឲ្យប្រពន្ធកូនទទួលទារុណកម្មជំនួសខ្លួនឯង ស្រុក ។ ខ្ញុំមិនគួររស់តទៅទៀតទេ រស់ក្នុងជីវិតខ្លោចផ្សារហូតដល់ថ្ងៃស្លាប់ ។ មានចិត្តមួយទៀតគិតថា ទៅស្រុកសៀមទៅឲ្យពេទ្យសៀមព្យាបាលរបួសឲ្យសិន និងរកអាហារបរិភោគឲ្យមានកម្លាំងសឹមរកមធ្យោបាយរំដោះស្រុកពីពួកខ្មែរក្រហមជាថ្មីទៀត ។ កាលពីអំឡុងឆ្នាំ១៩៧៥ ខ្ញុំនិងគ្រួសាររស់នៅទីប្រជុំជននិមិត្ត កូនដំរី ដែលមានចម្ងាយប្រមាណ៦គីឡូម៉ែត្រពីប៉ោយប៉ែត ។ ខ្ញុំមានទំនាក់ទំនងល្អក្នុងមុខរបររកទទួលទានជាមួយឱសថដ្ឋានជាច្រើននៅស្រុកអារញ្ញ ។ ខ្ញុំសង្ឃឹមថា ទៅដល់ទីនោះ ពួកម្ចាស់ឱសថស្ថានទាំងនោះមុខជានឹងយកចិត្តទុកដាក់ទំនុកបម្រុងដល់ខ្ញុំពុំខានឡើយ ។

នៅថ្ងៃទី១៥ នៃដំណើររត់ភៀសខ្លួនរបស់ខ្ញុំត្រូវនឹងថ្ងៃទី២០ ខែមេសា ឆ្នាំ១៩៧៨ ព្រឹកឡើង ខ្ញុំបន្តដំណើររបស់ខ្ញុំដោយកកិលតាមគន្លងផ្លូវជើងសត្វចតុប្បាទដូចធម្មតា ។ ថ្ងៃនោះបរិយាកាសអួរអាប់តាំងពីព្រឹក បន្ទាប់មក ក៏មានភ្លៀងបង្អុរយ៉ាងខ្លាំងជាមួយនឹងខ្យល់បោកបក់កក្រើកព្រៃ ។ ខ្ញុំជ្រកសម្ងំក្រោមដើមឈើមួយដើមដែលមានស្លឹកត្រឈៃ ។ រាងកាយរបស់ខ្ញុំរងាញ័រញាក់ខុសប្រក្រតី ។ តាំងពីចេញដំណើរមកជាលើកទីមួយ ហើយដែលខ្ញុំជួបប្រទះធាតុអាកាសបែបនេះ ។ គ្រាប់ភ្លៀងធ្លាក់ពីលើមេឃដូចស្រោចទឹកមកម៉្លេះលើស្លឹករុក្ខជាតិបានជាសំឡេងកងរំពងគ្រប់ទិសទី ។ ខ្ញុំយកកំណាត់ក្រមា និងកន្សែងយ័ន្តមកត្រដាងលើដី ឲ្យជោកទឹកទើបយកមកជញ្ជក់ ។ ខ្ញុំធ្វើបែបនេះរហូតដល់ឆ្អែត ។ អស់ជាច្រើនថ្ងៃមកហើយ ភ្លៀងធ្លាក់ស្ទើររាល់ថ្ងៃ ប៉ុន្តែ ពុំដែលបានខ្លាំងដូចម្ដងនេះទេ ។ នៅពេលភ្លៀងស្រាក ខ្ញុំចេញដំណើរទៅទៀត ។ នៅតាមផ្លូវ ខ្ញុំហួសម្រែកកង្កែបហ៊ឹងអឹងអាប់ ។ ធម្មជាតិមានសម្រស់គួរគយគន់ ។ ក្ដាមចោតចេញពីរន្ធស្អេកស្កះពេញដី ។ ខ្ញុំចាប់ក្ដាមមកទំពាជញ្ជក់យកជាតិទាំងរស់អស់ក្ដាមពីរ ប៉ុន្តែ ពុំមានរសឆ្ងាញ់ពិសាទេ ។ ខ្ញុំកកិលទៅមុខរហូតដល់ពេលល្ងាច ។ ខ្ញុំទៅដល់មាត់ព្រៃក្រាស់ដែលមានស្បូវ ស្លាព្រៃ អំពៅ និងដើមរុក្ខជាតិធំ តូច ដុះប្រជ្រៀតគ្នាចាក់ស្រែះ ។ ភ្លៀងទើបនឹងរាំងជាប់តំណក់ទឹកនៅហូររីញៗកាត់ស្មៅនៅឡើយ ។ នៅលើផ្លូវជើងមួយ មានដានជើងមនុស្សដើរកាត់ថ្មីៗ ទឹកនៅល្អក់តិចៗ ស្មៅដែលក្រាបកំពុងងើបឡើយវិញ ។ ខ្ញុំមានចិត្តភ័យក្ដុកនឹកដល់វត្តមានរបស់យោធាខ្មែរក្រហម ។ ខ្ញុំសង្កេតឃើញដានជើងបែរមុខមកក្នុងបញ្ច្រាសទិសពីដំណើររបស់ខ្ញុំ ហើយបត់ទៅទិសផ្សេងពីផ្លូវដែលខ្ញុំធ្វើដំណើរមក ។ ខ្ញុំប្រញាប់ប្រញាល់រុលទៅមុខទៀត តាមផ្លូវជើងនោះកាត់ព្រៃរបោះបានប្រមាណ១០ម៉ែត្រ ខ្ញុំឃើញមានប្រឡោះមួយខាងក្រោមព្រៃក្រាស់ ទំនងជារូងដែលគេលុងចូលក្នុង

ព្រៃទំហំប៉ុនមនុស្សដើរឡិន ។ ខ្ញុំកកិលចូលទៅក្នុងច្រកនោះ ដោយប្រថុយប្រថាន ពីព្រោះ ពុំមានជម្រើសផ្សេងទៀត ។ ដោយមានព្រៃក្រាស់គ្របពីលើ នៅក្នុងច្រកនោះមានភាពងងឹតស្លុបមានដានជើងមនុស្សវក់វី ។ ខ្ញុំខំប្រឹងកកិលអស់ពីកម្លាំងកាយ ព្រោះជាកន្លែងគ្រោះថ្នាក់ ។ មិនយូរប៉ុន្មាន ខ្ញុំឃើញពន្លឺព្រាលៗនៅខាងចុង ។ ទៅដល់ចុងរូង ខ្ញុំឃើញមានដើមឈើយ៉ាងធំដេកគងលើមាត់អូរធ្វើជាស្ពានចម្លងទៅម្ខាងអូរ ។ អូរនេះមានទំហំធំស្មើនឹងកូនព្រែក មានជម្រៅយ៉ាងជ្រៅ មានទឹកហូររឹមៗនៅបាតអូរ ។ ខ្ញុំប្រញាប់កកិលលើដើមឈើឆ្លងទៅត្រើយម្ខាង ។ នៅពេលខ្ញុំឆ្លងផុតពីមាត់អូរល្មមនឹងពេលព្រលប់ ។ ខ្ញុំចោលភ្នែកទៅខាងមុខឃើញមានវាលចោទខ្ពស់ជាខ្ពង់រាបមានដើមឈើមួយៗជាឈើហូបផ្លែទំនងជាចម្ការ និងភូមិអ្នកស្រុក ។ នៅខាងមុខជិតៗ មាន ដើមចេក ដើមខ្នុរ ដើមដូង ឆេះរោលខ្មោច ។ ឥតមានលំនៅឋានអ្នកស្រុកទេ ។ តាមទិដ្ឋភាពនៃទឹកកន្លែងនោះ ខ្ញុំដឹងច្បាស់ថា ខ្ញុំចូលដល់ដីសៀមហើយ ព្រោះអូរដែលខ្ញុំទើបនឹងឆ្លងនេះ ជាអូរខណ្ឌព្រំដែនខ្មែរ-សៀម ពិតប្រាកដ ។ ចិត្តខ្ញុំសែនក្តុកក្តួលទឹកភ្នែកហូរហៀរនឹកដល់ស្រុកកំណើត ដល់ប្រពន្ធកូនដល់ម៉ែដល់បងប្អូនដល់ពាក្យសច្ចាថា មិនរត់ចោលស្រុកដែលខ្ញុំបានស្បថ កាលពីខែមេសា ឆ្នាំ១៩៧៥ នៅពេលដែលមិត្តភក្តិមកបបួលឲ្យរត់ទៅស្រុកសៀម ។ ខ្ញុំក្លាយទៅជាមនុស្សទាល់ច្រក មនុស្សអត់តម្លៃ គ្រាន់តែសម្បថមួយគោរពមិនបានផង តើជាតិនេះ ខ្ញុំទៅធ្វើអ្វីនឹងគេកើត? ខ្ញុំលើកដៃទាំងគូដាក់លើបន្ទូលក្បាលបួងទៅដល់វត្ថុស័ក្តិសិទ្ធិក្នុងលោកមានទេព្តាដែលរក្សាប្រទេសកម្ពុជា និងជាពិសេសទេព្តាដែលរក្សាព្រឹក្សព្រៃនេះថា ខ្លួនខ្ញុំពុំបំភ្លេចសម្បថរបស់ខ្ញុំទេ ។ ខ្ញុំពុំមានចេតនារត់ចោលស្រុកកំណើតរបស់ខ្ញុំឡើយ ប៉ុន្តែភាពទាល់ច្រកនៅចំពោះមុខខ្ញុំបង្ខំខ្ញុំឲ្យត្រដររស់ដើម្បីបម្រើជាតិ សាសនា ទៅអនាគត ។ សូមទសបារមីនៃព្រះពុទ្ធជាម្ចាស់ សូមឥទ្ធិឫទ្ធិនៃទេព្តាទាំងពួងដែលខ្លាំងពូកែ ជួយរក្សាខ្ញុំរហូតដល់បានសម្រេចបំណងកុំបីអាក់ខានឡើយ ។ បន្ទាប់មក ខ្ញុំក្រាបសំពះឆ្ពោះមកមាតុភូមិជាទីស្រឡាញ់ថា ខ្ញុំសូមលាអ្នកមួយគ្រាសិន ដោយសេចក្តីស្រណោះអាឡោះអាល័យក្រៃលែង ។ បើខ្ញុំនៅមានជីវិត ខ្ញុំនឹងមកស្លាប់នៅលើទ្រូងរបស់អ្នកវិញជាពុំខាន ។ ខ្ញុំក្រាបសំពះអស់ពេលយ៉ាងយូរ រហូតដល់ព្រលប់ធំ ។ យប់នោះ ជាយប់ដែលមានព្រះច័ន្ទបញ្ចេញពន្លឺត្រចះដូចថ្ងៃ ។ ដោយស្រេកឃ្លាន ខ្ញុំកកិលទៅរកគុម្ពចេក ។ ខ្ញុំចង់កាប់កូនចេកមួយដើម្បីយកមកជញ្ជក់យកទឹក ។ ខ្ញុំរៀបកន្លែងខាងក្រោយខ្នងខ្ញុំឲ្យស្អាត ទើបខ្ញុំផ្ទង់ស្វាយារកាំបិតដ៏មុតថ្វារបស់ខ្ញុំ កាប់ឲ្យចំពាក់កណ្តាលដើម ។ ផ្លែកាំបិតជាប់ក្នុងដើម ខ្ញុំប្រះខ្លួនដេក ដើម្បីសម្រួលដង្ហើម ។ មួយស្របក់ក្រោយមក ខ្ញុំងើបអង្គុយដកកាំបិតចេញពីដើមចេក ប៉ុន្តែពុំត្រូវចំកន្លែងដដែល ត្រូវកន្លែងទីទៃឃ្លាតពីស្នាមមុនប្រមាណមួយតឹកឯណោះ ។ ខ្ញុំប្រះខ្លួនដេកដូចពេលមុនហើយខ្ញុំគិតថា ខ្ញុំពិតជាល្ងង់មែន ។ ខ្ញុំពុំមានកម្លាំងតម្រង់កាំបិតឲ្យចំកន្លែងដដែលបានទេ ។ ខ្ញុំចំណាយកម្លាំងច្រើនឥតអំពើ ។ ខ្ញុំងើបឡើងវិញម្តងនេះខ្ញុំប្រើបច្ចេកទេសថ្មី ។ ខ្ញុំខំដកដង្ហើមឲ្យវែងៗទើបខ្ញុំយកកាំបិតទៅចិញ្ច្រាំតិចៗលើកន្លែងតែមួយ មួយសន្ទុះទើបដើមចេកនោះដួល ។ ខ្ញុំប្រះខ្លួនដេករហូតដល់ខ្ញុំមានកម្លាំងបន្តិចឡើងវិញ ក៏ងើបឡើងកាប់ចិញ្ច្រាំដើមចេកជាថ្មីត្រង់កន្លែងផ្សេង ដើម្បីឲ្យបានដើមចេកមួយកង់ ។ ខ្ញុំបកស្រទបចេកខាងក្រៅចេញយកស្រទបខ្ចីខាងក្នុងមកខាំជញ្ជក់យកទឹក ។ ទឹកដើមចេកមានរសចត់ហើយស្អិតពុំស្រួលលេបដូចទឹកធម្មតាទេ ។ ខ្ញុំប្រះខ្លួនដេកជិតគុម្ពចេកនោះរហូតដល់ភ្លឺ ។

## ទុក្ខសោកនៅស្រុកគេ

ព្រឹកនេះចូលដល់ថ្ងៃទី១៦ នៃដំណើររត់ភៀសខ្លួនរបស់ខ្ញុំ គឺត្រូវនឹងថ្ងៃទី២១ ខែមេសា ឆ្នាំ១៩៧៨ ។ បុណ្យចូលឆ្នាំមមីកន្លងទៅបានមួយអាទិត្យហើយ ។ ខ្ញុំនៅលើទឹកដីសៀមបានមួយយប់ ។ ស្ថានភាពចាំបាច់តម្រូវឲ្យខ្ញុំយកទឹកដីបរទេសនេះ សម្រាប់រំដោះខ្លួនពីរបបព្រៃផ្សៃនៃកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម ។ ចិត្តខ្ញុំគិតស្លុងទៅរកអនាគតដ៏ខ្លីខាងមុខនេះ ។ តើពួកសៀមមានមេត្តាធម៌ទទួលរូបខ្ញុំឲ្យរស់នៅក្នុងប្រទេសរបស់គេឬទេ? តើគេនឹងទទួលខ្ញុំយ៉ាងដូចម្តេច? ខ្ញុំបានកម្លាចិត្តខ្លួនឯងឲ្យក្លាហានឡើង ហើយព្រមទទួលយកអ្វីៗតាមយថាកម្មទៅចុះ ។ ជីវិតខ្ញុំនៅលើមាត់រណ្តៅមរណៈស្រេចទៅហើយ បើជីវិតត្រូវអស់ត្រឹមនេះ ក៏មិនមានហេតុផលអ្វីត្រូវស្តាយដែរ ។ ពុក គីម និងហ៊ា ឡាយ សហសេវិករួមដំណើរជាមួយខ្ញុំ ជាបុគ្គលដែលខ្ញុំគោរពរាប់អាន និងទុកចិត្តជាទីបំផុតជាមនុស្សដែលមានកាយសម្បទាមាំទាំជាងខ្ញុំ ឥឡូវគាត់បានចាកចោលខ្ញុំតាំងពី៩ថ្ងៃមុនមកម៉្លេះ ។ រូបកាយខ្ញុំពោរពេញទៅដោយសេចក្តីឈឺចាប់ ទាំងកាយ ទាំងចិត្ត ។ មុខរបួសលើជើងទាំងពីររបស់

ខ្ញុំ កាន់តែហើមឡើង កាន់តែឈឺចាប់ឡើង កម្លាំងពលំស្ទើរតែគ្មានសេសសល់នៅក្នុងខ្លួន សេចក្តីស្រេកឃ្លានញាំញីរាងកាយខ្ញុំស្ទើរទ្រាំលែងបាន ។ ខ្ញុំខំងើបឡើង ហើយយកបណ្តូលដើមចេកមកជញ្ជក់ឲ្យសើមបំពង់ក ប៉ុន្តែលទ្ធផល គឺឲ្យខះបំពង់កទៅវិញ ។ ខ្ញុំកកិលកាត់ភូមិចាស់ ដែលឆេះខ្លោចនេះ ហើយបានទៅដល់ដីចម្ការដែលមានអាចម៍បំណះនៅថ្មីៗ ។ នៅឯឆ្ងាយខាងចុងចម្ការម្ខាង ខ្ញុំឃើញបុរសម្នាក់ និងក្មេងជំទង់ម្នាក់កំពុងភ្ជួរ ។ ខ្ញុំខំកកិលទៅមុខសំដៅបុរសអ្នកភ្ជួរនោះ ។ នៅប្រមាណជា៥០ម៉ែត្រពីបុរសនោះ ខ្ញុំខំប្រឹងស្រែកហៅ ជាភាសាសៀមថា ភី (បង) ហើយលើកដៃបក់ហៅ ។ អ្នកភ្ជួរមានការភ័យខ្លាចចង់អូសនង្គ័ល និងគោបម្រុងគេចឆ្ងាយ ។ ខ្ញុំស្រែកហៅជាលើកទីពីរ ទីបីទៀត ទើបអ្នកភ្ជួរ ដាក់នង្គ័ល និងគោ ហើយដើរសំដៅមករកខ្ញុំ ។ ខ្ញុំនៅចាំថា អ្នកភ្ជួរទាំងពីរនាក់បានកៀកដៃខ្ញុំគ្រង់ក្លៀកទាំងសងខាង ហើយអូសខ្ញុំផ្ទារកាត់ដីអាចម៍បំណះ ។ ចាប់ពីត្រឹមនោះមក ខ្ញុំលែងដឹងអ្វីទាំងអស់ ព្រោះបាត់ស្មារតី ។ ខ្ញុំមិនដឹងថា អស់រយៈពេលប៉ុន្មានពិតប្រាកដ ស្រាប់តែខ្ញុំឮសំឡេងមនុស្សខ្សឹបខ្សៀវជាភាសាសៀម ខ្ញុំខំបើកភ្នែកឡើងឃើញមុខមនុស្ស និងភ្នែកជាច្រើនសម្លឹងមកលើខ្ញុំ ។ ខ្ញុំមិនដឹងថា ខ្លួនខ្ញុំនៅទីណាឡើយ ។ មាត់ខ្ញុំដែលស្ងួតដូចក្រដាស ស្រាប់តែទទួលទឹកពីក្នុងស្លាបព្រាដែលប៉ះទង្គិចនឹងធ្មេញខ្ញុំ ។ ខ្ញុំដឹងថា មានអ្នក មានចិត្តល្អកំពុងបញ្ចុកទឹកខ្ញុំ ។ ទឹកចូលក្នុងខ្លួនខ្ញុំប៉ុណ្ណាកម្លាំងកាយខ្ញុំកើនប៉ុណ្ណឹងដែរ ។ ខ្ញុំអត់ធ្មត់ដោយសុខចិត្តទទួលទានទឹកម្តងមួយស្លាបព្រាៗសិន ។ នៅពេលអ្នកសប្បុរសភ្លេចខ្លួន ខ្ញុំស្រវាផ្តិលទឹកពីដៃអ្នកសប្បុរសជាថ្មីទៀត មកផឹករហូតដល់អស់ទឹកពីផ្តិល ។ ខ្ញុំលើកដៃសំពះសុំអភ័យទោសផង និងថ្លែងអំណរគុណផងដល់អ្នកមានចិត្តធម៌ ។ ខ្ញុំងើបឡើងអង្គុយដោយខ្លួនឯង ។ ខ្ញុំកំពុងស្ថិតនៅប្របចិញ្ចើមថ្នល់ធំ ដែលមានចរាចរណ៍ប្រកបដោយល្បឿនខ្លាំង ។ អ្នកដំណើរឈប់មើលរូបកាយដូចអសុភរបស់ខ្ញុំ ដែលជាខ្មែររត់ចោលស្រុក ។ សូមខ្មែរអ្នកល្មោភអំណាចទាំងឡាយជំនាន់ក្រោយល្មមគិតដល់រឿងអតីតកាលដ៏អសោចនេះផង ។ អ្នកបន្តោកពូជខ្មែរបានត្រឹមតែស្លាប់ដូចសត្វតិរច្ឆាន ។

ខ្ញុំមានកម្លាំងបានបន្តិច គេលើកខ្ញុំដាក់លើម៉ូតូហើយគេដឹករូបខ្ញុំឡើងលើភ្នំមួយដែលមានបន្ទាយទាហានស្ថិតនៅទីនោះ ។ គេដាក់ខ្ញុំចុះពីលើម៉ូតូឲ្យខ្ញុំអង្គុយផ្ទាល់ដីក្រោមម្លប់ឈើ ។ មួយសន្ទុះក្រោយមកមានទាហានពីរនាក់ ដើរសំដៅមករកខ្ញុំ ។ ម្នាក់ជាអ្នកសួរ និងម្នាក់ទៀតជាអ្នកបកប្រែ ។ សំណួរដំបូងគឺ៖

- ឯងឃ្លានឬទេ?

ខ្ញុំឆ្លើយថា ខ្ញុំឃ្លានណាស់ ។

- ឯងមកពីណា?

ខ្ញុំឆ្លើយថា ខ្ញុំមកពីដែនខ្មែរ

- ហេតុអ្វីបានជាឯងរត់?

គេចង់សម្លាប់ខ្ញុំ ។

- ព្រោះអ្វី? ព្រោះឯងជាមនុស្សខិលឬ?

ពុំមែនដូចនោះទេ

- ដូច្នេះមានតែឯងក្បត់នឹងគេ?

ខ្ញុំជាប្រជាជនថ្មីដែលគេចង់សម្លាប់ ។

- អ្វីទៅជាប្រជាជនថ្មី?

ប្រជាជនថ្មី គឺជាប្រជាជនដែលពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ រស់នៅក្រោមរបបសាធារណរដ្ឋ ។

- ឯងនៅធ្វើអីទីនោះ?

ខ្ញុំធ្វើស្រែ ។

- ឯងមានអ្វីខ្លះ ចូរយកចេញមក?

ខ្ញុំដាក់ឥវ៉ាន់របស់ខ្ញុំទៅលើដីមានកន្សែងយ័ន្តសស្លែត ដែលខ្ញុំជញ្ជក់វាកាលនៅក្នុងព្រៃរហូតដល់ឆ្លកពណ៌ ។ ខ្សែបង្កេះបញ្ចើកែ្អកមួយរយមុខ វល្លិចងឯង និងត្រីវិស័យ ។

- ចុះនៅនឹងកឯងនេះ?

បាទ ជាកញ្ចប់ធាតុរបស់ឪពុកខ្ញុំ

- ចូរឯងរុះវាឲ្យអញមើល

បាទ សុទ្ធតែជាផេះ រុះពុំកើតទេ សូមលោកមេត្តាយោគយល់ ។ ទាហានម្នាក់នោះបានយកដៃមកឈ្ងីលើកូនថង់ភ្ជិតមុខដែលភរិយាខ្ញុំដេរដាក់ធាតុឪពុករបស់ខ្ញុំ ហើយធ្វើខ្សែកអំបោះពាក់ព្យួរនៅករបស់ខ្ញុំ ។ រួចគេលើកខ្ញុំឲ្យឈរ គេលូកដៃស្ទាបរាវសពុកខ្នែងចុងក្រោយគេលូកក្នុងហោប៉ៅខោខ្លីរបស់ខ្ញុំឃើញចិញ្ចៀនត្បូងកណ្តៀងមួយវង់នៅបាតហោប៉ៅដែលមិត្តខ្ញុំឈ្មោះ តាំង ស្រេង បានឲ្យខ្ញុំកាលពីអំឡុងឆ្នាំ១៩៧៣ ។ ***(តទៅលេខក្រោយ)***

(តទៅលេខក្រោយ)

**ជា សីហា**

# សៀវភៅរំឭកវិញ្ញាណក្ខន្ធអ្នកដែលបានស្លាប់ នៅក្នុងរបបខ្មែរក្រហម










មជ្ឈមណ្ឌលឯកសារកម្ពុជា គ្រោងនឹងបោះពុម្ពផ្សាយនូវសៀវភៅមានកត់ត្រាឈ្មោះរបស់អ្នកដែលស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម ។ កន្លងមក មជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រងនូវឈ្មោះអ្នកដែលស្លាប់ជាង១លាននាក់រួចមកហើយ ។ ប្រសិនបើលោកយាយ លោកតា អ៊ំ ពូ មីង ប្រាថ្នាចង់ឲ្យឈ្មោះសមាជិកក្រុមគ្រួសារដែលបានស្លាប់បាត់បង់ជីវិតមាននៅក្នុងសៀវភៅនេះ សូមទាក់ទងមកកាន់មជ្ឈមណ្ឌលឯកសារកម្ពុជាតាមរយៈ អេង កុកថាយ ទូរស័ព្ទលេខ ០១២ ៧៩៧ ៣៩៨ ឬ អ៊ីម៉ែល ៖ truthkokthay@dccam.org ឲ្យបានឆាប់រហ័សតាមពេលវេលាដែលអាចធ្វើទៅបាន ។

***សូមផ្តល់ព័ត៌មានដូចខាងក្រោម៖***

១) ឈ្មោះអ្នកប្រកាសប្រាប់, ២) តើមានបងប្អូនបង្កើតរួមទាំងឪពុកម្តាយស្លាប់ប៉ុន្មាននាក់នៅក្នុងសម័យខ្មែរក្រហម? ៣) ឈ្មោះអ្នកស្លាប់, ៤) ភេទអ្នកស្លាប់, ៥) អាយុអ្នកស្លាប់ (បើអាចចាំបាន), ៦) ត្រូវជាអ្វីនឹងអ្នកប្រកាស (ឧទាហរណ៍៖ ឪពុក ម្តាយ បងប្រុស ប្អូនប្រុស បងស្រី ឬប្អូនស្រី), ៧) សាច់រឿងទាក់ទងនឹងការស្លាប់ (ឧទាហរណ៍ ៖ ស្លាប់នៅទីណា? មូលហេតុអ្វី?), ៨) វត្ថុតាងទាក់ទងនឹងអ្នកស្លាប់ (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ), ៩) ព័ត៌មានសម្រាប់មជ្ឈមណ្ឌលទាក់ទង (ឧទាហរណ៍៖ លេខទូរស័ព្ទ អាសយដ្ឋាន) ។

***ប្រសិនបើចង់ស្វែងរកអ្នកដែលបាត់ខ្លួនសូមផ្តល់ព័ត៌មានខាងក្រោម៖***

១) ឈ្មោះអ្នកបាត់ខ្លួន, ២) ភេទ, ៣) អាយុ, ៤) ត្រូវជាអ្វី, ៥) សាច់រឿងទាក់ទងនឹងការបែកគ្នា, ៦) វត្ថុតាងទាក់ទងនឹងអ្នកបាត់ខ្លួន (ឧទាហរណ៍៖ រូបថត ឯកសារ ឬវត្ថុផ្សេងៗ) ។

ដើម្បីយុត្តិធម៌និងការចងចាំ
ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការផ្សះផ្សាជាតិ

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ សហរដ្ឋអាមេរិក (USAID)
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម.៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ ៖ (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ ៖ (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 183, 2015 ◆ Funded by USAID.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.